សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីសវនាការ ក្នុងរឿងរដ្ឋប្បវេណី

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **វ៉េង សិរីរ័ត្ន**
កញ្ញា **ថន រស្មីបញ្ញា**

ណែនាំដោយ
លោកគ្រូ **ហួ វាសនា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **២៤**

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ម៉េង សិរីរ័ត្ន** និងឈ្មោះ **ថន រស្មីបញ្ញា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី**២៤** ក្នុងឆ្នាំសិក្សា ២០២០-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ

**លោកអ្នកមានគុណរបស់យើងខ្ញុំ** ដែលបានផ្តល់កំណើត ខិតខំចិញ្ចឹមបីបាច់ ថែរក្សា ផ្គត់ផ្គង់ការរៀនសូត្រ ការទូន្មាន ការប្រៀនប្រដៅ ចាប់តាំងពីថ្នាក់មត្តេយ្យ រហូតមកដល់កម្រិតថ្នាក់បរិញ្ញាបត្រ ដែលលោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីរ បានពុះពារគ្រប់ឧបសគ្គ ប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្ត ក្នុងការជួយទំនុកបម្រុងគ្រប់បែបយ៉ាង ទាំងបញ្ញា និងស្មារតី ដើម្បីឱ្យកូនៗមានអនាគតភ្លឺស្វាង និងអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គមជាតិ។ សេចក្តីទាំងអស់នេះ ពុំអាចកាត់ថ្លៃបាន និងមិនអាចរៀបរាប់ឱ្យអស់សេចក្តីនៅក្នុងសេចក្តីថ្លែងអំណរគុណនេះបានឡើយ។

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ជាទីកន្លែងដែលបានបណ្តុះបណ្តាល និងផ្តល់ចំណេះដឹងក្នុងការស្រាវជ្រាវផ្នែកនីតិសាស្ត្រ ចាប់តាំងពីឆ្នាំទី១ រហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយភាពជោគជ័យ និងបានផ្តល់ចំណេះដឹងផ្នែកច្បាប់បានយ៉ាងល្អប្រសើរ។

**ឯកឧត្តមបណ្ឌិត លុយ ចន្ធា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រងថ្នាក់ដឹកនាំ លោក-លោកស្រីសាស្ត្រាចារ្យ និងលោកគ្រូ-អ្នកគ្រូទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់នូវពុទ្ធិ ការអប់រំ ការបណ្តុះបណ្តាល និងសីលធម៌យ៉ាងល្អថ្លៃថ្លាដល់យើងខ្ញុំទាំងពីរក្នុងរយៈពេល ៤ ឆ្នាំ កន្លងមកនេះ ឱ្យក្លាយជានិស្សិតដែលប្រកបដោយចំណេះដឹង និងមានសមត្ថភាពពេញលេញ ដើម្បីជាទុនដ៏មានតម្លៃ និងមានប្រសិទ្ធិភាពខ្ពស់ក្នុងការបម្រើនូវវិស័យយុត្តិធម៌ ទៅតាមវិជ្ជាជីវៈនាពេលថ្ងៃខាងមុខ។

**លោកចៅក្រម វ៉ាន់ សុបញ្ញា** និង**លោកក្រឡាបញ្ជី ហួយ ហ៊ី** នៃអយ្យការអមសាលាដំបូងខេត្តកណ្តាល ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរ បានចុះកម្មសិក្សានៅសាលាដំបូងខេត្តកណ្តាល ក្នុងការជួយផ្តល់មតិយោបល់ គំនិត ចំណេះដឹង បទពិសោធន៍ ការណែនាំ និងបានផ្តល់ឱកាសឱ្យយើងខ្ញុំទាំងពីរបានសិក្សាស្វែងយល់អំពីដំណាក់កាលនីមួយៗ នៃនីតិវិធីសំណុំរឿងក្តី។ មិនតែប៉ុណ្ណោះ លោកទាំងពីរ ក៏បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀនអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីក្នុងសំណុំរឿងក្តីរដ្ឋប្បវេណី និងបានចែករំលែកបទពិសោធន៍លល្អៗ ទាក់ទងនឹងវិជ្ជាជីវៈជាក្រឡាបញ្ជី។

**លោកសាស្ត្រាចារ្យជំនួយ ញឹក ឧត្តម** ជាប្រធានការិយាល័យស្រាវជ្រាវ ដែលបានអនុញ្ញាតឱ្យយើង

ខ្ញុំទាំងពីរ ធ្វើការស្រាវជ្រាវលើប្រធានបទនេះ ឬស្រដៀងនេះក៏ដោយ ក៏លោកតែងតែអនុគ្រោះ ដោយសារតែការស្រាវជ្រាវអត្ថបទ និងការឡើងការពារសារណានេះតែងតែមានសណ្ឋាន និងមានបច្ចេកទេសក្នុងការបកស្រាយខុសប្លែកពីគ្នា។

ជាពិសេស **លោកគ្រូ ហួ ខាសនា** ដែលជាលោកគ្រូណែនាំ និងដឹកនាំក្នុងការសរសេរសារណារបស់ក្រុមយើងខ្ញុំ ដោយលោកបានខិតខំទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការផ្តល់ដំបូន្មាន គំនិត ពុទ្ធិ យោបល់ ការលើកទឹកចិត្ត ការណែនាំ ការកែសម្រួលប្រធានបទ អត្ថរស ការពិនិត្យពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លោងឃ្លា និងបង្ហាញផ្លូវដល់យើងខ្ញុំទាំងពីរ ចាប់តាំងពីថ្ងៃដែលបានចាប់ផ្តើមសរសេរសារណាបញ្ចប់ការសិក្សា រហូតដល់ថ្ងៃដែលទទួលបានស្នាដៃមួយនេះជាស្ថាពរ ដែលគុណទាំងនេះ គឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់ថ្លៃបានឡើយមកលើយើងខ្ញុំទាំងពីរ។

ជាកិច្ចបញ្ចប់នេះ យើងខ្ញុំទាំងពីរសូមបួងសួងដល់បារមីនៃវត្ថុស័ក្តសិទ្ធិទាំងពួងនៅលើលោក មេត្តាជួយថែរក្សាអ្នកមានគុណរបស់យើងខ្ញុំទាំងពីរ ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យស្រាវជ្រាវ លោក-លោកស្រីសាស្ត្រាចារ្យ និងលោកគ្រូ-អ្នកគ្រូទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេស **លោកគ្រូ ហួ ខាសនា លោកចៅក្រម ខ៉ាន់ សុបញ្ញា** និង**លោកគ្រូឧត្តមបញ្ញា ហួយ ហ៊ី** សូមឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងពុទ្ធពរជ័យទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរជានិស្សិត ដែលកំពុងនឹងបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានសិក្សារយៈពេល ៤ ឆ្នាំ កន្លងមកនេះ បានធ្វើឱ្យយើងខ្ញុំមានមោទនភាពជាពន់ពេក ដោយសារតែការសិក្សាផ្នែកនីតិសាស្ត្រ ពិតជាបានផ្ដល់នូវសារៈសំខាន់ណាស់សម្រាប់យើងខ្ញុំទាំងពីរក្នុងនាមជាយុវជនជំនាន់ក្រោយ។ ទោះបីជាមានកាលៈទេសៈខ្លះយើងខ្ញុំ បានជួបប្រទះនូវឧបសគ្គយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែព្យាយាម តស៊ូ ក្រេបយកចំណេះដឹង ដោយមិនព្រមបោះបង់ចោលក្នុងគោលបំណងដ៏ធំ ដើម្បីសម្រេចនូវការសិក្សាផ្នែកនីតិសាស្ត្រ ប្រកបដោយភាពជោគជ័យជាស្ថាពរ។ ការបញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យនេះ យើងខ្ញុំមានគោលបំណងក្នុងការសរសេរសារណា ដើម្បីទុកជាស្នាដៃ និងទុកជាការរំលឹកសម្រាប់យើងខ្ញុំទាំងពីរ បន្ទាប់ពីបញ្ចប់ការសិក្សាអស់រយៈពេល ៤ ឆ្នាំ កន្លងមក។

ជាកត្តាចម្បង ដោយសារមានការសិក្សាពីមុខវិជ្ជាសំខាន់ៗកន្លងមក បានធ្វើឱ្យយើងខ្ញុំមានចំណាប់អារម្មណ៍ជាខ្លាំងលើមុខវិជ្ជា ដែលបានសិក្សាទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាមុខវិជ្ជាដ៏សំខាន់មួយបានរួមចំណែកក្នុងការគ្រប់គ្រងសង្គមជាតិឱ្យមានសណ្ដាប់ធ្នាប់ និងសន្តិភាព។ កាលដែលយើងខ្ញុំទាំងពីរជ្រើសរើសប្រធានបទ “**តួនាទី និងភារកិច្ចក្រឡាបញ្ជីសវនាការក្នុងរឿងរដ្ឋប្បវេណី**” មកធ្វើការស្រាវជ្រាវ ដោយសារតែយើងខ្ញុំយល់ឃើញថា ប្រធានបទនេះថ្មី ដែលពុំទាន់មានអតីតសិស្សច្បងណាម្នាក់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ធ្វើការសិក្សាស្រាវជ្រាវ និងតម្កល់ទុកជាឯកសារនៅបណ្ណាល័យនៅឡើយទេ។ ម៉្យាងទៀត កាលដែលលើកឡើងនូវប្រធានបទមួយនេះ ក្នុងគោលបំណងចង់សិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី ដើម្បីស្វែងយល់អំពីវិជ្ជាជីវៈក្រឡាបញ្ជី និងទុកជាបទពិសោធន៍ក្នុងការប្រកបការងារនាថ្ងៃអនាគត។

ជាការពិតណាស់ ការសរសេរសារណានេះ ស្រាវជ្រាវក្នុងន័យចែករំលែកជាបទពិសោធន៍ និងគន្លឹះក្នុងការស្វ័យសិក្សាបញ្ចប់ការសិក្សា។ កត្តាចម្បងនេះហើយ ទើបយើងខ្ញុំបានខិតខំ ប្រឹងប្រែង រិះរក និងផ្ដួចផ្ដើមគំនិតធ្វើការចងក្រងសារណានេះឡើង ដើម្បីផ្ដល់ជាភាពងាយស្រួលដល់បញ្ញវន្តជំនាន់ក្រោយៗ យកមកធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ។

ជាចុងបញ្ចប់ យើងខ្ញុំសង្ឃឹមយ៉ាងមុះមុតថា សារណារនេះអាចផ្ដល់គុណប្រយោជន៍ដល់បញ្ញវន្តជំនាន់ក្រោយៗ ដែលមានចំណាប់អារម្មណ៍ក្នុងការសិក្សាស្វែងយល់អំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីនាពេលសវនាការ។ ទន្ទឹមនឹងគុណសម្បត្តិដ៏មានតម្លៃនៃសារណានេះ បើមានការខុសឆ្គង ឬខ្វះចន្លោះនូវអត្ថបទ ឬខ្លឹមសារ ឬពាក្យពេចន៍ណាមួយនោះ យើងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុន ព្រមទាំងថ្លែងអំណរគុណនៅពេលទទួលបានសេក្ដីអធិប្បាយ ផ្ដល់មតិយោបល់កែលម្អ ក្នុងន័យស្ថាបនាពីលោកអ្នក។

# និយមន័យ និងពាក្យសម្គាល់ក្នុងរឿងរដ្ឋប្បវេណី

- **ដើមចោទ** ៖ គឺជាភាគីដែលផ្តួចផ្តើមដាក់ពាក្យបណ្តឹងទៅតុលាការក្នុងរឿងក្តីរដ្ឋប្បវេណី។
- **ចុងចម្លើយ** ៖ គឺជាបុគ្គលដែលត្រូវបានភាគីម្ខាងទៀតមានឋានៈជាដើមចោទ ប្តឹងទៅតុលាការក្នុងរឿងក្តីរដ្ឋប្បវេណី។
- **ចៅក្រម** ៖ គឺជាមន្ត្រីសាធារណៈ ដែលទទួលបានការជ្រើសតាំងឱ្យដឹកនាំគ្រប់គ្រងកិច្ចការច្បាប់នៅតាមសាលាជម្រះក្តី។
- **អ្នកតំណាងដោយអាណត្តិ** ៖ គឺជាអ្នកដែលទទួលបានសិទ្ធិអំណាចដែលទទួលបានពីអាណត្តិទាយក។
- **ហេដ្ឋារចនាសម្ព័ន្ធ** ៖ គឺសំដៅលើការរចនា ប្រព័ន្ធ នីតិវិធី ក្រម ឬនិយាម និងបណ្តាញទំនាក់ទំនងការងារ។
- **វិសោធនកម្ម** ៖ គឺជាការកែប្រែ ឬបន្ថែមទៅលើបទដ្ឋានច្បាប់ដែលមានរួចហើយ។
- **សេនាធិការ** ៖ គឺជាអ្នកជំនួយ ឬហៅម៉្យាងទៀតថា ជាលេខាធិការរបស់ចៅក្រម។
- **កាតព្វកិច្ច** ៖ គឺជាចំណងតាមផ្លូវច្បាប់ ដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ ហៅថា កូនបំណុល មានករណីកិច្ចចំពោះបុគ្គលម្នាក់ទៀត ហៅថា ម្ចាស់បំណុល។
- **បទដ្ឋានគតិយុត្ត** ៖ គឺជាវិធានច្បាប់ ឬបទបញ្ជាផ្សេងៗ ដែលបានបង្កើតឡើងដោយរដ្ឋ។
- **វិសាមញ្ញ** ៖ គឺសំដៅលើការប្លែកពីធម្មតា ដែលខុសប្រក្រតី ដែលមិនមែនជាសាធារណៈ។
- **កម្មវត្ថុនៃបណ្តឹង** ៖ គឺជាគោលបំណងនៃការទាមទាររបស់អ្នកប្តឹង។
- **ប្រាក់ពន្ធ** ៖ គឺជាប្រាក់មិនចំពោះប្រាក់ពន្ធនៃគ្រឿងបរិភោគ និងគ្រឿងប្រើប្រាស់ផ្សេងៗ។
- **ប្រាក់ប្រដាប់ក្តី** ៖ គឺជាប្រាក់ដែលត្រូវបង់សម្រាប់ចាត់ការរឿងក្តីរបស់ខ្លួនទៅតាមបញ្ញត្តិច្បាប់។
- **សោហ៊ុយ** ៖ គឺជាប្រាក់សម្រាប់ចាយ តម្លៃចាយប្រើដើមទុនជាដើម។
- **ឆន្ទានុសិទ្ធិ** ៖ គឺជាអំណាចដែលប្រគល់ឱ្យចៅក្រម រើសយកមធ្យោបាយណាមួយតាមការវាយតម្លៃរបស់ខ្លួនយកមកដោះស្រាយបញ្ហាណាមួយ។
- **ការវិនិច្ឆ័យ** ៖ គឺជាសេចក្តីសម្រេច ឬដីកាបង្គាប់របស់តុលាការ ឬរបស់សាលាជម្រះក្តីដែលកំណត់ការដាក់ទណ្ឌកម្ម។
- **សិទ្ធិអំណាច** ៖ គឺជាលទ្ធភាពតាមផ្លូវច្បាប់ក្នុងការធ្វើអ្វីមួយ។
- **សក្ខីភាព** ៖ គឺជាភស្តុតាង ដែលផ្តល់ឱ្យដោយសាក្សីដែលបានស្បថ។
- **អានុភាព** ៖ គឺជាផលគតិយុត្ត ដែលកើតចេញពីលិខិតគតិយុត្តដូចជា កិច្ចសន្យាច្បាប់ សេចក្តីសម្រេចរបស់តុលាការ។

# មាតិកា


**ទំព័រ**

**សេចក្ដីផ្ដើម** ........................................ **១**

**ជំពូកទី១**

**សញ្ញាណទូទៅនៃក្រឡាបញ្ជី**

**កថាខណ្ឌទី១៖ អត្ថន័យក្រឡាបញ្ជី និងប្រវត្តិនៃការបង្កើតក្រឡាបញ្ជី** .................... **៧**

**ក.** អត្ថន័យក្រឡាបញ្ជី ........................................ ៧

**ខ.** ប្រវត្តិនៃការបង្កើតក្រឡាបញ្ជី ........................................ ៧

**កថាខណ្ឌទី២៖ វិជ្ជាជីវៈក្រឡាបញ្ជី** ........................................ **៨**

**ក.** គោលបំណងនៃការបង្កើតឱ្យមានក្រឡាបញ្ជី ........................................ ៩

**ខ.** លក្ខខណ្ឌនៃការជ្រើសរើសក្រឡាបញ្ជីនាពេលបច្ចុប្បន្ន ........................................ ៩

**គ.** ការបែងចែកក្រឡាបញ្ជី និងឯកសណ្ឋាន ........................................ ១០

**គ.១.** ការបែងចែកក្រឡាបញ្ជី ........................................ ១០

**គ.២.** ឯកសណ្ឋានក្រឡាបញ្ជី ........................................ ១០

**ឃ.** ការផ្អាកវិជ្ជាជីវៈក្រឡាបញ្ជី និងវិសមិតភាពរបស់ក្រឡាបញ្ជី ........................................ ១១

**ឃ.១.** ការផ្អាកវិជ្ជាជីវៈក្រឡាបញ្ជី ........................................ ១១

**ឃ.២.** វិសមិតភាពក្រឡាបញ្ជី ........................................ ១១

**ជំពូកទី២**

**តួនាទី និងភារកិច្ចក្រឡាបញ្ជីមុនពេលសវនាការ**

**កថាខណ្ឌទី១៖ កិច្ចការក្រឡាបញ្ជីពេលមានបណ្ដឹង** ........................................ **១៣**

**ក.** កិច្ចការក្រឡាបញ្ជីក្នុងការទទួលបណ្ដឹងដោយផ្ទាល់មាត់ ........................................ ១៣

**ខ.** កិច្ចការក្រឡាបញ្ជីក្នុងការទទួលបណ្ដឹងពីរដ្ឋបាលតុលាការ ........................................ ១៣

**គ.** ការថែរក្សាសំណុំរឿងរបស់ក្រឡាបញ្ជី ........................................ ១៣

**ឃ.** ការត្រួតពិនិត្យពាក្យបណ្ដឹង និងការបញ្ជូនពាក្យបណ្ដឹង ........................................ ១៣

**ឃ.១.** ការត្រួតពិនិត្យពាក្យបណ្ដឹង ........................................ ១៣

**ឃ.២.** ការបញ្ជូនពាក្យបណ្ដឹង ........................................ ១៤

**កថាខណ្ឌទី២៖ ការរៀបចំឯកសារក្នុងចំណាត់ការរឿងក្ដី** ........................................ **១៥**

**ក.** ដីកាសម្រេចបង្គាប់ឱ្យបង់ពន្ធដាក់ពាក្យសុំ និងដីកាសម្រេចលើកចោលពាក្យបណ្តឹង.................... ១៥
**ក.១.** ដីកាសម្រេចបង្គាប់ឱ្យបង់ពន្ធដាក់ពាក្យសុំ.................................................................. ១៥
**ក.២.** ដីកាសម្រេចលើកចោលពាក្យបណ្តឹង ........................................................................ ១៥
**ខ.** ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាត និងដីកាសម្រេចលើកចោលពាក្យបណ្តឹង................. ១៥
**ខ.១.** ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាត ................................................................ ១៥
**ខ.២.** ដីកាសម្រេចលើកចោលពាក្យបណ្តឹង ........................................................................ ១៥
**គ.** ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងដីកាសម្រេចលើកចោលពាក្យបណ្តឹង ១៦
**គ.១.** ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ.............................................. ១៦
**គ.២.** ដីកាសម្រេចលើកចោលពាក្យបណ្តឹង........................................................................ ១៦
**ឃ.** ដីកាកោះហៅ និងលិខិតអញ្ជើញ ............................................................................ ១៧
**ឃ.១.** ដីកាកោះហៅ ...................................................................................................... ១៧
**ឃ.២.** លិខិតអញ្ជើញ...................................................................................................... ១៧
**ឃ.៣.** របាយការណ៍បញ្ជូន............................................................................................... ១៨

## ជំពូកទី៣

## តួនាទី និងភារកិច្ចក្រឡាបញ្ជីក្នុងដំណាក់កាល

## នីតិវិធីត្រៀមសម្រាប់ការទាញហេតុ

**កថាខណ្ឌទី១៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីមុនពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................................................................................ ២០**
**ក.** ពិនិត្យរបាយការណ៍ ...................................................................................................... ២០
**ខ.** ការពិនិត្យវត្តមាន និងអត្តសញ្ញាណគូភាគី............................................................................ ២០
**គ.** រៀបចំបន្ទប់ដំណើរការនីតិវិធី ........................................................................................ ២១
**កថាខណ្ឌទី២៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីអំឡុងពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................................................................................ ២១**
**ក.** ការកត់ត្រានូវដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................ ២១
**ខ.** ចំណុចសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល .............................. ២២
**កថាខណ្ឌទី៣៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីក្រោយពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................................................................................ ២២**

**ក.** ការធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២៣
**ខ.** ការរៀបចំដីកាកោះហៅ និងលិខិតអញ្ជើញទៅអ្នកពាក់ព័ន្ធ ........ ២៣

## ជំពូកទី៤
## តួនាទី និងភារកិច្ចក្រឡាបញ្ជីក្នុងដំណាក់កាល
## ការទាញហេតុផលដោយផ្ទាល់មាត់

**កថាខណ្ឌទី១៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីមុនពេលការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៥**
**ក.** ការពិនិត្យរបាយការណ៍បញ្ជូន ........ ២៥
**ខ.** ការពិនិត្យវត្តមាន និងអត្តសញ្ញាណគូភាគី ........ ២៥
**គ.** រៀបចំបន្ទប់សវនាការ ........ ២៦
**ឃ.** ការដឹកនាំធ្វើសម្បថ (ករណីមានសាក្សី) ........ ២៦
**កថាខណ្ឌទី២៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីអំឡុងពេលការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៦**
**ក.** ការកត់ត្រានូវដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៧
**ខ.** ចំណុចសារធាតុនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៧
**កថាខណ្ឌទី៣៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីក្រោយពេលការទាញហេតុផលដោយផ្ទាល់មាត់ ........ ២៨**
**ក.** ការធ្វើកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាត់មាត់ ........ ២៨
**ខ.** ការពិនិត្យភស្តុតាងដោយសមូហវិធី ........ ២៩
**គ.** ការប្រកាសសាលក្រម ........ ២៩
**គ.១.** ការកត់ត្រាដំណើរការនៃការប្រកាសសាលក្រម ........ ៣០
**គ.២.** ការកត់ត្រានូវដំណើរការនៃសាលក្រមនៃរឿងក្តីដែលមានចំនួនទឹកប្រាក់តិច ........ ៣០
**ឃ.** ការបញ្ជូនអនុសារសាលក្រម ........ ៣១
**ង.** របាយការណ៍បញ្ជូន ........ ៣១
**កថាខណ្ឌទី៤៖ ការចារនូវការចូលជាស្ថាពរនៃសាលក្រមក្នុងករណីមិនមានបណ្តឹងទាស់ ឬបណ្តឹងឧទ្ធរណ៍ ........ ៣១**
**ក.** លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម ........ ៣២

ខ. ពាក្យសុំឱ្យផ្ដល់រូបមន្ដអនុវត្ត................................................................................................................ ៣៣
ខ.១. ចំណុចដែលត្រូវសរសេរក្នុងរូបមន្ដអនុវត្ត........................................................................................ ៣៣
ខ.២. ការផ្ដល់រូបមន្ដអនុវត្ត................................................................................................................ ៣៣
គ. ការបញ្ជូនសំណុំរឿងទៅតុលាការជាន់ខ្ពស់ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍...................................................៣៤
**សេចក្ដីសន្និដ្ឋាន**................................................................................................................... **៣៥**
**អនុសាសន៍**...........................................................................................................................**៣៧**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

យើងដឹងហើយថា នៅតាមបណ្តាប្រទេសនានានៃសាកលលោកយើងនេះ គឺតែងតែមានប្រព័ន្ធច្បាប់ដើម្បីធ្វើការគ្រប់គ្រងប្រទេសឱ្យមានសន្តិភាព ធានាស្ថេរភាពរបស់ប្រទេសជាតិ និងជាពិសេសនោះ គឺការបង្កើតប្រព័ន្ធយុត្តិធម៌របស់តុលាការ។ ដោយឡែក យើងសង្កេតឃើញថា ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលធ្លាប់បានឆ្លងកាត់នូវសឹកសង្គ្រាមរាប់មិនអស់ ហើយក៏ធ្លាប់បានផ្លាស់ប្តូរនូវគោលនយោបាយជាច្រើនលើកច្រើនសារមកហើយ។ ដោយសារតែការផ្លាស់ប្តូរនេះហើយ ទើបធ្វើឱ្យប្រទេសកម្ពុជាបានបាត់បង់នូវហេដ្ឋារចនាសម្ព័ន្ធ និងយន្តការនៃការគ្រប់គ្រងរដ្ឋស្ទើរគ្រប់វិស័យទាំងអស់ ជាពិសេស គឺវិស័យច្បាប់នេះតែម្តង។ ក្នុងនោះ ចំពោះបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ ក៏ជាកត្តាមួយដ៏សំខាន់មួយដែរ ដែលរាជរដ្ឋាភិបាលកម្ពុជាបានខិតខំយកចិត្តទុកដាក់ពង្រឹងនឹងពង្រីក ហេដ្ឋារចនាសម្ព័ន្ធផ្នែកច្បាប់ និងបានបង្កើតច្បាប់ជាច្រើនផងដែរ។ ច្បាប់ដែលរាជរដ្ឋាភិបាលបានបង្កើតកន្លងមករួមមាន៖ រដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ។ល។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលមិនត្រឹមតែបង្កើតប្រព័ន្ធច្បាប់ជាច្រើននោះទេ ថែមទាំងបានធ្វើវិសោធនកម្មលើច្បាប់មួយចំនួនផងដែរ ដើម្បីធ្វើយ៉ាងណាឱ្យសមស្របទៅនឹងការរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងសមស្របនឹងបរិបទសង្គម។

ច្បាប់នីមួយៗ ដែលបានបង្កើតឡើងសុទ្ធសឹងតែមានគោលបំណងច្បាស់លាស់ និងដាច់ដោយឡែកពីគ្នាដែលស្តែងចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋដោយសេរី និងយុត្តិធម៌។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែង ធ្វើយ៉ាងណាដើម្បីធានាឱ្យប្រជាពលរដ្ឋមានសិទ្ធិសេរីគ្រប់គ្រាន់ និងក្លាយជាម្ចាស់នៃប្រទេសពេញលេញដែលមានន័យថា ត្រូវធ្វើយ៉ាងណាក៏ដោយ ឱ្យប្រព័ន្ធយុត្តិធម៌របស់តុលាការនៅកម្ពុជាមានឯករាជ្យភាព និងសុក្រឹត្យ។ ទន្ទឹមជាមួយគ្នានេះដែរ បើយើងនិយាយដល់ប្រព័ន្ធយុត្តិធម៌របស់កម្ពុជា យើងសង្កេតឃើញថាក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានបង្កើតឡើងនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ គឺជាលិខិតបទដ្ឋាននៃច្បាប់ដែលអាចនិយាយបានថា ជាអត្ថបទច្បាប់បែបទំនើប និងជាអត្ថបទច្បាប់ដែលបានកំណត់អំពីនីតិវិធី តួនាទីនិងភារកិច្ចរបស់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងជនដែលជាប់ពាក់ព័ន្ធជាដើម។ ទន្ទឹមនឹងនេះ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ក៏បានបង្ហាញខ្លះៗអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីផងដែរ ដែលបានដើរតួយ៉ាងសំខាន់នៅក្នុងសំណុំរឿងក្តីរដ្ឋប្បវេណីដែលមាននៅគ្រប់ដំណាក់កាល និងមិនអាចខ្វះបាន គឺនៅមុនពេល អំឡុងពេល និងក្រោយពេលសវនាការនេះតែម្តង។

ខណៈពេលដែលមានការចាប់ផ្តើមសវនាការបានកើតឡើងម្តងៗ គឺយើងសង្កេតឃើញថា មានវត្តមានរបស់ក្រឡាបញ្ជីជានិច្ច ដោយសារតែ ក្រឡាបញ្ជី គឺជាសេនាធិការរបស់ចៅក្រម។ ហើយនៅក្នុងសំណុំរឿងក្តីរដ្ឋប្បវេណីមានដំណាក់កាលជាច្រើន ដែលក្រមនីតិវិធីរដ្ឋប្បវេណីបាននិយាយអំពីការអនុវត្តតាមដំណាក់កាល

នីមួយៗ និងមានចំណុចមួយចំនួនដែរ ដែលក្រមនីតិវិធីរដ្ឋប្បវេណីពុំបានលើកឡើងនូវតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី។ ហើយរាល់ការចេញលិខិត ឬឯកសារគតិយុត្តណាមួយ ដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ក្នុងរឿងក្តីរដ្ឋប្បវេណី គឺដែលត្រូវធ្វើឡើងដោយក្រឡាបញ្ជី ក៏ប៉ុន្តែត្រូវស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ចៅក្រមទទួលបន្ទុកនៃរឿងក្តី។

យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ គឺជាប្រព័ន្ធច្បាប់ដែលមានគោលបំណងច្បាស់លាស់ ដែលបានបង្ហាញអំពីឆន្ទៈនៃការបង្កើតរបស់រាជរដ្ឋាភិបាល ដែលត្រូវធ្វើយ៉ាងណាឱ្យប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជាមានភាពរីកចម្រើន សន្តិភាព សណ្តាប់ធ្នាប់ល្អ និងសុក្រឹត្យភាព។ ជាមួយគ្នានេះផងដែរ ក្រមនីតិវិធីរដ្ឋប្បវេណីក៏បានលើកឡើងអំពីការដោះស្រាយបញ្ហាវិវាទនៅក្នុងរឿងក្តីរដ្ឋប្បវេណីទៅតាមច្បាប់ចែង ដោយបានបង្ហាញអំពីគោលបំណង ការទទួលខុសត្រូវរបស់តុលាការ ការទទួលខុសត្រូវរបស់គូភាគី នីតិវិធីក្នុងការជំនុំជម្រះរឿងក្តី និងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ជាដើម។ ហើយការបង្ហាញខាងលើនេះ គឺជាអ្វីដែលច្បាប់ចង់បង្ហាញអំពីដំណើរការ ដំណាក់កាល និងវិធីសាស្ត្រនៃការដោះស្រាយរឿងក្តីរបស់តុលាការផងដែរ។

ម៉្យាងទៀត ដើម្បីឈានដល់ការបញ្ចប់វិវាទនៃរឿងក្តីទាំងមូល ត្រូវឆ្លងកាត់នៅដំណាក់កាលមួយចំនួនរួមមាន៖ ដំណាក់កាលនៅមុនពេលសវនាការ ដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ឱ្យស្របទៅតាមនីតិវិធីនៃសំណុំរឿងក្តី មិនតែប៉ុណ្ណោះ ត្រូវគោរពតាមគោលការណ៍ដែលច្បាប់បានកំណត់។

## ១. ចំណោទបញ្ហានៃការដោះស្រាយ

ក្នុងការជ្រើសរើសយកនូវប្រធានខាងលើនេះ មករៀបចំធ្វើជាសារណាបញ្ចប់ការសិក្សា ដោយសារតែយើងខ្ញុំបានសិក្សាស្វែងយល់អំពីបញ្ហា និងអត្ថប្រយោជន៍ដែលកំពុងកើតមាននៅក្នុងសង្គមបច្ចុប្បន្ន ក្រោយពេលដែលយើងខ្ញុំបានសិក្សាស្រាវជ្រាវលើឯកសារ និងសៀវភៅសិក្សាមួយចំនួន ដែលបាននិយាយអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី។ ប៉ុន្តែ យើងងាកមកមើលបញ្ហាមួយចំនួន ដែលមាននៅអង្គការតុលាការរួមមាន៖ កង្វះក្រឡាបញ្ជី ដែលបណ្តាលឱ្យការអនុវត្តនៃរឿងក្តីមានភាពយឺតយ៉ាវ និងការអនុវត្តរឿងក្តីនៅក្នុងនីតិវិធីមួយចំនួនមានរយៈពេលខ្លី ដែលបណ្តាលឱ្យក្រឡាបញ្ជីកកស្ទះនូវការអនុវត្តច្បាប់។

ចំពោះបញ្ហា ដែលបានចោទសួរឡើងទាក់ទងនឹងប្រធានបទរបស់យើងខ្ញុំ ដែលត្រូវបានលើកឡើងយកមកពិភាក្សានៅពេលនេះគឺ៖

**ក**. តើក្រឡាបញ្ជីជានរណា?

**ខ**. តើក្រឡាបញ្ជី ត្រូវបានបង្កើតឡើងចាប់តាំងពីពេលណា?

**គ**. ហើយក្រឡាបញ្ជី ត្រូវបានបង្កើតឡើងក្នុងគោលបំណងអ្វី?

**ឃ.** តើនៅមុនពេល អំឡុងពេល និងក្រោយពេលសវនាការ ក្រឡាបញ្ជី ត្រូវមានតួនាទី និងភារកិច្ចអ្វីខ្លះ?

**ង.** ក្នុងករណីមួយចំនួន ប្រសិនបើច្បាប់មិនបានចែង តើក្រឡាបញ្ជីអាចមានសិទ្ធិអនុវត្តបានដែរឬទេ?

## ២. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺចង់សិក្សាលម្អិតទៅលើតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី នីតិវិធីរបស់ក្រឡាបញ្ជីក្នុងពេលអនុវត្តនាពេលសវនាការនៅសាលាដំបូង និងដំណាក់កាលនៃរឿងក្ដីរដ្ឋប្បវេណី។ គោលបំណងទាំងនេះ បានផ្ដល់អត្ថប្រយោជន៍ដល់អ្នកអាន និងសង្គមជាតិរួមមាន៖

- យល់ដឹងអំពីគោលការណ៍ជាមូលដ្ឋាននៃច្បាប់
- យល់ដឹងអំពីគោលបំណងនៃការបង្កើតឱ្យមានក្រឡាបញ្ជី
- យល់ដឹងអំពីនីតិវិធីនៃការអនុវត្តច្បាប់នៅសាលាដំបូង
- យល់ដឹងអំពីលិខិតនានាពាក់ព័ន្ធនឹងសំណុំរឿងក្ដីរដ្ឋប្បវេណី ដែលចេញដោយក្រឡាបញ្ជី
- ផ្ដល់ជាចំណេះដឹងសម្រាប់បញ្ញវន្តជំនាន់ក្រោយ
- ផ្ដល់ជាចំណេះដឹងបន្ថែមសម្រាប់អ្នកសិក្សាផ្នែកច្បាប់
- ផ្ដល់ជាចំណេះដឹងសម្រាប់ប្រជាពលរដ្ឋ ដែលផ្ដល់ភាពងាយស្រួលក្នុងការស្វែងយល់ចំពោះនីតិវិធីនៃការអនុវត្តជាក់ស្ដែងនៅអង្គការតុលាការ។

## ៣. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឱ្យទំហំនៃការស្រាវជ្រាវប្រព្រឹត្តទៅដោយរលូន ទទួលបានលទ្ធផលល្អ និងអាចក្ដោបបានខ្លឹមសារទាំងមូលនៃប្រធានបទបានគ្រប់ជ្រុងជ្រោយ គឺយើងខ្ញុំបានផ្ដោតទៅលើចំណុចគោលសំខាន់ៗ ដែលបានលើកឡើងក្នុងប្រធានបទ ហើយចំណុចទាំងនោះរួមមាន៖ សញ្ញាណទូទៅនៃក្រឡាបញ្ជី តួនាទី និងភារកិច្ចក្រឡាបញ្ជីមុនពេលសវនាការ តួនាទី និងភារកិច្ចក្រឡាបញ្ជីក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងតួនាទី និងភារកិច្ចក្រឡាបញ្ជីក្នុងដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់។ ចំណុចទាំងអស់នេះ យើងខ្ញុំនឹងធ្វើការបកស្រាយឱ្យកាន់តែលម្អិតនៅក្នុងប្រធានបទ។

ចំពោះដែនកំណត់នៃការស្រាវជ្រាវ គឺយើងខ្ញុំបានអនុវត្តផ្ទាល់នៅសាលាដំបូងខេត្តកណ្ដាល និងទទួលបានការអនុញ្ញាតពីលោកចៅក្រម និងលោកក្រឡាបញ្ជី។ ហើយលោកទាំងពីរ ក៏បានផ្ដល់ដំបូន្មាន មតិយោបល់ការណែនាំ និងការផ្ដល់ជាគំនិតដែលឆ្លុះបញ្ចាំងអំពីប្រធានបទខាងលើ ព្រមទាំងបានផ្ដល់នូវឯកសារដែលទាក់ទងនឹងប្រធានផងដែរ។

## ៤. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ចំពោះសារៈសំខាន់នៃការស្រាវជ្រាវទៅលើប្រធានមួយនេះ បានរួមចំណែកជាប្រយោជន៍ដល់គ្រប់មជ្ឈដ្ឋាន អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ វិស័យការងារក្នុងប្រព័ន្ធតុលាការ វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈរួមមាន៖ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី និងជាចំណេះដឹងបន្ថែមសម្រាប់ប្រជាពលរដ្ឋ ឱ្យមានភាពយល់កាន់តែច្បាស់ អំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី និងនីតិវិធីមួយចំនួននៃការអនុវត្តច្បាប់របស់ប្រព័ន្ធយុត្តាធិការនៅកម្ពុជា។

## ៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

### ៥.១. តម្រូវការព័ត៌មាន

- **ទិន្នន័យទី១៖** ជាប្រភេទទិន្នន័យដោយផ្ទាល់ ដែលយើងខ្ញុំបានចុះអនុវត្តការងារជាក់ស្តែងដើម្បីយកជាបទពិសោធន៍ការងារ និងទទួលបានព័ត៌មានពីការសាកសួរមន្ត្រីអនុវត្តច្បាប់ក្នុងប្រព័ន្ធតុលាការ សិស្សច្បងដែលប្រការងារនៅអង្គការតុលាការ សាស្ត្រាចារ្យផ្នែកច្បាប់ និងលោកគ្រូណែនាំ។
- **ទិន្នន័យទី២៖** ជាប្រភេទទិន្នន័យ ដែលបានមកពីការស្រាវជ្រាវបន្ថែម និងដកស្រង់ខ្លឹមសារសំខាន់ៗ ដែលប្រមូលបានមកពីលិខិតបទដ្ឋានច្បាប់ផ្សេងៗរួមមាន៖ រដ្ឋធម្មនុញ្ញ ក្រមនីតិវិធីរដ្ឋប្បវេណី សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ សារណាបញ្ចប់ការសិក្សានៅតាមបណ្ណាល័យ និងគេហទំព័រជាដើម។

### ៥.២. ការប្រមូលព័ត៌មាន

ការប្រមូលព័ត៌មាន ត្រូវបានធ្វើឡើងដោយយកចិត្តទុកដាក់បំផុត និងបានសុំការអនុញ្ញាតពីមន្ត្រីដែលធ្វើការនៅអង្គការតុលាការពាក់ព័ន្ធនឹងឯកសារមួយចំនួន ដែលមាននៅក្នុងឧបសម្ព័ន្ធ។ លោកក៏បានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរ បានចូលរួមក្នុងការសង្កេតមើលការអនុវត្តផ្ទាល់អំពីដំណាក់កាលនីមួយៗនៃរឿងក្តីរដ្ឋប្បវេណី។

### ៥.៣. ដំណើរការនៃការជ្រើសរើសគំរូតាង

ការជ្រើសរើសគំរូតាង ត្រូវបានណែនាំដោយលោកគ្រូដឹកនាំ និងបានផ្តល់ជាគំនិត មតិយោបល់ ដែលធ្វើឱ្យសារណាមួយនេះមានខ្លឹមសារ ព្រមទាំងជួយពន្លឿនការធ្វើសារណាមួយនេះឱ្យមានភាពរហ័ស ក៏ដូចជាអត្ថន័យនៃប្រធានបទនេះមានភាពពេញលេញ និងមានរចនាបទល្អប្រសើរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនៃសារណានេះ គឺមានចំនួន ៤០ ទំព័រ ហើយត្រូវបានបែងចែកជា ៤ ជំពូកធំៗ ដូចខាងក្រោមនេះ៖

- **សេចក្តីផ្តើម៖** ក្នុងសារណានេះ ចង់បង្ហាញអំពីចំណោទបញ្ហានៃការដោះស្រាយ គោលបំណងនៃការស្រាវទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ (មានចំនួន ៥ ទំព័រ ចាប់ពីទំព័រទី១ ដល់ទំព័រទី៥)។
- **ជំពូកទី១៖ សញ្ញាណទូទៅនៃក្រឡាបញ្ជី** ក្នុងសារណានេះ ចង់បង្ហាញអំពីគោលបំណងនៃការបង្កើតឱ្យមានក្រឡាបញ្ជី និងព័ត៌មានទាក់ទងនឹងក្រឡាបញ្ជី។
- **ជំពូកទី២៖ តួនាទី និងភារកិច្ចក្រឡាបញ្ជីមុនពេលសវនាការ** ក្នុងសារណានេះ ចង់បង្ហាញអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីនៅមុនពេលសវនាការ និងចង់បង្ហាញអំពីឯកសារនានាដែលពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីនៅមុនពេលសវនាការ។
- **ជំពូកទី៣៖ តួនាទី និងភារកិច្ចក្រឡាបញ្ជីក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ក្នុងសារណានេះ ចង់បង្ហាញអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាដំណាក់កាលធ្វើការផ្សះផ្សា និងរកចំណុចវិវាទ។
- **ជំពូកទី៤៖ តួនាទី និងភារកិច្ចក្រឡាបញ្ជីក្នុងដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់** ក្នុងសារណានេះ ចង់បង្ហាញអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីក្នុងដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់ ដែលជាដំណាក់កាលនៃការជំនុំជម្រះលើកទី១។
- **សេចក្តីសន្និដ្ឋាន៖** ក្នុងសារណានេះ ចង់បង្ហាញអំពីខ្លឹមសារ និងក្តោបអត្ថន័យនៃប្រធានបទទាំងមូលដែលបានលើកបង្ហាញក្នុងសេចក្តីសន្និដ្ឋាន។
- **អនុសាសន៍៖** ក្នុងសារណានេះ ចង់បង្ហាញអំពីការណែនាំមួយចំនួន និងចង់បង្ហាញអំពីការកែប្រែមួយចំនួន ដែលចង់ឱ្យរាជរដ្ឋាភិបាលស្វែងយល់អំពីផលវិបាករបស់ក្រឡាបញ្ជី និងកែតម្រូវនូវមុខងាររបស់ក្រឡាបញ្ជីមួយចំនួនផងដែរ។

# ជំពូកទី១
# សញ្ញាណទូទៅនៃ
# ក្រឡាបញ្ជី

# ជំពូកទី១

# សញ្ញាណទូទៅនៃក្រឡាបញ្ជី

នៅក្នុងយុត្តាធិការតុលាការនៅកម្ពុជា ឬអាចនិយាយម្យ៉ាងទៀតបានថា ប្រព័ន្ធតុលាការនៅកម្ពុជា គឺជាសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជាដែលក្នុងនោះរួមមាន៖ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល[1]។ បណ្តឹងរដ្ឋប្បវេណី ត្រូវបានដឹកនាំដោយសកម្មភាពនៃអំណាចតុលាការរបស់រដ្ឋមួយ ដែលត្រូវបានប្រគល់ទៅឱ្យតុលាការ។ ជាពិសេស អំណាចតុលាការ គឺជាអំណាចឯករាជ្យ។ អំណាចតុលាការ ធានារក្សាអនាគត និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ[2]។ ជាការពិតណាស់ ឯករាជ្យភាពនៃអំណាចតុលាការ គឺជាគោលការណ៍សំខាន់ទីមួយនៃនីតិវិធីរដ្ឋប្បវេណី។ ហើយដើម្បីឱ្យការជម្រះក្តីអាចនឹងដំណើរការត្រឹមត្រូវតាមច្បាប់ និងឯករាជ្យភាពរបស់តុលាការ គឺមានភាពចាំចាច់ណាស់ដើម្បីឱ្យសាលាជម្រះក្តីប្រព្រឹត្តទៅស្របតាមគោលការណ៍ច្បាប់ជាមូលដ្ឋាន និងធ្វើឱ្យគូភាគីមានទំនុកចិត្ត។ ហើយបើយើងនិយាយឱ្យស៊ីជម្រៅជាងនេះ ចំពោះប្រព័ន្ធតុលាការនៅកម្ពុជា ក្នុងនោះគេសង្កេតឃើញថា រចនាសម្ព័ន្ធនៅក្នុងតុលាការ គឺមានការបែងចែកឋានៈទៅតាមឋានានុក្រម ក៏ដូចជាបែងចែកអំពីតួនាទី និងភារកិច្ចរបស់បុគ្គលមួយចំនួនដែលមាននៅក្នុងក្របខណ្ឌនៅអង្គការតុលាការ។ ហើយសមាសភាពសាលាដំបូងរួមមាន៖ ប្រធាន អនុប្រធាន ចៅក្រម ក្រឡាបញ្ជី មេធាវី មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាដំបូង[3]។

បើយើងនិយាយអំពីដំណើរការនៃនីតិវិធីរបស់តុលាការ យើងសង្កេតឃើញថា ក្រឡាបញ្ជី មានតួនាទី និងភារកិច្ចយ៉ាងសំខាន់ណាស់។ ទោះបីជាគ្មានច្បាប់ណាមួយ បានកំណត់អំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីឱ្យបានច្បាស់លាស់ និងជាក់លាក់ក៏ដោយ ក៏ក្រឡាបញ្ជីមានសិទ្ធិ និងកាតព្វកិច្ចក្នុងការអនុវត្តតួនាទី និងភារកិច្ចមួយចំនួនដដែល ដោយស្ថិតក្រោមការដឹកនាំ និងការត្រួតពិនិត្យរបស់ចៅក្រមទទួលបន្ទុករឿងក្តី។

មួយវិញទៀត មុនពេលដែលយើងខ្ញុំនិយាយឱ្យកាន់តែស៊ីជម្រៅអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីដែលបានដើរតួយ៉ាងសំខាន់នៅក្នុងនីតិវិធីរបស់តុលាការ យើងគប្បីសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ជាមុនសិនថា តើក្រឡាបញ្ជីជានរណា? តើក្រឡាបញ្ជីបង្កើតឡើងនៅពេលណា? តើគោលបំណងបង្កើតឱ្យមានក្រឡាបញ្ជីដើម្បីអ្វី? តើមុនពេល អំឡុងពេល និងក្រោយពេលសវនាការ ក្រឡាបញ្ជី មានសិទ្ធិ តួនាទី និងភារកិច្ចធ្វើអ្វីបានខ្លះ? ចំពោះតួនាទី និងភារកិច្ចមួយចំនួនដែលច្បាប់ពុំបានកំណត់ តើក្រឡាបញ្ជីអាចមានសិទ្ធិអនុវត្តបានដែរឬទេ?

[1] មាត្រា ៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

[2] មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[3] មាត្រា ១៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

## កថាខណ្ឌទី១៖ អត្ថន័យក្រឡាបញ្ជី និងប្រវត្តិនៃការបង្កើតក្រឡាបញ្ជី

### ក. អត្ថន័យក្រឡាបញ្ជី

បើតាមការសិក្សា និងការស្រាវជ្រាវអស់រយៈពេលកន្លងមកនេះ យើងខ្ញុំសង្កេតឃើញថា ពាក្យក្រឡាបញ្ជី នៅមិនទាន់ត្រូវបានគេឱ្យនិយមន័យ ក៏ដូចជាលើកយកមកធ្វើការសិក្សាឱ្យបានច្បាស់លាស់ និងជាក់លាក់នៅឡើយទេ។ ប៉ុន្តែ នៅក្នុងវចនានុក្រមសម្ដេចព្រះសង្ឃ **ជួន ណាត** និងលិខិតបទដ្ឋានគតិយុត្តច្បាប់មួយចំនួនតូចតែប៉ុណ្ណោះ ដែលបានឱ្យនិយមន័យនៃពាក្យ ក្រឡាបញ្ជី។

**ក្រឡាបញ្ជី** ថ្នាក់ពាក្យជានាម ដែលមានន័យថា ឋានន្តររបស់មន្ត្រីជាន់កណ្ដាលខាងតុលាការជាស្មៀនសម្រាប់កាន់កាប់បញ្ជី និងសំណុំរឿងផ្សេងៗជាដើម[4]។

**ក្រឡាបញ្ជី** ដែលមានន័យថា ជាអ្នកបច្ចេកទេសផ្នែកនីតិវិធី ដែលជួយដល់ចៅក្រមនៅក្នុងសកម្មភាពរបស់សាលាជម្រះក្ដីទៅតាមលក្ខខណ្ឌ ដែលបានកំណត់ក្នុងអត្ថបទច្បាប់ ឬបទបញ្ជាជាធរមាន[5]។

**ក្រឡាបញ្ជី** ដែលមានន័យថា គឺជាមន្ត្រីនៃក្រុមតុលាការ និងស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលកណ្ដាលនៃក្រសួងយុត្តិធម៌ ហើយអាចចាត់ឱ្យបំពេញការងារនៅក្រសួងយុត្តិធម៌បាន[6]។

**ក្រឡាបញ្ជី** ដែលមានន័យថា ជាជំនួយការរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះជាអ្នកទទួលខុសត្រូវ ជាពិសេស ក្នុងការរក្សាទុកនូវរាល់ឯកសារផ្លូវការនៃការជំនុំជម្រះ ដែលទទួលបាននូវឯកសារច្បាប់ដើមពីភាគីទាំងអស់ និងធានាដល់ការជូនដំណឹងរាល់សេចក្ដីសម្រេច[7]។

សរុបជារួម **ក្រឡាបញ្ជី** គឺជាជំនួយ ឬលេខាធិការរបស់ចៅក្រម ដែលជួយសម្រួលការងារនៅក្នុងស្ថាប័នរបស់អង្គការតុលាការ។ ជាពិសេស ជាអ្នកជួយសម្រួលដល់ផ្នែកបច្ចេកទេសនៃនីតិវិធី និងការងារបន្ទាប់បន្សំផ្សេងៗទៀត នៅក្នុងប្រព័ន្ធយុត្តិធម៌របស់តុលាការ។

### ខ. ប្រវត្តិនៃការបង្កើតក្រឡាបញ្ជី

តាមរយៈការសិក្សាស្រាវជ្រាវលើឯកសារអត្ថបទច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ក៏ដូចជាសៀវភៅប្រវត្តិសាស្ត្រមួយចំនួន បានយល់ឃើញថា នៅយុគសម័យបុរាណ ក្រឡាបញ្ជី គឺពុំទាន់មានឯកសារណាមួយបានបញ្ជាក់អំពីវត្តមានរបស់ក្រឡាបញ្ជីនៅឡើយទេ ក៏ពុំទាន់មានអត្ថបទច្បាប់ណាមួយបានលើកឡើងអំពីអត្តសញ្ញាណរបស់ក្រឡាបញ្ជីដែរ។ រហូតមកដល់សម័យអង្គរ ក្រឡាបញ្ជី ក៏មិនទាន់មាននៅក្នុងច្បាប់

[4] ពាក្យ ក្រឡាបញ្ជី ក្នុងវចនានុក្រមសម្ដេចព្រះសង្ឃ ជួន ណាត

[5] មាត្រា ២ នៃសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែករបស់ក្រឡាបញ្ជី ឆ្នាំ២០១២

[6] មាត្រា ៤ នៃសេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

[7] សៀវភៅវិធានផ្ទៃក្នុងវិសោធនកម្ម ឆ្នាំ២០០៨ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅឡើយទេ តែបានស្តែងចេញឡើងក្រោមរូបភាពជាមន្ត្រីតុលាការ ហៅថា ធម្មសាស្រ្តិន ជំនួយឱ្យចៅក្រមដែលមានតួនាទីប្រហាក់ប្រហែលនឹងក្រឡាបញ្ជីនាពេលបច្ចុប្បន្ន។ បុគ្គលដែលត្រូវបានគេហៅថា ធម្មសាស្រ្តិន គឺជាអ្នកសូត្រច្បាប់ធម្មសាស្ត្រ ហើយបុគ្គលនេះ ប្រហែលជាបំពេញមុខងារជាអ្នកតម្រាច្បាប់ ឬជាទីប្រឹក្សាច្បាប់ដែលចៅក្រមសួរឱ្យសូត្រមាត្រាច្បាប់ ដែលទាក់ទងនឹងអង្គហេតុនៃរឿងក្ដី[8]។

មកដល់សម័យទំនើបកម្មនាពេលបច្ចុប្បន្ន នៅលើវិស័យយុត្តិធម៌របស់ប្រទេសកម្ពុជា ដោយសារតែប្រទេសកម្ពុជា ស្ថិតក្រោមអាណានិគមបារាំងនៅសម័យនោះ បានធ្វើឱ្យមានការលេចឡើងនូវវត្តមាន ក៏ដូចជាអត្តសញ្ញាណរបស់ក្រឡាបញ្ជី ត្រូវបានកត់ត្រាឡើងនៅតាមបណ្ដាលិខិតបទដ្ឋានគតិយុត្តមួយចំនួនរួមមាន៖ ច្បាប់ស្តីពីលក្ខន្តិកៈយុត្តាធិការចៅក្រម និងក្រឡាបញ្ជីខាងផ្នែកតុលាការ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៥៦ មាត្រា ២៣ បញ្ញត្តិថា ក្រឡាបញ្ជីទទួលបន្ទុកការងារបច្ចេកទេសនៃសាលាជម្រះក្ដី និងអយ្យការ[9]។

## កថាខណ្ឌទី២៖ វិជ្ជាជីវៈក្រឡាបញ្ជី

បើយើងនិយាយអំពីវិជ្ជាជីវៈក្រឡាបញ្ជី យើងដឹងហើយថា បេក្ខជនដែលប្រឡងជាប់ចូលជាសិស្សក្រឡាបញ្ជី ត្រូវទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលរៀបចំដោយក្រសួងយុត្តិធម៌។ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈនេះមានរយៈពេលមិនតិចជាង ១២ ខែ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្ដុះបណ្ដាលវិជ្ជាជីវៈនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[10]។ វិជ្ជាជីវៈនេះ គឺជាវិជ្ជាជីវៈនៃយុត្តាធិការដែលស្ថិតក្នុងល័ក្ខខ័ណ្ឌដោយឡែក ដែលបម្រើការឱ្យសេវាយុត្តិធម៌ មិនមានលក្ខណៈសេរី ហើយត្រូវអនុវត្តតាមក្រមសីលធម៌នៃវិជ្ជាជីវៈនេះ និងធានាផ្តល់សេវាយុត្តិធម៌ដោយសមភាព តម្លាភាព និងឆាប់រហ័សជូនប្រជាពលរដ្ឋ។ ក្នុងស្ថានភាពដែលពុំទាន់មានច្បាប់ណាមួយបានអនុម័តអំពីលក្ខន្តិកៈក្រឡាបញ្ជី ត្រូវបានគ្រប់គ្រងដោយវិធានទូទៅពោល គឺច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤។ ស្ថាប័នដែលធ្វើការគ្រប់គ្រងរួមមាន៖

- ស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងវិជ្ជាជីវៈក្រឡាបញ្ជី ដោយផ្ទាល់ក្នុងការអនុវត្តនាពេលបច្ចុប្បន្ន ការតែងតាំង ការផ្លាស់ប្តូរ ការដកហូត បញ្ចប់មុខងារក្រឡាបញ្ជី ធ្វើឡើងតាមការប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។
- ស្ថាប័នមានសមត្ថកិច្ចដឹកនាំវិជ្ជាជីវៈក្រឡាបញ្ជី យើងសង្កេតឃើញថា មានអង្គការតុលាការ និងអង្គការអយ្យការ ដែលមានចៅក្រម និងព្រះរាជអាជ្ញាដឹកនាំក្រឡាបញ្ជីដោយផ្ទាល់នូវសកម្មភាពការងារបច្ចេកទេសនៅគ្រប់ដំណាក់កាលនីតិវិធីនៃរឿងក្តី។

[8] សៀវភៅអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀបរបស់លោក កុយ នាម និងលោក ឡុង បញ្ញាវុធ ឆ្នាំ២០០៦
[9] បទបង្ហាញស្តីពីវិជ្ជាជីវៈក្រឡាបញ្ជី និងវិធីសាស្ត្រនៃការត្រៀមប្រឡងវិជ្ជាជីវៈតុលាការរបស់លោក មួន សេងលី ឆ្នាំ២០១៦
[10] មាត្រា ២៨ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

## ក. គោលបំណងនៃការបង្កើតឱ្យមានក្រឡាបញ្ជី

តាមរយៈការសិក្សាស្រាវជ្រាវកន្លងមក យើងសង្កេតឃើញថា ការបង្កើតឱ្យមានក្រឡាបញ្ជីឡើងមក មានគោលបំណងបង្កើតឱ្យមានអង្គការក្រឡាបញ្ជីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាជំនួយឱ្យអង្គការតុលាការ និងអង្គការអយ្យការ សំដៅដល់ប្រសិទ្ធិភាព និងគុណភាពនៃសេវាយុត្តិធម៌[11]។ ជាពិសេស ការបង្កើតឱ្យមានក្រឡាបញ្ជី បានជួយសម្រួល និងពន្លឿនដល់ការអនុវត្តនៃនីតិវិធីរបស់តុលាការឱ្យបានឆាប់រហ័ស ពីព្រោះយើងដឹងហើយថា បច្ចុប្បន្ននេះ នៅសាលាដំបូងរាជធានី-ខេត្ត គឺតែងតែមានបញ្ហាជួបប្រទះនឹងការកកស្ទះនៃសំណុំរឿងក្តី ដោយសារតែក្រឡាបញ្ជីមានតិចហើយនៅមានកម្រិត។

## ខ. លក្ខខណ្ឌនៃការជ្រើសរើសក្រឡាបញ្ជីនាពេលបច្ចុប្បន្ន

យើងដឹងហើយថា ក្នុងការប្រកបមុខរបរទាំងវិស័យរដ្ឋ និងវិស័យឯកជន គឺត្រូវតែឆ្លងកាត់ការធ្វើតេស្តសមត្ថភាព ចំណេះដឹង ជំនាញ ការប្រឡង ការប្រកួតប្រជែង និងត្រូវការបទពិសោធន៍ ដែលបានឆ្លងកាត់តាមរយៈការបណ្តុះបណ្តាល ជាពិសេស គឺត្រូវសមស្របទៅតាមល័ក្ខខ័ណ្ឌនៃការជ្រើសរើស។

សម្រាប់នាពេលបច្ចុប្បន្ននេះ គឺត្រូវធ្វើឡើងដោយការប្រឡងចូលក្របខណ្ឌនៃមន្ត្រីរាជការស៊ីវិល ដែលមានការប្រឡងប្រជែងចំពោះនិស្សិត ឬមន្ត្រីរាជការ ហើយមានការបញ្ជាក់ និងទទួលស្គាល់ដោយក្រសួង ហើយមានល័ក្ខខ័ណ្ឌនៃការជ្រើសរើសត្រឹមត្រូវច្បាស់លាស់។

ចំពោះល័ក្ខខ័ណ្ឌសម្រាប់បេក្ខជនដាក់ពាក្យស្នើសុំចូលរួមប្រឡងជ្រើសរើសសិស្សក្រឡាបញ្ជីនាពេលបច្ចុប្បន្នរួមមានចំណុចដូចខាងក្រោមៈ

១. ត្រូវមានសញ្ជាតិខ្មែរពីកំណើត

២. ត្រូវមានអាយុ ៣០ (សាមសិប) ឆ្នាំ យ៉ាងច្រើនចំពោះបេក្ខជននិស្សិត និងមានអាយុ ៣៥ (សាបសិបប្រាំ) ឆ្នាំ យ៉ាងច្រើនចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង។

៣. ត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (Bac II)

៤. ត្រូវមានសញ្ញាបត្របញ្ជាក់ការសិក្សាឆ្នាំទី២ ឡើងទៅ ផ្នែកនីតិសាស្ត្រ ឬបរិញ្ញាបត្ររងនៅមហាវិទ្យាល័យដែលមានកម្មវិធីសិក្សាសមមូល (ដោយភ្ជាប់មកជាមួយនូវព្រឹត្តិបត្រពិន្ទុពាក់ព័ន្ធ) ឬបរិញ្ញាបត្រនីតិសាស្ត្រ

៥. មិនដែលមានទោសពីបទមជ្ឈិម និងបទឧក្រិដ្ឋ

៦. ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន[12]។

---

[11] មាត្រា ១ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

[12] សេចក្តីជូនដំណឹងរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការលេខ ២៥៩/របវត ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣

## គ. ការបែងចែកក្រឡាបញ្ជី និងឯកសណ្ឋាន

### គ.១. ការបែងចែកក្រឡាបញ្ជី

អង្គក្រឡាបញ្ជីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជា២ប្រភេទ គឺក្រឡាបញ្ជីអង្គការតុលាការ និងក្រឡាបញ្ជីអង្គការអយ្យការ[13]។

- **ក្រឡាបញ្ជីអង្គការតុលាការ**

នៅតាមសាលាជម្រះក្តីនីមួយៗ មានក្រឡាបញ្ជីអង្គការតុលាការ ជាជំនួយនៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ។ ក្រឡាបញ្ជី នៃសាលាជម្រះក្តីមួយ ដឹកនាំដោយនាយកក្រឡាបញ្ជី ១ (មួយ) រូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ នាយកក្រឡាបញ្ជី និងក្រឡាបញ្ជីជម្រះក្តីមួយ ត្រូវស្ថិតនៅក្នុងអង្គភាពតែមួយ ហៅថា អង្គភាពក្រឡាបញ្ជីសាលាជម្រះក្តីនោះ[14]។

- **ក្រឡាបញ្ជីអង្គការអយ្យការ**

នៅតាមអង្គការអយ្យការអមសាលាជម្រះក្តីនីមួយៗ មានក្រឡាបញ្ជីអង្គការអយ្យការ ជាជំនួយនៅគ្រប់ដំណាក់កាលនៃនីតិវិធីអយ្យការ។ ក្រឡាបញ្ជី នៃអង្គការអយ្យការអមសាលាជម្រះក្តីមួយ ដឹកនាំដោយនាយកក្រឡាបញ្ជី ១ (មួយ) រូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ នាយកក្រឡាបញ្ជី និងក្រឡាបញ្ជីអង្គការអយ្យការអមសាលាជម្រះក្តីមួយ ត្រូវស្ថិតនៅអង្គភាពតែមួយ ហៅថា អង្គភាពក្រឡាបញ្ជីអង្គការអយ្យការអមសាលាជម្រះក្តីនោះ[15]។

### គ.២. ឯកសណ្ឋានក្រឡាបញ្ជី

ការបែងចែកឯកសណ្ឋានរបស់ក្រឡាបញ្ជីរួមមាន៖ ឯកសណ្ឋានពេលជំនុំជម្រះ ឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតក្រៅពីជំនុំជម្រះ ឯកសណ្ឋានផ្លូវការក្នុងពិធីបុណ្យជាតិផ្សេងៗ។ ឯកសណ្ឋានទាំងនេះត្រូវកំណត់លម្អិតដោយព្រះរាជក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[16]។

- ឯកសណ្ឋានដែលក្រឡាបញ្ជីទាំងអស់ត្រូវពាក់ពេលជំនុំជម្រះ គឺអាវផាយ។
- ឯកសណ្ឋានក្នុងពេលបំពេញមុខងារផ្សេងទៀតក្រៅពីជំនុំជម្រះ គឺជាសម្លៀកបំពាក់ ឬគ្រឿងសម្គាល់ផ្សេងៗ។

---

[13] មាត្រា ៦ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

[14] មាត្រា ៧ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

[15] មាត្រា ៨ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

[16] មាត្រា ១៧ នៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

ឯកសណ្ឋាន ដែលក្រឡាបញ្ជីទាំងអស់ពាក់ក្នុងពេលហែក្បួន ឬក្នុងពិធីបុណ្យជាតិផ្សេងៗ បើមានតម្រូវការ គឺជាសម្លៀកបំពាក់ផ្លូវការ[17]។

## ឃ. ការផ្អាកវិជ្ជាជីវៈក្រឡាបញ្ជី និងវិសមិតភាពរបស់ក្រឡាបញ្ជី

### ឃ.១. ការផ្អាកវិជ្ជាជីវៈក្រឡាបញ្ជី

ក្រឡាបញ្ជីដែលទទួលបានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្អាកដោយស្វ័យប្រវត្តិ មិនឱ្យបំពេញមុខងារជាបណ្ដោះអាសន្ន រហូតដល់មានសេចក្ដីសម្រេចរបស់តុលាការអំពីទោសជាស្ថាពរ។ ក្រឡាបញ្ជីនេះ ត្រូវទទួលបានប្រាក់បៀវត្សជាធម្មតា រហូតដល់មានសាលក្រមសម្រេចរបស់តុលាការថា មានទោស។ ប្រាក់បៀវត្សនេះ ត្រូវផ្អាកជាបណ្ដោះអាសន្នតាមសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីថ្ងៃដែលមានសាលក្រមរបស់តុលាការសម្រេចថា មានទោស ទោះបីមានបណ្ដឹងឧទ្ធរណ៍ពីសាលក្រមនេះក៏ដោយ[18]។

### ឃ.២. វិសមិតភាពក្រឡាបញ្ជី

ក្នុងការបំពេញមុខងារជាក្រឡាបញ្ជី មានវិសមិតភាពជាមួយការបំពេញមុខងារផ្សេងទៀត នៅក្នុងវិស័យតុលាការរួមមាន៖ មុខងារសាធារណៈ មុខងារជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភាព សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬមុខងារជាទីប្រឹក្សាគ្រប់ឋានានុក្រម លើកលែងតែមានបញ្ញត្តិផ្ទុយពីនេះ។ ក្រឡាបញ្ជី ដែលកំពុងបំពេញមុខងារ មិនអាចបំពេញមុខងារជាមេធាវី សារការីអាជ្ញាសាលា ឬធ្វើសកម្មភាពណាមួយផ្សេងទៀត ដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ ឬដែលប៉ះពាល់ដល់កិត្តិយសនៃអង្គក្រឡាបញ្ជី។ ប៉ុន្តែ ក្រឡាបញ្ជី អាចបំពេញមុខងារជាគ្រូឧទ្ទេសនាមបាន[19]។

[17] មាត្រា ១៨ នៃសេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

[18] មាត្រា ៦០ នៃសេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

[19] មាត្រា ៧០ នៃសេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦

# ជំពូកទី២
# តួនាទី និងភារកិច្ចក្រឡាបញ្ជី
# មុនពេលសវនាការ

# ជំពូកទី២
# តួនាទី និងភារកិច្ចក្រឡាបញ្ជីមុនពេលសវនាការ

បើទោះបីជាក្រមនីតិវិធីរដ្ឋប្បវេណី ហាក់ពុំបានកំណត់អំពីតួនាទី និងភារកិច្ចជាក់លាក់យ៉ាងណាក៏ដោយក៏ក្រឡាបញ្ជី នៅតែមានតួនាទី និងភារកិច្ចជាច្រើននៅមុនពេលសវនាការ ពីព្រោះនៅមុនពេលសវនាការក្រឡាបញ្ជី ដើរតួយ៉ាងសំខាន់ដើម្បីឱ្យនីតិវិធីនៃរឿងក្ដីបានដំណើរការទៅតាមនីតិវិធី និងដំណាក់កាលដែលច្បាប់កំណត់ មុននឹងឈានចូលដល់ការទាញហេតុផលដោយផ្ទាល់មាត់ ដែលហៅថា (សវនាការ)។

សាលាដំបូង គឺជាសាលាជម្រះក្ដីទូទៅ ដែលមានសមត្ថកិច្ចជំនុំជម្រះក្ដីទៅលើរឿងក្ដីទាំងអស់ លើកលែងតែរឿងក្ដីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្ដីពិសេស ឬសាលាជម្រះក្ដីវិសាមញ្ញ ដែលបង្កើតឡើងដោយច្បាប់ដោយឡែក[20]។ នៅសាលាដំបូង រឿងក្ដីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមទៅតាមវិវាទដែលសាលាដំបូងនោះទទួលបានពីភាគី ដូចដែលបានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដែលជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី[21]។ ចំពោះការអនុវត្តជាក់ស្ដែងនៅតាមស្ថាប័នតុលាការនីមួយៗ ក្រឡាបញ្ជី មានតួនាទី និងភារកិច្ចយ៉ាងច្រើននៅពេលមានសវនាការម្ដងៗ ក៏ដូចជាចេញនូវឯកសារគតិយុត្តមួយចំនួនផងដែរ។

នីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណីនៅតុលាការ ត្រូវចាប់ផ្ដើមនៅពេលដាក់ពាក្យបណ្ដឹង[22]។ បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ដើម្បីការពារសិទ្ធិរបស់បុគ្គល។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ការប្ដឹងត្រូវធ្វើដោយដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅតុលាការ[23]។

ជាទូទៅ រាល់ពាក្យបណ្ដឹងត្រូវសរសេរជាលាយលក្ខណ៍អក្សរជាដាច់ខាត ហើយត្រូវយកទៅដាក់នៅតុលាការដែលមានសមត្ថកិច្ចទទួលពាក្យបណ្ដឹង។ បណ្ដឹង អាចធ្វើឡើងបានក្នុងករណីដែលបណ្ដឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្ដែង និងដែលវិវាទនោះអាចដោះស្រាយដោយសាលក្រម[24]។ នៅក្នុងពាក្យបណ្ដឹង ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីគូភាគីនៃបណ្ដឹង អ្នកតំណាងដែលច្បាប់បានកំណត់ ព្រមទាំងអាសយដ្ឋានឱ្យបានត្រឹមត្រូវ។

---

[20] មាត្រា ១២ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

[21] មាត្រា ២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[22] សៀវភៅមេរៀនកិច្ចការក្រឡាបញ្ជីរបស់លោកមេធាវី មួង សេងលី

[23] មាត្រា ៧៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[24] មាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

## កថាខណ្ឌទី១៖ កិច្ចការក្រឡាបញ្ជីពេលមានបណ្តឹង

នៅពេលមានបណ្តឹងចូលមក ក្រឡាបញ្ជី គប្បីពិនិត្យលើពាក្យបណ្តឹងរបស់ដើមចោទថា តើការទាមទាររបស់ដើមចោទត្រឹមត្រូវតាមច្បាប់ឬទេ? តើការដាក់ពាក្យបណ្តឹងនោះ មានឯកសារគ្រប់គ្រាន់ដែរឬទេ? ហើយការទទួលពាក្យបណ្តឹងរបស់ក្រឡាបញ្ជីមានដូចខាងក្រោមនេះ៖

### ក. កិច្ចការក្រឡាបញ្ជីក្នុងការទទួលពាក្យបណ្តឹងដោយផ្ទាល់មាត់

ចំពោះរឿងក្តីដែលមានចំនួនទឹកប្រាក់តិច ដែលមានគោលបំណងធ្វើការដោះស្រាយវិវាទឱ្យបានឆាប់រហ័សតាមនីតិវិធីងាយស្រួល តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បានភ្លាមបន្ទាប់ពីការដាក់ពាក្យបណ្តឹង ដោយមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ។ នីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច មានគោលបំណងដើម្បីដោះស្រាយវិវាទឱ្យបានឆាប់រហ័សតាមនីតិវិធីសង្ខេប[25]។

### ខ. កិច្ចការក្រឡាបញ្ជីក្នុងការទទួលពាក្យបណ្តឹងពីរដ្ឋបាលតុលាការ

សំណុំរឿង ដែលកើតឡើងតាមរយៈការដាក់ពាក្យបណ្តឹងរបស់ដើមចោទ ត្រូវបញ្ជូនទៅស្ថាប័នយុត្តាធិការជំនុំជម្រះតាមរយៈលេខាធិការដ្ឋាននៃតុលាការ។ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវចាត់ចែងរៀបចំបណ្តឹងនោះដោយបន្ថែមក្រប ចុះលេខរៀងនៃសំណុំរឿងក្តី និងចុះថ្ងៃ ខែ ឆ្នាំ ឱ្យបានត្រឹមត្រូវ។ បន្ទាប់មកលេខាធិការដ្ឋាន មានតួនាទីបញ្ជូនសំណុំរឿងរឿងក្តីនោះទៅក្រឡាបញ្ជី ដើម្បីប្រគល់ជូនលោកចៅក្រមទទួលបន្ទុកនៃរឿងក្តី ចាត់ឱ្យក្រឡាបញ្ជីរៀបចំនីតិវិធីបន្ត។

### គ. ការថែរក្សាសំណុំរឿងរបស់ក្រឡាបញ្ជី

នៅពេលចៅក្រមទទួលបន្ទុករឿងក្តី បានចាត់ចែងប្រគល់សំណុំរឿងក្តីឱ្យទៅក្រឡាបញ្ជីរួចហើយ ក្រឡាបញ្ជី ត្រូវដំណើរការនីតិវិធីបន្ត ប៉ុន្តែក្រឡាបញ្ជី ត្រូវរក្សាទុកនូវសំណុំរឿងក្តីនោះឱ្យមានសុវត្ថិភាព ជៀសវាងមានការបាត់បង់នូវឯកសារណាមួយរបស់ដើមចោទ ឬការធ្វេសប្រហែសណាមួយដែលអាចធ្វើឱ្យបាត់បង់សំណុំរឿងក្តីជាដើម។

### ឃ. ការត្រួតពិនិត្យពាក្យបណ្តឹង និងការបញ្ជូនពាក្យបណ្តឹង

#### ឃ.១. ការត្រួតពិនិត្យពាក្យបណ្តឹង

នៅពេលបណ្តឹង ត្រូវបានដាក់នៅតុលាការរួចហើយ បណ្តឹងនោះត្រូវបញ្ជូនដល់ដៃតុលាការ តុលាការត្រូវធ្វើការពិនិត្យលើពាក្យបណ្តឹងដោយផ្អែកលើមាត្រា ៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីថា តើមានភាពត្រឹមត្រូវ និងពេញលេញដូចដែលច្បាប់បានកំណត់ឬនៅ? ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងរួមមាន៖

[25] មាត្រា ២២៥ កថាខណ្ឌទី១ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

**ក.** ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

**ខ.** ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញនិងអង្គហេតុចាំបាច់នៃការទាមទារ។

នៅក្នុងពាក្យបណ្តឹង ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខណ្ឌទី២ ខាងលើនេះ ដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុ ដែលជាមូលហេតុនៃការទាមទារ និងតាមចំណុចដែលត្រូវបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង[26]។

### ឃ.២. ការបញ្ជូនពាក្យបណ្តឹង

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់កំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹង ចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។ ការទទួលនូវការបញ្ជូន គឺជាការដាក់ខ្លួនក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ ហេតុនេះហើយ ការធ្វើការបញ្ជូនចំពោះជនដែលមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការកម្ពុជា។

ក្រោយការពិនិត្យពាក្យបណ្តឹង ប្រសិនបើតុលាការទទួលស្គាល់ថា ពាក្យបណ្តឹងនោះត្រឹមត្រូវតាមទម្រង់ហើយ ត្រូវទទួលពាក្យបណ្តឹងនោះ។ បន្ទាប់មក ក្រឡាបញ្ជី ត្រូវធ្វើរបាយការណ៍បញ្ជូនពាក្យបណ្តឹងនោះឱ្យទៅចុងចម្លើយ។ ដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង ត្រូវទាមទារឱ្យដើមចោទត្រៀមនូវឯកសារចម្លងនៃពាក្យបណ្តឹងទៅតាមចំនួនដែលត្រូវការតាមចំនួននៃចុងចម្លើយ ហើយត្រូវបញ្ជូនឯកសារចម្លងនៃពាក្យបណ្តឹងនោះ ឱ្យទៅកាន់ចុងចម្លើយ។ ការជូនដំណឹងអំពីបណ្តឹង ត្រូវធ្វើឡើងដោយដាក់លិខិតជាលាយល័ក្ខណ៍អក្សរ ដែលបញ្ជាក់អំពីមូលហេតុក្នុងការជូនដំណឹង និងអំពីដំណើរការនៃបណ្តឹងនោះទៅតុលាការ។ តុលាការ ត្រូវបញ្ជូនលិខិតនេះទៅអ្នកដែលត្រូវទទួលដំណឹង និងភាគីម្ខាងទៀតនៃបណ្តឹង[27]។

ការបញ្ជូនពាក្យបណ្តឹង គឺជាការផ្តល់ឱកាសឱ្យភាគីម្ខាងទៀតបានដឹងអំពីបណ្តឹងថា តើបុគ្គលណាជាអ្នកប្តឹង កម្មវត្ថុនៃបណ្តឹងជាអ្វី និងត្រៀមមធ្យោបាយសម្រាប់ការពារខ្លួនផងដែរ។ តាមរយៈការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ ចុងចម្លើយក៏ក្លាយទៅជាប្រធាននៃនីតិវិធីបណ្តឹងនោះ ហើយទំនាក់ទំនងគតិយុត្តរវាងភាគីទាំងបី គឺតុលាការ ចុងចម្លើយ និងដើមចោទនឹងកើតមាននៅពេលនោះ។

ពាក្យបណ្តឹង ត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់។ តាមបញ្ញត្តិនៃមាត្រា ៧៨ (ការពិនិត្យពាក្យបណ្តឹង) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពាក្យបណ្តឹងមិនអាចបញ្ជូនទៅបាន។ បញ្ញត្តិ

[26] មាត្រា ៧៥ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[27] មាត្រា ៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

នោះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលដើមចោទមិនបានបង់ប្រាក់សម្រាប់បញ្ជូនពាក្យបណ្តឹងទុកជាមុន[28]។

## កថាខណ្ឌទី២៖ ការរៀបចំឯកសារក្នុងចំណាត់ការរឿងក្តី

ក្នុងការរៀបចំឯកសារក្នុងចំណាត់ការនៃរឿងក្តី គឺដើម្បីធ្វើយ៉ាងណាឱ្យនីតិវិធីនៃរឿងក្តីបានដំណើរការស្រប ទៅតាមច្បាប់កំណត់ និងធ្វើយ៉ាងណាឱ្យរឿងក្តីដំណើរការបានត្រឹមត្រូវ និងមានប្រសិទ្ធិភាព។

### ក. ដីកាសម្រេចបង្គាប់ឱ្យបង់ពន្ធដាក់ពាក្យសុំ និងដីកាសម្រេចលើកចោលពាក្យបណ្តឹង

#### ក.១. ដីកាសម្រេចបង្គាប់ឱ្យបង់ពន្ធដាក់ពាក្យសុំ

នៅពេលពាក្យបណ្តឹងត្រូវបានដាក់ ភាគីត្រូវបង់ពន្ធនៃការដាក់ពាក្យបណ្តឹងនោះ ដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹង។ តុលាការអាចមានលទ្ធភាព ប្រមូលប្រាក់ពន្ធនៃការដាក់ពាក្យបណ្តឹងបន្ថែមទៀតក៏បាន ដូចបានចែងនៅមាត្រា ៦១ (ពន្ធដាក់ពាក្យសុំ) តម្លៃនៃការបង់ពន្ធដាក់ពាក្យបណ្តឹង គឺជាការវាយតម្លៃដ៏សមរម្យមួយដែលគណនាទៅតាមកម្មវត្ថុនៃពាក្យបណ្តឹង[29]។

#### ក.២. ដីកាសម្រេចលើកចោលពាក្យបណ្តឹង

ការបង់ពន្ធ ត្រូវធ្វើដោយការបង់ជាប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការ។ ពាក្យសុំដែលមិនបានបង់ពន្ធពេលដាក់ពាក្យទេ ត្រូវទុកថាជាពាក្យសុំមិនស្របច្បាប់[30]។ ពាក្យសុំត្រូវបានលើកចោល ដោយសារអ្នកដាក់ពាក្យបណ្តឹងផ្ទុយនឹងច្បាប់កំណត់ និងពុំទាន់មានភាពគ្រប់គ្រាន់ក្នុងការដាក់បណ្តឹង និងមិនគោរពតាមនីតិវិធីនៃច្បាប់ ឬការលើកឡើងនៃបណ្តឹងមានការទាមទារពុំមានមូលហេតុត្រឹមត្រូវជាដើម។

### ខ. ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាត និងដីកាសម្រេចលើកចោលពាក្យបណ្តឹង

#### ខ.១. ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាត

ក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបាន តុលាការអាចលើកចោលបណ្តឹងនោះចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន[31]។

#### ខ.២. ដីកាសម្រេចលើកចោលពាក្យបណ្តឹង

ក្នុងករណីដែលពាក្យបណ្តឹងផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា ៧៥ (របៀបដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង) ខាងលើនេះ តុលាការត្រូវកំណត់ពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវ

[28] មាត្រា ៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[29] សៀវភៅមេរៀនកិច្ចការក្រឡាបញ្ជីរបស់លោកមេធាវី មួង សេងលី

[30] មាត្រា ៦១ កថាខណ្ឌទី៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[31] មាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ចំណុចខ្វះចំពោះពាក្យបណ្ដឹងនោះក្នុងអំឡុងពេលនោះ។ ក្នុងករណីដែលបានកំណត់ខាងលើនេះ ប្រសិនបើដើមចោទមិនកែតម្រូវចំណុចខ្វះទេ តុលាការត្រូវលើកពាក្យបណ្ដឹងចោលដោយដីកាសម្រេច[32]។

នៅពេលដែលដើមចោទបានធ្វើការកែតម្រូវតាមការបង្គាប់ឱ្យកែតម្រូវ តុលាការត្រូវបញ្ជូនពាក្យបណ្ដឹងនោះទៅឱ្យចុងចម្លើយ ហើយចាប់ផ្ដើមបន្តនីតិវិធីជំនុំជម្រះ។

## គ. ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ និងដីកាសម្រេចលើកចោលពាក្យបណ្ដឹង

### គ.១. ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធ

ក្រៅពីនេះ ប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធផ្សេងពីការចាំបាច់ខាងលើ តុលាការអាចបង្គាប់ឱ្យបង់តាមករណីជាក់ស្ដែងដែលត្រូវចំណាយ និងតាមដំណាក់កាលនៃនីតិវិធីនៃរឿងក្ដី។ ភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវបង់ប្រាក់ប្រដាប់ក្ដីខាងក្រោមនេះ ទៅតាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ៖

**ក**. ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀតតាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណី។

**ខ**. ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តទៅនៅក្រៅតុលាការ។

ភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដី ដែលត្រូវបង់ប្រាក់ប្រដាប់ក្ដីដូចបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើនេះ ចំពោះប្រាក់ប្រដាប់ក្ដីសម្រាប់សកម្មភាព ដែលធ្វើឡើងដោយពាក្យសុំ គឺអ្នកដាក់ពាក្យសុំ រីឯចំពោះប្រាក់ប្រដាប់ក្ដីសម្រាប់សកម្មភាព ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ គឺអ្នកដែលតុលាការបានកំណត់ឱ្យបង់[33]។

### គ.២. ដីកាសម្រេចលើកចោលពាក្យបណ្ដឹង

ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យដើមចោទបង់ជាមុននូវប្រាក់ ដែលជាចាំបាច់ក្នុងការកោះហៅភាគីឱ្យចូលមកនៅកាលបរិច្ឆេទតាមបញ្ញត្តិនៃក្រមនេះ ដោយកំណត់ពេលសមរម្យ តែដើមចោទមិនបង់ប្រាក់នោះជាមុនទេ តុលាការអាចលើកចោលបណ្ដឹងដោយដីកាសម្រេចបាន លុះត្រាតែចុងចម្លើយគ្មានការតវ៉ា។ ចំពោះដីកាសម្រេចដែលបានកំណត់ខាងលើនេះ អាចប្ដឹងជំទាស់បាន[34]។

---

[32] មាត្រា ៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[33] មាត្រា ៦២ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[34] មាត្រា ៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

## ឃ. ដីកាកោះហៅ និងលិខិតអញ្ជើញ

### ឃ.១. ដីកាកោះហៅ

នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និងកោះហៅគូភាគី។ កាលបរិច្ឆេទដែលបានកំណត់ខាងលើនេះ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស[35]។ ការកំណត់បែបនេះ គឺចេញមកអំពីការគិតគូរដែលថា ចុងចម្លើយនឹងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន និងថាការចាប់ផ្តើមនីតិវិធីនឹងមិនមានការយឺតយ៉ាវ។

- **ដីកាកោះហៅដើមចោទ** គឺជាឯកសារច្បាប់មួយដែលចេញដោយតុលាការ ដើម្បីកោះហៅដើមចោទមកបង្ហាញខ្លួននៅតុលាការ ដើម្បីឱ្យចូលខ្លួនមកឆ្លើយនឹងសំណើរនៃបណ្តឹង។ អ្នកដែលទទួលដីកាត្រូវចូលរួមតាមថ្ងៃ និងម៉ោងដែលបានកំណត់។
- **ដីកាកោះហៅចុងចម្លើយ** គឺជាឯកសារច្បាប់មួយដែលចេញដោយតុលាការ ដើម្បីកោះហៅចុងចម្លើយមកបង្ហាញខ្លួននៅតុលាការ ដើម្បីចូលខ្លួនឆ្លើយនឹងការចោទប្រកាន់របស់ដើមចោទសម្រាប់ដំណើរការទៅកាន់កិច្ចសម្រេចចុងក្រោយ។
- **ដីកាកោះហៅសាក្សី** គឺជាឯកសារច្បាប់មួយដែលចេញដោយតុលាការ ដើម្បីកោះហៅសាក្សីឱ្យចូលរួមសវនាការក្នុងការផ្តល់ចម្លើយជុំវិញអង្គហេតុនៃរឿងក្តី។
- **ដីកាកោះហៅជនជាប់ពាក់ព័ន្ធ** គឺជាឯកសារច្បាប់មួយដែលចេញដោយតុលាការ ដើម្បីកោះហៅជនដែលជាប់ពាក់ព័ន្ធនឹងរឿងក្តីឱ្យចូលរួមសវនាការ ដើម្បីឱ្យផ្តល់ចម្លើយជុំវិញអង្គហេតុនៃរឿងក្តី។

### ឃ.២. លិខិតអញ្ជើញ

លិខិតអញ្ជើញ គឺជាឯកសារមួយដែលធ្វើជាការអញ្ជើញឱ្យបុគ្គលដែលមានកិត្តិយស ចូលរួមក្នុងកិច្ចនីតិវិធីណាមួយ ឬសកម្មភាពដំណើរការនីតិវិធីនៃរឿងក្តីរបស់តុលាការជាដើម។ លិខិតអញ្ជើញ អាចនឹងត្រូវអញ្ជើញអ្នកពាក់ព័ន្ធរួមមាន៖ មេធាវីជាដើម។

- **លិខិតអញ្ជើញមេធាវី** (**ករណីដើមចោទ និងចុងចម្លើយមានមេធាវី**) គឺជាឯកសារផ្លូវការដែលចេញដោយតុលាការធ្វើការអញ្ជើញមេធាវីឱ្យមកចូលរួមឆ្លើយការពារផលប្រយោជន៍របស់កូនក្តី និងបំភ្លឺនៃអង្គហេតុ។

**សម្គាល់៖** លិខិតអញ្ជើញមេធាវី គឺជាការអញ្ជើញមេធាវីឱ្យចូលរួមក្នុងនីតិវិធីនៃរឿងក្តីដោយគ្មានការបង្ខិតបង្ខំឡើយ ពីព្រោះជាសិទ្ធិរបស់មេធាវីក្នុងការចូលរួមដើម្បីការពារផលប្រយោជន៍ឱ្យកូនក្តីរបស់ខ្លួន។

---

[35] មាត្រា ៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

តាមរយៈការអនុវត្តជាក់ស្តែង ក្រោយពីបានពិនិត្យ ហើយបានទទួលពាក្យបណ្តឹង តុលាការត្រូវកំណត់នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ហើយត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងនោះព្រមជាមួយនឹងដីកាកោះហៅចុងចម្លើយឱ្យមកតុលាការតាមកាលបរិច្ឆេទកំណត់។ ចំពោះដើមចោទវិញ ត្រូវបញ្ជូនដីកាកោះហៅតាមកាលបរិច្ឆេទតែមួយនឹងចុងចម្លើយ។ ម៉្យាងទៀត ប្រសិនបើដើមចោទពុំបានបង់សោហ៊ុយចាំបាច់សម្រាប់ការកោះហៅតាមកាលបរិច្ឆេទទេ ហើយមិនព្រមបង់តាមការបង្គាប់ឱ្យបង់ជាមុននូវប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ តុលាការអាចលើកចោលបណ្តឹងនោះដោយដីកាសម្រេច។

**ឃ.៣. របាយការណ៍បញ្ជូន**

មន្ត្រីទទួលបន្ទុកការបញ្ជូនដែលបានធ្វើការបញ្ជូនរួចហើយ ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូននោះជូនទៅតុលាការ។ របាយការណ៍ដែលបានកំណត់ខាងលើនេះ ត្រូវបញ្ជាក់អំពីចំណុចដូចតទៅៈ

**ក**. សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន។

**ខ**. ជនដែលត្រូវទទួលការបញ្ជូន។

**គ**. ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន។

**ឃ**. វិធីបញ្ជូន។

**ង**. ចំណាត់ការតាមកថាខណ្ឌទី៣ នៃមាត្រា ២៤៧ (គោលការណ៍នៃការបញ្ជូនដោយការប្រគល់) នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងករណីជនដែលត្រូវទទួលការបញ្ជូននោះមិនចេះអក្សរ។

**ច**. ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដែលបានទទួលឯកសារ។

**ឆ**. ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូននៅក្នុងករណីជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារតាមបញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល) នៃក្រមនេះ ប្រកែកមិនព្រមទទួល។

**ជ**. ហេតុការណ៍នៅក្នុងករណីដែលការបញ្ជូនធ្វើតាមបញ្ញត្តិនៃមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល) នៃក្រមនេះ។

**ឈ**. ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន[36]។

---

[36] មាត្រា ២៥៤ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

# ជំពូកទី៣

# តួនាទី និងភារកិច្ចក្រឡាបញ្ជី ក្នុងដំណាក់កាលនីតិវិធី ត្រៀមសម្រាប់ការទាញហេតុផល

# ជំពូកទី៣
# តួនាទី និងភារកិច្ចក្រឡាបញ្ជីក្នុងដំណាក់កាលត្រៀមសម្រាប់ការទាញហេតុផល

ក្រឡាបញ្ជី ជាតួអង្គដ៏ចម្បងមួយនៅក្នុងដំណាក់នីមួយៗ ហើយក្រឡាបញ្ជីតែងតែជួយសម្រួលបញ្ហានៅគ្រប់ដំណាក់កាលនៃរឿងក្តីរដ្ឋប្បវេណី។ លើសពីនេះទៅទៀត មុននឹងឈានដល់ការបើកសវនាការ គឺតែងតែមានកិច្ចនីតិវិធីមួយចំនួនដើម្បីឱ្យគូភាគីសងខាងចូលខ្លួនមកបកស្រាយនូវអង្គហេតុដែលបានដាក់ពាក្យបណ្តឹង ប្រសិនបើភាគីម្ខាងនៃរឿងក្តី ពុំយល់ស្របលើអង្គហេតុទេ ក្រឡាបញ្ជីនឹងបន្តនីតិវិធីជាបន្ត។ ក្នុងករណីនៃការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុនេះ គឺដើម្បីឱ្យគូភាគីត្រៀមខ្លួន ដើម្បីដាក់ភស្តុតាងផ្សេងៗដែលជួយដោះបន្ទុក ឬដាក់បន្ទុកក្នុងមធ្យោបាយតទល់ដែលស្ថិតនៅតុលាការរដ្ឋប្បវេណី អាចនិយាយបានថា ជាផ្នែកមួយនៃការទទួលខុសត្រូវរបស់អង្គការតុលាការមុននឹងឈានដល់ដំណាក់កាលជំនុំជម្រះ។

សវនាការត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែសាធារណៈភាពនេះអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ល្អ ឬមានបញ្ញត្តិពិសេសក្នុងច្បាប់ចែងនៅគ្រប់ករណីទាំងអស់ សាលក្រម និងសាលដីកាតុលាការត្រូវប្រកាសនៅសាលសវនាការដែលបើកជាសាធារណៈ[37]។ នៅដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ រាល់ឯកសារត្រៀម និងការបញ្ជាក់របស់គូភាគីពុំចាត់ទុកជាភស្តុតាងឡើយ។ ប៉ុន្តែ ភាគីអាចស្នើសុំឱ្យតុលាការពិនិត្យភស្តុតាងបាន ក្នុងពេលនោះភស្តុតាងដែលអាចទទួលយកមកពិនិត្យបានមានតែភស្តុតាងជាឯកសារតែប៉ុណ្ណោះ។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់គូភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់[38]។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីកាត់បន្ថយនូវចំណុចវិវាទ ឬកុំឱ្យមានភាពស្មុគស្មាញលើចំណុចវិវាទ ដើម្បីជួយសម្រួលដល់ការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់ ពីព្រោះថា នៅពេលទាញហេតុផលដោយផ្ទាល់មាត់ភាគីនីមួយៗតែងតែលើកឡើងនូវអង្គហេតុផ្សេងៗ ដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់ខ្លួនឯងដោយពុំគិតថាអង្គហេតុនោះមាន ឬគ្មានសារៈសំខាន់ចំពោះរឿងក្តីនោះទេ។ ឯភាគីម្ខាងទៀត តែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុរបស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនយល់ថា មានផលប្រយោជន៍

[37] មាត្រា ៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

[38] មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

សម្រាប់ខ្លួនឯង ការធ្វើបែបនេះនឹងនាំឱ្យការជំនុំជម្រះក្ដីមានភាពស្មុគស្មាញ និងអូសបន្លាយពេលវេលាឥតប្រយោជន៍ដែលធ្វើឱ្យមានការលំបាកក្នុងការស្វែងរកការពិត។

ហេតុដូច្នេះហើយ បានជាមុនពេលនឹងចាប់ផ្ដើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវពិគ្រោះជាមួយភាគីទាំងសងខាងដើម្បីរៀបចំសេចក្ដីអះអាងរបស់គូភាគី និងបំភ្លឺអំពីចំណុចវិវាទជាមុនសិន។ ភាគីត្រូវធ្វើការស្រាវជ្រាវឱ្យបានលម្អិតជាមុនសិន នូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និងភស្តុតាងផ្សេងៗដើម្បីធ្វើការអះអាង និងបញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ក្នុងបណ្ដឹង[39]។

តុលាការ ត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស[40]។ ភាគីណាក៏មិនអាចត្រូវបានជម្រះក្ដីដោយមិនបានសាកសួរ ឬកោះហៅឡើយ[41]។ ដើម្បីធានានូវសិទ្ធិទាមទារឱ្យសាកសួរឱ្យមានប្រសិទ្ធិភាព ការជម្រះក្ដីត្រូវធ្វើឡើងដោយការកោះហៅភាគីទាំងសងខាងឱ្យមកបង្ហាញខ្លួននៅកាលបរិច្ឆេទតែមួយ ហើយត្រូវឱ្យភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថា សមរម្យចូលស្ដាប់បានជាអ្នកអង្កេតការណ៍[42]។

**កថាខណ្ឌទី១៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីមុនពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ក. ពិនិត្យរបាយការណ៍បញ្ជូន**

របាយការណ៍ដែលបានបញ្ជូនត្រឡប់មកវិញ ក្រឡាបញ្ជី ត្រូវយករបាយការណ៍នោះដាក់ក្នុងសំណុំរឿងវិញ ដើម្បីបញ្ជាក់ថា ក្រឡាបញ្ជី បានផ្ញើឯកសារដែលភ្ជាប់ជាមួយនឹងរបាយការណ៍នោះទៅឱ្យជនដែលត្រូវទទួលឯកសាររួចរាល់ហើយ។

**ខ. ការពិនិត្យវត្តមាន និងអត្តសញ្ញាណគូភាគី**

នៅមុនពេលចូលបន្ទប់សវនាការ ក្រឡាបញ្ជី ដែលទទួលបន្ទុកនៃសំណុំរឿងក្ដីត្រូវធ្វើលិខិតកត់ត្រាអំពីវត្តមានរបស់អ្នកចូលរួមដូចជា៖ ដើមចោទ ចុងចម្លើយ មេធាវី សាក្សី អ្នកជំនាញ អ្នកតំណាងដោយអាណត្តិ និង

[39] មាត្រា ៩២ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

[40] មាត្រា ៨០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[41] មាត្រា ៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[42] មាត្រា ១០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ជនជាប់ពាន់ព័ន្ធនឹងសំណុំរឿងក្តីជាដើម ដើម្បីបញ្ជាក់អំពីការដែលបានចូលរួមជំនុំជម្រះសំណុំរឿងក្តី និងទុកជាភស្តុតាងអំពីវត្តមាននៃការចូលរួម។ មិនតែប៉ុណ្ណោះ ងាយស្រួលក្នុងការផ្ទៀងផ្ទាត់អំពីការថ្លែងការណ៍របស់គូភាគី និងជនជាប់ពាក់ព័ន្ធនៅពេលដែលចៅក្រមទទួលបន្ទុកចេញសាលក្រម។

- **សម្គាល់៖** ចំពោះការត្រួតពិនិត្យវត្តមាននៅដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់ ក៏ប្រព្រឹត្តទៅដូចនឹងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែរ។

### គ. រៀបចំបន្ទប់ដំណើរការនីតិវិធី

មុនពេលចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រឡាបញ្ជីត្រូវបំពេញតួនាទីឱ្យបានខ្ជាប់ខ្ជួនជាពិសេសនោះ គឺត្រូវរៀបចំបន្ទប់សម្រាប់ដំណើរការនីតិវិធីទៅតាមកាលបរិច្ឆេទនៃសំណុំរឿងក្តី។ មិនតែប៉ុណ្ណោះ បន្ទាប់ពីរៀបចំបន្ទប់រួចហើយត្រូវរាយការណ៍ប្រាប់លោកចៅក្រម ដើម្បីត្រៀមខ្លួនក្នុងការអនុវត្តនីតិវិធី។

នៅមុនពេលជំនុំជម្រះក្តី ក្រឡាបញ្ជី ត្រូវចុះមករៀបចំបន្ទប់ចៅក្រមទទួលបន្ទុកនៃរឿងក្តី និងរៀបចំកន្លែងអង្គុយសម្រាប់គូភាគីនៃរឿងក្តីនោះឱ្យមានសណ្តាប់ធ្នាប់ល្អ និងរៀបរយ។ ហើយក្រឡាបញ្ជី ក៏ត្រូវរៀបចំកន្លែងដែលសមរម្យសម្រាប់ជនដែលជាប់ពាក់ព័ន្ធនឹងរឿងក្តីឱ្យមានសណ្តាប់ធ្នាប់ល្អផងដែរ។

- **សម្គាល់៖** ចំពោះការអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចប្រព្រឹត្តបាននៅបន្ទប់ចៅក្រមទទួលបន្ទុកនៃរឿងក្តីក៏បាន បន្ទប់សវនាការក៏បាន ហើយការរៀបចំបន្ទប់នេះអនុវត្តបានតែនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ។ ចំពោះដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ គឺត្រូវធ្វើនៅបន្ទប់សវនាការតែប៉ុណ្ណោះ។

## កថាខណ្ឌទី២៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីអំឡុងពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ក. ការកត់ត្រានូវដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅគ្រប់កាលបរិច្ឆេទនីមួយៗ[43]។ នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ៖

**ក.** សញ្ញាណនៃរឿងក្តី។

**ខ.** ឈ្មោះចៅក្រម និងក្រឡាបញ្ជី។

**គ.** ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញខ្លួន។

**ឃ.** ពេលវេលា និងទីកន្លែង។

[43] មាត្រា ១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជីត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលបានកំណត់នៅកថាខណ្ឌទី១ ខាងលើនេះ[44]។

**ខ. ចំណុចសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវសេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចដូចខាងក្រោមនេះ៖

**ក**. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ។

**ខ**. ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និងការស្នើសុំឱ្យពិនិត្យភស្តុតាង។

**គ**. ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និងការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ។

**ឃ**. ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់ការទាមទារ។

**ង**. ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រាតាមការទាមទាររបស់ភាគី។

**ច**. ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយល័ក្ខណ៍អក្សរ[45]។

**កថាខណ្ឌទី៣៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីក្រោយពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ជាក់នូវការរៀបចំចំណុចវិវាទ និងភស្តុតាងរួចហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាងអំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់តាមរយៈការពិនិត្យភស្តុតាងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាងហើយ នោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅពេលក្រោយ[46]។

ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីបានទៀតទេ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមធ្យោបាយនោះ

[44] មាត្រា ១១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[45] មាត្រា ១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[46] មាត្រា ១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬករណីដែលដាក់មធ្យោបាយថ្មីនោះមិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្ដឹង ឬករណីដែលភាគីបានធ្វើសេចក្ដីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយគ្មានកំហុសធ្ងន់ធ្ងរឡើយ[47]។

### ក. ការផ្ញើកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្នុងករណីដែលធ្វើការពិនិត្យ និងពិចារណាលើកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការដែលទទួលបន្ទុកនៃរឿងក្ដី ត្រូវផ្ញើនូវកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទៅឱ្យគូភាគីនៃសំណុំរឿងក្ដីដើម្បីឱ្យគូភាគីបានស្វែងយល់ និងដឹងអំពីខ្លឹមសារនៃកំណត់ហេតុ។ មិនតែប៉ុណ្ណោះ ប្រសិនបើគូភាគីមិនយល់ស្របត្រង់ចំណុចណានោះ ក៏អាចមកជួបលោកចៅក្រមទទួលបន្ទុកដើម្បីដាក់ភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកនៃរឿងក្ដី។

ការផ្ញើកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាប្រភេទឯកសារមួយដែលសរសេរបញ្ជាក់អំពីដំណើរការនីតិវិធីដែលត្រូវបានធ្វើឡើង ដើម្បីត្រៀមខ្លួនសម្រាប់ការទាញហេតុផល ឬកិច្ចសវនាការតាមច្បាប់។ កំណត់ហេតុនេះត្រូវសម្គាល់ និងបញ្ជាក់ព័ត៌មានសំខាន់ៗទាក់ទងនឹងការរៀបចំឯកសារ សក្ខីកម្ម និងនីតិវិធីមុនពេលសវនាការ។ ការផ្ញើកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុ គឺដើម្បីឱ្យគូភាគីនៃរឿងក្ដីបានដឹងអំពីខ្លឹមសារនៃកំណត់ហេតុរបស់តុលាការ។

- **សម្គាល់៖** ចំពោះការអនុវត្តនូវការផ្ញើកំណត់ស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ ក៏ប្រព្រឹត្តទៅដូចនឹងការផ្ញើកំណត់ហេតុស្ដីពីការត្រៀមសម្រាប់ការទាញហេតុផលដែរ។

### ខ. ការរៀបចំដីកាកោះហៅ និងលិខិតអញ្ជើញទៅអ្នកពាក់ព័ន្ធ

ដីកាកោះហៅ និងលិខិតអញ្ជើញក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវប្រព្រឹត្តទៅក្នុងបែបបទ និងទម្រង់ដូចគ្នានៃការអនុវត្តក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែរ។ បែបបទ និងទម្រង់នៃឯកសារ គឺជាបែបបទ និងទម្រង់តែមួយចំពោះការអនុវត្តនៃនីតិវិធីដែលមានសរសេរក្នុងដំណាក់កាលនៃនីតិវិធីត្រៀម។

- **សម្គាល់៖** ចំពោះការកោះហៅនៅនីតិវិធីត្រៀមក៏ត្រូវការរបាយការណ៍បានបញ្ជូនដែរ។

[47] មាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

# ជំពូកទី៤
# តួនាទី និងភារកិច្ចក្រឡាបញ្ជី
# ក្នុងដំណាក់កាល
# ការទាញហេតុផលដោយផ្ទាល់មាត់

# ជំពូកទី៤
# តួនាទី និងភារកិច្ចក្រឡាបញ្ជីក្នុងដំណាក់កាល
# ការទាញហេតុផលដោយផ្ទាល់មាត់

ការជំនុំជម្រះលើបណ្តឹង ត្រូវប្រព្រឹត្តឡើងដោយការងារសហការគ្នារវាងតុលាការ និងភាគីទាំងសងខាងដែលជាប្រធាននៃបណ្តឹង ដោយផ្អែកលើការបែងចែកតួនាទីរៀងៗខ្លួន។ ក្រមនីតិវិធីរដ្ឋប្បវេណី បានចែងអំពីការបែងចែកតួនាទី ឬក៏ហៅម៉្យាងទៀតថា សិទ្ធិអំណាច និងការទទួលខុសត្រូវដោយបានកំណត់ដូចតទៅនេះ។ ការរៀបចំនៃការជំនុំជម្រះ គឺជាសិទ្ធិអំណាច និងការទទួលខុសត្រូវចម្បងរបស់តុលាការ ដោយឡែក ការកំណត់នូវចំណុចដែលជាកម្មវត្ថុនៃការជំនុំជម្រះ និងការសម្រេចសេចក្តី ការបំភ្លឺអំពីអង្គហេតុនៃរឿងក្តី និងការផ្តល់ឯកសារជាមូលដ្ឋានសម្រាប់ការសម្រេចសេចក្តី គឺជាសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ភាគី។

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម[48]។ ដើម្បីចេញសាលក្រមទៅលើបណ្តឹង តុលាការចាំបាច់ត្រូវតែឆ្លងកាត់នូវការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែ ចំពោះរឿងក្តី ឬចំណុចណាដែលត្រូវសម្រេចដោយដីកាសម្រេច តុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនត្រូវធ្វើ[49]។ ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន។ ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងនៅសាលសវនាការជាសាធារណៈ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណី ដែលភាពជាសាធារណៈនេះបណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់[50]។

ក្នុងករណីដែលភាពសាធារណៈបណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ នោះតុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈបាន ដោយតុលាការត្រូវកត់ត្រាអំពីហេតុការណ៍នោះ ព្រមទាំងមូលហេតុនៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់។ នៅពេលថ្ងៃចាប់ផ្តើមបើកសវនាការបានមកដល់ ក្រឡាបញ្ជី ត្រូវរួសរាន់រៀបចំសៀវភៅកំណត់ហេតុសវនាការ សំណុំរឿងក្តី និងរៀបចំឯកសណ្ឋានសម្រាប់ចូលបន្ទប់សវនាការ។ ខាងក្រោមនេះ នឹងរៀបរាប់អំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីក្នុងដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់។ ក្រៅពីកិច្ចដែលបានបញ្ចប់ក្រោយពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុ

[48] មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[49] មាត្រា ១១៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[50] មាត្រា ១១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ផលដូចដែលបានរៀបរាប់ខាងលើនេះ ក្រឡាបញ្ជី នៅមិនទាន់អស់តួនាទី និងភារកិច្ចនៅឡើយទេ។ ខាងក្រោមនេះ គឺជាតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីដែលត្រូវអនុវត្តនីតិវិធីបន្ត។

**កថាខណ្ឌទី១៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីមុនពេលការទាញហេតុផលដោយផ្ទាល់មាត់**

ក្រឡាបញ្ជីត្រូវប្រគល់ទៅភាគីនូវលិខិតលាយល័ក្ខណ៍អក្សរដែលពន្យល់នូវអត្ថន័យនៃនីតិវិធីនៃការជំនុំជម្រះ និងការសម្រេចសេចក្តីតាមរឿងក្តីចំនួនទឹកប្រាក់តិច នៅពេលកោះហៅតាមកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងរឿងក្តីចំនួនទឹកប្រាក់តិច។ នៅពេលដំបូងនៃកាលបរិច្ឆេទដែលបានកំណត់ខាងលើនេះ តុលាការត្រូវពន្យល់ភាគីនូវចំណុចដូចខាងក្រោមនេះ៖

**ក**. លើកលែងតែក្នុងករណីដែលមានសភាពការណ៍ពិសេស តុលាការត្រូវបញ្ចប់នូវការជំនុំជម្រះនៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់។

**ខ**. ចំពោះសាលក្រមចុងក្រោយនៃរឿងក្តីចំនួនទឹកប្រាក់តិច ភាគីពុំអាចធ្វើឧបាស្រ័យបានឡើយ លើកលែងតែបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។

**គ**. ការពិនិត្យភស្តុតាង អាចធ្វើបានចំពោះតែភស្តុតាងដែលអាចពិនិត្យបានភ្លាមៗប៉ុណ្ណោះ។

**ឃ**. ចុងចម្លើយអាចធ្វើសេចក្តីថ្លែងការណ៍ឱ្យផ្ទេរបណ្តឹងទៅនឹងនីតិវិធីបណ្តឹងធម្មតាបាន។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចុងចម្លើយបានធ្វើការឆ្លើយទាញហេតុផល នៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ឬក្រោយពេលកាលបរិច្ឆេទនោះបានបញ្ចប់ហើយ[51]។

**ក. ការពិនិត្យរបាយការណ៍បញ្ជូន**

របាយការណ៍ដែលបានបញ្ជូនត្រឡប់មកវិញ ក្រឡាបញ្ជី ត្រូវយករបាយការណ៍នោះដាក់ក្នុងសំណុំរឿងវិញ ដើម្បីបញ្ជាក់ថា ក្រឡាបញ្ជី បានផ្ញើឯកសារដែលភ្ជាប់ជាមួយនឹងរបាយការណ៍នោះទៅឱ្យជនដែលត្រូវទទួលឯកសាររួចរាល់ហើយ។

- **សម្គាល់៖** របាយការណ៍បញ្ជូននៅក្នុងនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីនេះ គឺមានអត្ថន័យ និងទម្រង់ដូចគ្នាចាប់តាំងពីមានការផ្ញើដីកានៅដំណាក់កាល

  ពីដំបូងរហូតដល់ការបញ្ចប់នីតិវិធីនៃសំណុំរឿងក្តីនេះ។

**ខ. ការពិនិត្យវត្តមាន និងអត្តសញ្ញាណគូភាគី**

នៅមុនពេលចូលបន្ទប់សវនាការ ក្រឡាបញ្ជី ដែលទទួលបន្ទុកនៃសំណុំរឿងក្តីត្រូវធ្វើលិខិតកត់ត្រាអំពីវត្តមានរបស់អ្នកចូលរួមដូចជា៖ ដើមចោទ ចុងចម្លើយ មេធាវី សាក្សី អ្នកជំនាញ អ្នកតំណាងដោយអាណត្តិ

[51] មាត្រា ២២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

និងជនជាប់ពាក់ព័ន្ធនឹងសំណុំរឿងក្តីជាដើម ដើម្បីបញ្ជាក់អំពីការដែលបានចូលរួមជំនុំជម្រះសំណុំរឿងក្តី និងទុកជាភស្តុតាងអំពីវត្តមាននៃការចូលរួម។ មិនតែប៉ុណ្ណោះ ងាយស្រួលក្នុងការផ្ទៀងផ្ទាត់អំពីការថ្លែងការណ៍របស់គូភាគី និងជនជាប់ពាក់ព័ន្ធនៅពេលដែលចៅក្រមទទួលបន្ទុកចេញសាលក្រម។

**គ. រៀបចំបន្ទប់សវនាការ**

មុនពេលបើកសវនាការ ក្រឡាបញ្ជី ត្រូវរួសរាន់រៀបចំបន្ទប់សវនាការសម្រាប់ធ្វើការជំនុំជម្រះរឿងក្តី ដែលបានកំណត់តាមកាលបរិច្ឆេទនៃសំណុំរឿង។ នៅមុនពេលជំនុំជម្រះ ក្រឡាបញ្ជី ត្រូវចុះមកត្រួតពិនិត្យ និងរៀបចំបើកឧបករណ៍ដែលត្រូវប្រើប្រាស់ក្នុងពេលដំណើរការសវនាការ។ មិនតែប៉ុណ្ណោះ បន្ទាប់ពីរៀបចំបន្ទប់សវនាការរួចហើយ ត្រូវរាយការណ៍ប្រាប់ចៅក្រមអំពីបន្ទប់សវនាការ និងការត្រួតពិនិត្យវត្តមានរបស់អ្នកចូលរួមជំនុំជម្រះ ដើម្បីឱ្យចៅក្រមត្រៀមខ្លួនក្នុងការជំនុំជម្រះ ដើម្បីបន្តអនុវត្តលើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់។ ក្រឡាបញ្ជី ក៏ត្រូវរៀបចំកន្លែងដែលសមរម្យសម្រាប់ជនដែលជាប់ពាក់ព័ន្ធនឹងរឿងក្តីឱ្យមានសណ្តាប់ធ្នាប់ល្អផងដែរ ដើម្បីជៀសវាងក្នុងការបង្កឱ្យមានភាពរញ៉េរញ៉ៃនាពេលសវនាការ។

**ឃ. ការដឹកនាំធ្វើសម្បថ (ករណីមានសាក្សី)**

តុលាការត្រូវឱ្យសាក្សីធ្វើសម្បថ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស។ ក្នុងករណីសាក្សីដែលនឹងត្រូវសួរ ជាជនដែលមានអាយុក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឬជនដែលមិនយល់អំពីអត្ថន័យនៃសម្បថ តុលាការមិនអាចឱ្យសាក្សីនោះធ្វើសម្បថបានឡើយ។ សម្បថរបស់សាក្សី ត្រូវធ្វើនៅមុនពេលសាកសួរ។ ប៉ុន្តែបើមានមូលហេតុពិសេស អាចធ្វើនៅក្រោយពេលសាកសួរបាន។ មុនពេលធ្វើសម្បថ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវពន្យល់អំពីគោលបំណងនៃសម្បថ ហើយប្រាប់ឱ្យដឹងជាមុនអំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីភាពក្លែងក្លាយ[52]។

## កថាខណ្ឌទី២៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីអំឡុងពេលការទាញហេតុផលដោយផ្ទាល់មាត់

បន្ទាប់ពីអានអង្គហេតុរួចហើយ ក្រឡាបញ្ជី ត្រូវផ្ចង់អារម្មណ៍ក្នុងការស្តាប់អំពីការសាកសួររបស់ចៅក្រមទទួលបន្ទុក និងត្រៀមសម្រាប់ការកត់ត្រានូវសេចក្តីថ្លែងការណ៍នៅក្នុងសំណុំរឿងក្តីទាំងមូល និងកិច្ចពិភាក្សាដេញដោលសំណួរចម្លើយរបស់ជនដែលជាប់ពាក់ព័ន្ធរួមមាន៖ មេធាវី ដើមចោទ ចុងចម្លើយ និងសាក្សីក្នុងសវនាការ។ ហើយរាល់ការកត់ត្រាទាំងអស់ក្នុងសវនាការ ត្រូវកត់ត្រាទុកនៅក្នុងសៀវភៅកំណត់ហេតុស្តីពីការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី។

[52] មាត្រា ១៣៧ កថាខណ្ឌទី១ ទី២ ទី៤ និងទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

## ក. ការកត់ត្រានូវដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់

តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ នៅគ្រប់កាលបរិច្ឆេទនីមួយៗ[53]។ នៅក្នុងកំណត់ហេតុស្ដីពីការទាញហេតុដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ៖

**ក**. សញ្ញាណនៃរឿងក្ដី។

**ខ**. ឈ្មោះចៅក្រម និងក្រឡាបញ្ជី។

**គ**. ឈ្មោះតំណាងអយ្យការដែលបានចូលរួមប្រសិនបើមាន។

**ឃ**. ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញខ្លួន។

**ង**. ពេលវេលា និងទីកន្លែងនៃការទាញហេតុផលដោយផ្ទាល់មាត់។

**ច**. ហេតុការណ៍ដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬហេតុការណ៍ និងមូលហេតុដែលមិនបានធ្វើជាសាធារណៈក្នុងករណីមិនធ្វើជាសាធារណៈ។

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជីត្រូវចុះហត្ថលេខានៅក្នុងកំណត់ហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ[54]។

## ខ. ចំណុចសារធាតុនៃកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់

នៅក្នុងកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវសេចក្ដីសង្ខេបអំពីការទាញហេតុផលនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ៖

**ក**. ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ និងការសារភាព។

**ខ**. សេចក្ដីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និងរបស់អ្នកធ្វើកោសលវិច័យ។

**គ**. ការធ្វើសម្បថ ឬមិនធ្វើសម្បថរបស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និងរបស់អ្នកធ្វើកោសលវិច័យ និងមូលហេតុដែលមិនបានឱ្យសាក្សី និងអ្នកធ្វើកោសលវិច័យធ្វើសម្បថ។

**ឃ**. លទ្ធផលនៃការត្រួតពិនិត្យ។

**ង**. ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រាតាមការទាមទាររបស់ភាគី។

**ច**. ការសម្រេចសេចក្ដីដែលបានធ្វើឡើងដោយមិនបានធ្វើជាលាយល័ក្ខណ៍អក្សរ។

**ឆ**. ការប្រកាសសេចក្ដីសម្រេច។

53 មាត្រា ១១៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

54 មាត្រា ១១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ក្នុងករណីដែលបណ្ដឹងត្រូវបានបញ្ចប់ដោយមិនតាមការសម្រេចសេចក្ដីទេ សេចក្ដីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និងរបស់អ្នកធ្វើកោសលវិច័យ និងលទ្ធផលនៃការត្រួតពិនិត្យអាចមិនសរសេរក្នុងកំណត់ហេតុបាន ដោយទទួលបានការអនុញ្ញាតពីតុលាការ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលភាគីទាមទារឱ្យកត់ត្រាក្នុងកំណត់ហេតុ ក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ គិតចាប់ពីខ្លួនដែលខ្លួនបានដឹងថាបណ្ដឹងនោះត្រូវបានចប់[55]។

**កថាខណ្ឌទី៣៖ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីក្រោយពេលការទាញហេតុផលដោយផ្ទាល់មាត់**

ក្នុងករណីដែលបណ្ដឹង ត្រូវបានបញ្ចប់ដោយមិនតាមការសម្រេចសេចក្ដីទេ សេចក្ដីថ្លែងការណ៍របស់សាក្សី របស់គូភាគី របស់អ្នកធ្វើកោសលវិច័យ និងលទ្ធផលនៃការពិនិត្យអាចមិនសរសេរក្នុងកំណត់ហេតុបានដោយទទួលការអនុញ្ញាតពីតុលាការ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលភាគីទាមទារឱ្យកត់ត្រានៅក្នុងកំណត់ហេតុការទាញហេតុផលដោយផ្ទាល់មាត់ ក្នុងពេល ១ (មួយ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលខ្លួនបានដឹងថាបណ្ដឹងនោះត្រូវបានបញ្ចប់។ ក្រៅពីចៅក្រមទទួលបន្ទុករឿងក្ដី ក្រឡាបញ្ជី និងអ្នកចូលរួមដែលពាក់ព័ន្ធនឹងសំណុំរឿងក្ដីត្រូវចុះហត្ថលេខា ឬផ្ដិតមេដៃនៅលើបញ្ជីវត្តមាន និងកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់។

**ក. ការផ្ញើកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់**

ក្នុងករណីដែលធ្វើការពិនិត្យ និងពិចារណាលើអង្គនៃកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ តុលាការដែលទទួលបន្ទុកនៃរឿងក្ដី ត្រូវផ្ញើនូវកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់នោះទៅឱ្យគូភាគីនៃសំណុំរឿងក្ដីដើម្បីឱ្យគូភាគីបានស្វែងយល់ និងដឹងអំពីខ្លឹមសារនៃកំណត់។ មិនតែប៉ុណ្ណោះ ប្រសិនបើគូភាគីមិនយល់ស្របត្រង់ចំណុចណានោះ ក៏អាចមកជួបលោកចៅក្រមទទួលដើម្បីដាក់ភស្ដុតាងដាក់បន្ទុក ឬដោះបន្ទុកនៃរឿងក្ដី។

ការផ្ញើកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ គឺជាការកត់ត្រាដោយផ្ទាល់ទៅនឹងការពិភាក្សានៃការទាញហេតុផល ឬសេចក្ដីថ្លែងការណ៍របស់គូភាគី ឬការដាក់បញ្ចូលភស្ដុតាងនៅក្នុងដំណើរការរឿងក្ដី។ ការផ្ញើកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ អាចចាប់ផ្ដើមការជជែកអំពីសក្ខីកម្ម ឬចម្លើយពីបុគ្គលដែលជាប់ពាក់ព័ន្ធនឹងរឿងក្ដី។ ការផ្ញើកំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ គឺដើម្បីឱ្យគូភាគីនៃរឿងក្ដីបានដឹងអំពីខ្លឹមសារនៃកំណត់ហេតុរបស់តុលាការ។

[55] មាត្រា ១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### ខ. ការពិនិត្យភស្តុតាងដោយសមូហវិធី

តុលាការ និងភាគីសងខាង ត្រូវធ្វើការបញ្ជាក់ថា តើអង្គហេតុណាខ្លះដែលជាចំណុចវិវាទ ហើយដែលត្រូវបានក្លាយជាកម្មវត្ថុនៃការពិនិត្យភស្តុតាង ហើយតុលាការ និងភាគីសងខាងត្រូវមានការទទួលស្គាល់រួមគ្នាចំពោះបញ្ហានេះ ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធីនៅពេលទាញហេតុផលដោយផ្ទាល់មាត់។ តុលាការ អាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្តីដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន[56]។ នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង ដែលធ្វើឡើងបន្ទាប់ពីបានបញ្ចប់ការរៀបចំចំណុចវិវាទ និងភស្តុតាងរួចហើយ។

តុលាការត្រូវធ្វើឱ្យការពិនិត្យភស្តុតាងអាចប្រព្រឹត្តទៅជាបន្ទាន់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ បន្ទាប់ពីបានបញ្ចប់ការរៀបចំណុចវិវាទ និងភស្តុតាងរួចហើយ។ ការសាកសួរទៅលើសាក្សី ឬសាមីភាគី បើអាចធ្វើបានត្រូវតែធ្វើដោយសមូហវិធី[57]។ តាមរយៈការពិនិត្យភស្តុតាង ដោយសមូហវិធី តុលាការនឹងអាចធ្វើដោយការវិនិច្ឆ័យបានត្រឹមត្រូវ ហើយបានលឿន ដោយផ្អែកលើជំនឿទុកចិត្តថ្មីៗ។

### គ. ការប្រកាសសាលក្រម

សាលក្រម គឺជាការសម្រេចសេចក្តីដែលតុលាការធ្វើលិខិតសាលក្រមដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ដែលច្បាប់បានកំណត់ ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងក្រមនេះ ឬនៅក្នុងច្បាប់ផ្សេង ហើយកើនអានុភាពដោយការប្រកាស ដោយផ្អែកលើកលិខិតសាលក្រមនោះ[58]។ ចំណុចនេះមានន័យថា ចំពោះបណ្តឹងធម្មតាជាគោលការណ៍វិនិច្ឆ័យទៅលើពាក្យបណ្តឹងថាមានលក្ខណៈគ្រប់គ្រាន់ ហើយត្រឹមត្រូវតាមច្បាប់កំណត់ ឬមិនត្រូវតាមច្បាប់កំណត់ ឬក៏ការវិនិច្ឆ័យលើការទាមទារក្នុងពាក្យបណ្តឹងថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ឬមិនត្រឹមត្រូវតាមច្បាប់ គឺត្រូវធ្វើដោយសាលក្រម។ សាលក្រម នឹងមានអានុភាពដោយការប្រកាស[59]។

ជាគោលការណ៍ កំណើតនៃអានុភាពនៃសាលក្រម នឹងមានអានុភាពដោយការប្រកាសដែលជាទម្រង់នៃការជូនដំណឹងពិសេស។ ទម្រង់ណាក្រៅពីការប្រកាសនេះ មិនបណ្តាលឱ្យមានអានុភាពឡើយ។ ការប្រកាសសាលក្រម អាចធ្វើបានទោះបីជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ[60]។ ការប្រកាសត្រូវធ្វើជាសាធារណៈ។ តុលាការត្រូវប្រកាសសាលក្រមភ្លាម ក្រោយពេលដែលការទាញហេតុផលដោយផ្ទាល់មាត់

[56] មាត្រា ១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[57] មាត្រា ១២៧ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[58] មាត្រា ១៧៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[59] មាត្រា ១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[60] មាត្រា ១៨៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

បានបញ្ចប់ លើកលែងតែករណីដែលយល់ឃើញថាមិនសមរម្យ។ ការប្រកាសសាលក្រមអាចធ្វើឡើងបាន ដោយមិនចាំបាច់ផ្អែកលើច្បាប់ដើមនៃមូលសាលក្រមឡើយ។ ក្នុងករណីនេះ តុលាការត្រូវប្រកាសសាលក្រម ដោយប្រាប់សេចក្ដីសម្រេចបញ្ចប់ និងខ្លឹមសារនៃសំអាងហេតុ[61]។

**គ.១. ការកត់ត្រានូវដំណើរការនៃការប្រកាសសាលក្រម**

តុលាការត្រូវឱ្យក្រឡាបញ្ជីកត់ត្រានូវហេតុដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ ក្នុងកំណត់ហេតុនៃកាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ដែលតុលាការប្រកាសសាលក្រម ជំនួសការការធ្វើលិខិតសាលក្រម៖

**ក**. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង ដែលច្បាប់បានកំណត់។

**ខ**. សាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ។

**គ**. សេចក្ដីសម្រេចបញ្ចប់។

**គ.២. ការកត់ត្រានូវដំណើរការនៃសាលក្រមនៃរឿងក្ដីដែលមានចំនួនទឹកប្រាក់តិច**

នៅលើលិខិតសាលក្រមនៃរឿងក្ដីចំនួនទឹកប្រាក់តិច ឬលើកំណត់ហេតុជំនួសលិខិតសាលក្រមនោះ ត្រូវសរសេរថា ជាសាលក្រមនៃរឿងក្ដីចំនួនទឹកប្រាក់តិច[62]។ នៅក្នុងលិខិតសាលក្រម ត្រូវសរសេរចំណុចដូចខាងក្រោមនេះ៖

**ក**. តុលាការ។

**ខ**. ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

**គ**. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង ដែលច្បាប់បានកំណត់។

**ឃ**. អង្គហេតុ និងចំណុចវិវាទ។

**ង**. សំអាងហេតុ។

**ច**. សេចក្ដីសម្រេចចុងបញ្ចប់។

ចំពោះអង្គហេតុ និងចំណុចវិវាទ ត្រូវសរសេរខ្លឹមសារសំខាន់ៗដោយផ្អែកលើសេចក្ដីថ្លែងការណ៍របស់ភាគី។ ចៅក្រមដែលចេញសាលក្រម ត្រូវចុះហត្ថលេខាលើលិខិតសាលក្រមនោះ[63]។

[61] មាត្រា ២៣៦ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[62] មាត្រា ២៣៦ កថាខណ្ឌទី៣ និងទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[63] មាត្រា ១៨៩ កថាខណ្ឌទី១ ទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

### ឃ. ការបញ្ជូនអនុសារៈសាលក្រម

លិខិតសាលក្រមត្រូវបញ្ជូនទៅឱ្យគូភាគី ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនេះ។ ការបញ្ជូនដែលបានកំណត់ខាងលើនេះ ត្រូវបានធ្វើឡើងដោយអនុសារសាលក្រម[64]។ ទោះបីជាមាន ឬគ្មានវត្តមានរបស់គូភាគីនៅពេលប្រកាសាលក្រមក៏ដោយ ក៏ការបញ្ជូនលិខិតសាលក្រមទៅឱ្យគូភាគីនៃរឿងក្ដី គឺក្នុងគោលបំណងឱ្យគូភាគីដឹងច្បាស់លាស់អំពីអត្ថន័យរបស់សាលក្រម។ ម៉្យាងទៀត ឆ្លងកាត់ការបញ្ជូននេះអំឡុងពេលអាចប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចាប់ពីដំណើរការ ហើយភាគីដែលឈ្នះក្ដីអាចដាក់ពាក្យសុំទៅតុលាការអនុវត្តជាបណ្ដោះអាសន្នបាន។

### ខ. របាយការណ៍បញ្ជូន

របាយការណ៍បញ្ជូន គឺជាលិខិតមួយដែលចាំបាច់មានភ្ជាប់ជាមួយនឹងលិខិតបញ្ជូនសាលក្រម ដើម្បីបញ្ជាក់អំពីការផ្ញើទៅកាន់ដើមចោទ និងចុងចម្លើយ ឬជនដែលជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿងក្ដី។ ជាពិសេសជារបាយការណ៍ដែលបានផ្ដល់ដំណឹងដល់មេភូមិ ឬមេឃុំឱ្យផ្ដល់ដំណឹងដល់គូភាគីដែលមាននៅក្នុងលិខិតសាលក្រម និងជាភស្តុតាងដែលបានបញ្ជាក់ថា ក្រឡាបញ្ជីពិតជាបានបញ្ជូនលិខិតសាលក្រមទៅជនដែលជាប់ពាក់ព័ន្ធពិតប្រាកដមែន។ ការបញ្ជូន ត្រូវបានប្រព្រឹត្តដោយបុគ្គលិកប្រៃសណីយ៍អាជ្ញាសាលា ឬក្រឡាបញ្ជី[65]។ ឯកសារដែលត្រូវបញ្ជូន គឺជាឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។ ក្នុងករណី ដែលអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុកការបញ្ជូនគប្បីពន្យល់នូវខ្លឹមសារនៃឯកសារនោះ នៅពេលប្រគល់ឯកសារ[66]។

## កថាខណ្ឌទី៤៖ ការចារនូវការចូលជាស្ថាពរនៃសាលក្រមក្នុងករណីមិនមានបណ្ដឹងទាស់ ឬបណ្ដឹងឧទ្ធរណ៍

ពេលដែលច្បាប់បានផ្ដល់សិទ្ធិឱ្យទៅភាគីប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬប្ដឹងទាស់ដោយស្របច្បាប់នោះ សាលក្រមមិនចូលជាស្ថាពរឡើយ។ សាលក្រមមិនអាចចូលជាស្ថាពរ នៅមុនពេលផុតអំឡុងពេលដែលបានកំណត់សម្រាប់ការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលស្របច្បាប់ ឬការប្ដឹងទាស់ដែលស្របច្បាប់បានទេ។ ការចូលជាស្ថាពរនៃសាលក្រម ត្រូវបានបង្អាក់ ដោយការដាក់ពាក្យបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬពាក្យបណ្ដឹងទាស់ដែលត្រូវបានធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី១

[64] មាត្រា ១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[65] មាត្រា ២៤៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[66] មាត្រា ២៤៧ កថាខណ្ឌទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ខាងលើនេះ[67]។ នៅពេលសាលក្រមចូលជាស្ថាពរហើយ អានុភាពនៃអាជ្ញាអស់ជំនុំត្រូវកើនឡើង។ អាជ្ញាអស់ជំនុំដែលបានកំណត់ខាងលើនេះ ត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ ទំហំនៃអាជ្ញាអស់ជំនុំដែលបានកំណត់ខាងលើនេះ មានត្រឹមតែទំហំដែលបានវិនិច្ឆ័យនៅក្នុងសេចក្តីសម្រេចបញ្ចប់ ចំពោះការទាមទារដែលបានសុំដោយពាក្យបណ្តឹង ឬពាក្យបណ្តឹងតបតែប៉ុណ្ណោះហើយអានុភាពនៃអាជ្ញាអស់ជំនុំនេះមិនអាចមាននៅលើសេចក្តីវិនិច្ឆ័យក្នុងសំអាងហេតុនៃសាលក្រមបានទេ[68]។

ហើយម្យ៉ាងទៀត បើចុងចម្លើយទាមទារការទូទាត់ដោយសិទ្ធិលើបំណុលតបសេចក្តីវិនិច្ឆ័យក្នុងសាលក្រមស្ថាពរ ដែលសម្រេចថាគ្មានសិទ្ធិលើបំណុលតបទេ ត្រូវបង្កើតអានុភាពនៃអាជ្ញាអស់ជំនុំលើទឹកប្រាក់ ដែលបានតវ៉ាដោយការទូទាត់នោះ។ ពេលសាលក្រមចូលជាស្ថាពរ បង្កើតអានុភាពអនុវត្តចាប់តាំងពីពេលដែលអាជ្ញាអស់ជំនុំត្រូវបានកើតឡើង។

### គ. លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម

ក្នុងករណី ដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ[69]។ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត[70]។ ក្នុងករណី ដែលលិខិតអនុវត្តជាសេចក្តីសម្រេចដែលមិនបង្កើតអានុភាពបើមិនចូលជាស្ថាពរទេ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តចំពោះលិខិតអនុវត្តនោះ ម្ចាស់បំណុចនៃការអនុវត្តត្រូវភ្ជាប់មកជាមួយពាក្យសុំនូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលច្បាស់លាស់ថា សេចក្តីសម្រេចនោះបានចូលជាស្ថាពរហើយ ក្នុងសំណុំរឿង[71]។

[67] មាត្រា ១៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[68] មាត្រា ១៩៤ កថាខណ្ឌទី១ ទី២ និងទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[69] មាត្រា ៣៤៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[70] មាត្រា ៣៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[71] មាត្រា ២៥៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

**ខ. ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត**

ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងដោយលិខិតជាលាយល័ក្ខណ៍អក្សរ ដែលសរសេរចំណុចដូចខាងក្រោមនេះ៖

**ក**. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

**ខ**. សញ្ញាណនៃលិខិតអនុវត្ត។

**គ**. ហេតុការណ៍ និងមូលហេតុ បើការទាមទារឱ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) ឬកថាខណ្ឌទី១ នៃមាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ជាអាទិ៍) នៃក្រមនេះ[72]។

**ខ.១. ចំណុចដែលត្រូវសរសេរក្នុងរូបមន្តអនុវត្ត**

ការផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែម នៅផ្នែកក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនូវចំណុចនីមួយៗដូចខាងក្រោមនេះ៖

**ក**. បុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបាន ដោយលិខិតអនុវត្តនោះ និងភាគីម្ខាងទៀត។

**ខ**. ហេតុការណ៍ ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ។

**គ**. ទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបានផ្តល់រូបមន្តអនុវត្តតែមួយផ្នែកនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត។

**ឃ**. ហេតុការណ៍ ក្នុងករណីដែលផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ៣៥៨ (ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ជាអាទិ៍) នៃក្រមនេះ។

ក្រឡាបញ្ជី ឬសារការី ត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្ត ដោយសរសេរថ្ងៃ ខែ ឆ្នាំ នៃការផ្តល់[73]។

**ខ.២. ការផ្តល់រូបមន្តអនុវត្ត**

រូបមន្តអនុវត្ត ត្រូវបានផ្តល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះតាមពាក្យសុំ។ ប៉ុន្តែចំពោះលិខិតអនុវត្តដែលបានកំណង់នៅក្នុងចំណុច ច កថាខណ្ឌទី២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះ ត្រូវផ្តល់ដោយសារការីដែលរក្សាទុកនូវលិខិតដើមនោះ[74]។

[72] មាត្រា ៣៥៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[73] មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[74] មាត្រា ៣៥៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

នៅក្នុងករណីដែលសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ ក្រឡាបញ្ជី ឬសារការីអាចប្រគល់រូបមន្តអនុវត្តបាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានបញ្ជាក់អំពីការបំពេញល័ក្ខខ័ណ្ឌ ឬការមកដល់នូវពេលកំណត់មិនពិតប្រាកដនោះ[75]។

ដើម្បីឱ្យរូបមន្តអនុវត្តមានប្រសិទ្ធិភាព លុះត្រាតែអ្នកដាក់ពាក្យសុំស្នើសុំរូបមន្តអនុវត្តភ្ជាប់ជាមួយនឹងលិខិតបញ្ជាក់ស្ថាពរ។ ជាគោលការណ៍សន្មត់ ក្រឡាបញ្ជី ជាអ្នកមានសិទ្ធិចេញលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម និងចេញរូបមន្តអនុវត្ត។

## គ. ការបញ្ជូនសំណុំរឿងទៅតុលាការជាន់ខ្ពស់ក្នុងករណីមានបណ្តឹងឧទ្ធរណ៍

ក្នុងករណីដែលពាក្យបណ្តឹងឧទ្ធរណ៍ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា ២៦៥ (របៀបប្តឹងឧទ្ធរណ៍) នៃក្រមនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវកំណត់អំឡុងពេលសមរម្យមួយ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៅក្នុងអំឡុងពេលនោះ។ ប្រសិនបើដើមបណ្តឹងឧទ្ធរណ៍មិនបានកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះដោយដីកាសម្រេច[76]។

ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅចុងបណ្តឹងឧទ្ធរណ៍។ បញ្ញត្តិនៃមាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍បានរួមទាំងករណីដែលមិនបានបង់ជាមុន នូវសោហ៊ុយចាំបាច់សម្រាប់បញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍[77]។

[75] មាត្រា ៣៥៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[76] មាត្រា ២៦៦ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[77] មាត្រា ២៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងបកស្រាយប្រធានបទខាងលើរួចមក យើងខ្ញុំយល់ឃើញថា តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីសវនាការក្នុងរឿងក្ដីរដ្ឋប្បវេណី គឺពិតជាសំខាន់ណាស់ ដើម្បីឱ្យរឿងក្ដីរដ្ឋប្បវេណីមួយដំណើរការបានយ៉ាងរលូន និងត្រឹមត្រូវទៅតាមបញ្ញត្តិច្បាប់ជាធរមាន គឺត្រូវការចាំបាច់នូវវត្តមានក្រឡាបញ្ជី ដែលជាតួអង្គក្រឡាបញ្ជី តែងតែមានវត្តមានជានិច្ចនៅគ្រប់កិច្ចនីតិវិធីតុលាការ រាប់ចាប់តាំងពីកិច្ចដំបូងនៃការទទួលពាក្យបណ្ដឹង រហូតដល់បណ្ដឹងនោះសម្រេចក្ដីចប់សព្វគ្រប់ ជាពិសេស គឺដំណាក់កាលសវនាការ ដែលហៅថា នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ ដែលតម្រូវឱ្យក្រឡាបញ្ជីត្រូវធ្វើយ៉ាងណាឱ្យរឿងក្ដីនោះ ស្របទៅតាមច្បាប់កំណត់ដែលជៀសវាងឱ្យគូភាគីនៃរឿងក្ដីរដ្ឋប្បវេណីទទួលបាននូវការសម្រេចសេចក្ដីមួយដោយមិនបានឆ្លងកាត់សវនាការ ដែលហៅថា (នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់) របស់តុលាការដែលស្របទៅតាមគោលការណ៍ចំពោះមុខដែលច្បាប់បានចែង។ លើសពីនេះទៅទៀត បន្ទាប់ពីតុលាការបានចេញសេចក្ដីសម្រេចរួមមក តួអង្គក្រឡាបញ្ជីនៅតែមានតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាសំណុំរឿង ឯកសារដែលមានក្នុងសំណុំរឿង ធានាបានយ៉ាងល្អនូវការទុកដាក់សំណុំរឿងឱ្យមានសុវត្ថិភាព និងមានសណ្ដាប់ធ្នាប់ល្អផងដែរ។

នៅដំណាក់កាលនីមួយៗខាងលើនេះ មុននឹងឈានដល់ដំណាក់កាលជំនុំជម្រះ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីមុនពេលសវនាការពិតជាសំខាន់ ដោយសារតែមុនពេលសវនាការ ការអនុវត្តកាតព្វកិច្ចរបស់ក្រឡាបញ្ជីក៏មានច្រើនដែរ ក្នុងនាមជាសេនាធិការ ដែលជួយសម្រួលរាល់ការរៀបចំនូវឯកសារដែលពាក់ព័ន្ធនានាជូនតុលាការ និងការកត់នូវចំណុចសំខាន់ៗនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រហូតដល់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់។ ដូច្នេះហើយ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីមុនពេលសវនាក៏មានសារៈសំខាន់ដែរ មុននឹងឈានដល់ការបើកសវនាការ។ ចំពោះនីតិវិធីត្រៀមនៃការទាញហេតុផលដោយផ្ទាល់មាត់ គឺក្រឡាបញ្ជីត្រូវកត់ត្រារាល់សេចក្ដីថ្លែងការណ៍របស់គូភាគី ក្នុងពេលតុលាការធ្វើការផ្សះផ្សាគ្នា និងរកនូវចំណុចវិវាទនៃរឿងក្ដីដើម្បីជួយសម្រួលដល់ការវិនិច្ឆ័យច្បាប់របស់អង្គការតុលាការ។ ម៉្យាងទៀត ដើម្បីឱ្យគូភាគីទាំងសងខាងបានចូលឆ្លើយបញ្ជាក់នូវអង្គហេតុតទល់គ្នាដើម្បីដាក់បន្ទុក ឬដោះបន្ទុកជាដើម។ ហើយនៅដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការវិនិច្ឆ័យដែលតាមរយៈសកម្មភាពរបស់តុលាការ និងភាគីដែលទាក់ទងនឹងការជំនុំជម្រះលើបណ្ដឹង ជាពិសេស ការធ្វើសេចក្ដីថ្លែងការណ៍របស់គូភាគី និងការពិនិត្យភស្តុតាង ត្រូវធ្វើឡើងដោយសេចក្ដីថ្លែងការណ៍ដោយផ្ទាល់មាត់ និងការស្ដាប់សេចក្ដីថ្លែងការណ៍នោះក្នុងសវនាការសាធារណៈនៅកាលបរិច្ឆេទដែលគូភាគីអាចចូលរួមបាន។ គោលការណ៍នៃការជម្រះ

ក្តីតាមវិធាននៃការទាញហេតុផលដោយផ្ទាល់មាត់បែបនេះ គេហៅថា គោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់។

ជារួមមក យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈនៃក្រឡាបញ្ជី ច្បាប់ស្តីពីការរៀបចំអង្គការតុលាការនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់មួយចំនួនទៀតដែលបានបង្ហាញយ៉ាងច្បាស់ និងស៊ីសង្វាក់អំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី។

សរុបសេចក្តីមក តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីសវនាការ ក្នុងរឿងក្តីរដ្ឋប្បវេណី ពិតជាមានភាពចាំបាច់បំផុតសម្រាប់តុលាការក៏ដូចជាគូភាគី ដែលក្រឡាបញ្ជីចាំបាច់កត់ត្រានូវកំណត់ហេតុផ្សេងៗ និងរាល់ការអះអាងរបស់ភាគី ឬជាការលើកឡើងរបស់អ្នកតំណាងរបស់ភាគី និងសាក្សីជាដើម ដែលកំណត់ហេតុរបស់ក្រឡាបញ្ជីសវនាការនោះ ជាមូលដ្ឋានដ៏សំខាន់របស់គូភាគីដែលលើកឡើង និងជាមូលដ្ឋានដ៏សំខាន់សម្រាប់តុលាការរដ្ឋប្បវេណីចេញសម្រេចសេចក្តី ដែលហៅថា សាលក្រម។ ម្យ៉ាងទៀត អ្វីដែលសំខាន់នោះ គឺក្រឡាបញ្ជីសវនាការត្រូវមានភារកិច្ចចាំចាច់ និងសម្រាប់ការឱ្យចូលជាស្ថាពរនៃសេចក្តីសម្រេច ដែលហៅថា សាលក្រមនោះ ក៏ដូចជាការផ្តល់នូវរូបមន្តសម្រាប់ការអនុវត្តនៃសេចក្តីសម្រេច (សាលក្រម) សម្រាប់ឱ្យគូភាគីនៃរឿងក្តីអាចយកទៅអនុវត្តត្រឹមត្រូវតាមច្បាប់បាន។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់នូវការសិក្សាស្រាវជ្រាវ និងធ្វើការស្វែងយល់អំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី កន្លងមកនេះ យើងដឹងហើយថា ក្រឡាបញ្ជី គឺជាមន្ត្រីរាជការស៊ីវិលដែលស្ថិតក្នុងក្របខណ្ឌនៃក្រសួងយុត្តិធម៌ ដែលមានតួនាទីជាជំនួយរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមនៅគ្រប់ដំណាក់កាលនៃរឿងក្តី។ ប៉ុន្តែ នៅមានចំណុចមួយចំនួនដែលមិនបានផ្តល់ជាលក្ខណៈងាយស្រួលចំពោះក្រឡាបញ្ជីឡើយ ថ្វីត្បិតតែគាត់ជាបុគ្គលដែលសំខាន់នៅគ្រប់ដំណាក់កាលនៃនីតិវិធីរឿងក្តី ជាពិសេស គឺនៅដំណាក់កាលសវនាការនេះតែម្តង។ ទោះយ៉ាងណាបច្ចុប្បន្ននេះ តួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីមិនទាន់មានបទបញ្ញត្តិ ឬច្បាប់ណាមួយជាក់លាក់នៅឡើយទេ ដោយរាជរដ្ឋាភិបាលទើបតែចេញនូវសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជីបានចំនួន ២ ដង តែប៉ុណ្ណោះ គឺនៅឆ្នាំ២០១២ និងឆ្នាំ២០១៦ ហេតុនេះហើយ រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ ជម្រុញ និងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជីឱ្យបានឆាប់រហ័ស និងគួរតែសិក្សាស្វែងយល់នូវផលវិបាករបស់ក្រឡាបញ្ជីដែលទាក់ទងនឹងការអនុវត្តតួនាទី និងភារកិច្ចចំពោះការអនុវត្តជាក់ស្តែងនៅតាមសាលាដំបូងរាជធានី-ខេត្ត។

ក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់ខ្លួន ក្រឡាបញ្ជី ត្រូវមានឯករាជ្យភាព សុក្រឹត្យ គោរពគោលការណ៍ ការណែនាំ និងសម្បជញ្ញៈរបស់ខ្លួន។ ការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីសព្វថ្ងៃនេះ គឺអាស្រ័យលើការដឹកនាំ និងត្រួតពិនិត្យរបស់ចៅក្រម។ ក្នុងន័យនេះ ដើម្បីឱ្យការអនុវត្តត្រឹមត្រូវតាមវិជ្ជាជីវៈរបស់ខ្លួនរាជរដ្ឋាភិបាលគួរគប្បីបង្កើតនូវច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ដើម្បីឱ្យក្រឡាបញ្ជីបានដឹងអំពីតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានជាក់លាក់ ដើម្បីបង្កើនភាពងាយស្រួលក្នុងការអនុវត្តកាតព្វកិច្ចដោយយុត្តិធម៌។ ម្យ៉ាងទៀត បច្ចុប្បន្ននេះ សំណុំរឿងនៅតាមបណ្តាលអយ្យការអមសាលាដំបូងមានចំនួនច្រើន ចំណែកឯក្រឡាបញ្ជី ក៏ពុំទាន់មានតួនាទី និងភារកិច្ចច្បាស់លាស់នៅឡើយទេដែលជាហេតុធ្វើឱ្យចំណាត់ការនៃរឿងក្តីមានភាពយឺតយ៉ាវ និងកកស្ទះ។ ដូច្នេះហើយ រាជរដ្ឋាភិបាលគួរតែកែសម្រួលនូវចំណុចនេះផងដើម្បីបំពេញនូវចំណុចខ្វះខាត និងអនុម័តទៅលើសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី ព្រមទាំងលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលឆ្លុះបញ្ចាំងអំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី។

ជាពិសេស គឺត្រូវយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពរបស់ក្រឡាបញ្ជី ព្រមទាំងបើកឱកាសឱ្យបានទូលំទូលាយក្នុងការប្រឡងជ្រើសរើសឱ្យចូលប្រកបវិជ្ជាជីវៈជាក្រឡាបញ្ជី ដើម្បីបង្គ្រប់តាមតម្រូវការសម្រាប់បំពេញនូវភាពខ្វះខាតរបស់ក្រឡាបញ្ជី និងជួយកាត់បន្ថយនូវការកកស្ទះនៃរឿងក្តី ព្រមទាំងបច្ចេកទេសក្នុងការអនុវត្តច្បាប់មានភាពល្អប្រសើរនៅពេលមានសវនាការម្តងៗ ដែលប្រកបដោយតម្លាភាព សុក្រឹត្យ និងយុត្តិធម៌។ ក្រៅពីអ្វីដែលបានរៀបរាប់ខាងលើនេះ យើងបានមើលឃើញថា ចំពោះការអនុវត្តបច្ចុប្បន្ន ការងារមួយចំនួនពុំ

មែនជាតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីឡើយ ក៏ប៉ុន្តែ ក្រឡាបញ្ជីត្រូវតែអនុវត្តជាដាច់ខាតដូចករណីដែលបានរៀបរាប់រួមមាន៖ ការធ្វើសៀវភៅចុះសំណុំរឿង ការថែរក្សាសំណុំរឿង ការរៀបចំបន្ទប់សវនាការ កិច្ចការមួយចំនួនទៀតដែលសូម្បីតែច្បាប់ស្តីពីលក្ខន្តិកៈក្រឡាបញ្ជី និងក្រមនីតិវិធីរដ្ឋប្បវេណីក៏ពុំបានបញ្ជាក់ថា ជាតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីឡើយតែក្រឡាបញ្ជីមានសិទ្ធិអនុវត្តដដែលក្នុងនោះរួមមាន៖ ការធ្វើបញ្ជីវត្តមានអ្នកពាក់ព័ន្ធនៅដំណាក់ត្រៀមការទាញហេតុផល និងដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់ ដែលហៅថាសវនាការ ការដឹកនាំអ្នកពាក់ព័ន្ធចូលបន្ទប់សវនការ។ ដូចដែលបានរៀបរាប់ខាងលើនេះ រាជរដ្ឋាភិបាលគួរកែតម្រូវតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីដើម្បីកាន់បន្ថយនូវតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី។

ដូច្នេះហើយ រាជរដ្ឋាភិបាលគួរបែងចែកឱ្យបានច្បាស់អំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជី និងកែប្រែទម្រង់នៃការអនុវត្តច្បាប់របស់ក្រសួងយុត្តិធម៌ និងគួរបង្កើតច្បាប់ និងចេញសេចក្តីអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈរបស់ក្រឡាបញ្ជីឱ្យបានច្បាស់លាស់អំពីតួនាទី និងភារកិច្ចរបស់ក្រឡាបញ្ជីជុំវិញនីតិវិធី និងដំណើរការនៃរឿក្តីផងដែរ។

# ឯកសារយោង

# ឯកសារយោង

**១. កម្រងឯកសារច្បាប់**

- ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែករបស់ក្រឡាបញ្ជី ឆ្នាំ២០១២
- សេចក្ដីព្រាងច្បាប់ស្ដីពីលក្ខន្តិកៈក្រឡាបញ្ជី ឆ្នាំ២០១៦
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

**២. កម្រងឯកសារមេរៀន**

- សៀវភៅអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀបរបស់លោក **កុយ នាម** និងលោក **ឡុង បញ្ញាវុធ** ឆ្នាំ ២០០៦
- បទបង្ហាញស្ដីពីវិជ្ជាជីវៈក្រឡាបញ្ជី និងវិធីសាស្ត្រនៃការត្រៀមប្រឡងវិជ្ជាជីវៈតុលាការរបស់លោក **មួង សេងលី** ឆ្នាំ២០១៦
- សៀវភៅវិធានផ្ទៃក្នុងវិសោធនកម្ម ឆ្នាំ២០០៩ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- វចនានុក្រមសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ឆ្នាំ១៩៦៧

**៣. កម្រងឯកសារជាក់ស្ដែងនៅសាលាដំបូង**

- បង្កាន់ដៃបង់ប្រាក់
- ដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដី
- ដីកាកោះហៅ
- កំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផល
- កំណត់ហេតុស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់

សាលក្រម......។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

| ល.រ | បញ្ជីរាយលិខិត | ចំនួន |
|---|---|---|
| **គំរូឧបសម្ព័ន្ធ** | | |
| ឧបសម្ព័ន្ធទី១ | សេចក្តីជូនដំណឹងរបស់រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ | ១ ច្បាប់ |
| **ឧបសម្ព័ន្ធមុនពេលសវនាការ** | | |
| ឧបសម្ព័ន្ធទី២ | ពន្ធដាក់ពាក្យសុំ | ១_ |
| | ពាក្យបណ្តឹង | ១_ |
| | ភស្តុតាងជាឯកសារ | ១_ |
| ឧបសម្ព័ន្ធទី៣ | លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ | ១_ |
| | លិខិតតំណាងដោយអាណត្តិ | ១_ |
| ឧបសម្ព័ន្ធទី៤ | ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ | ១_ |
| | របាយការណ៍បញ្ជូន | ១_ |
| **ឧបសម្ព័ន្ធនៅដំណាក់កាលនៃនីតិវិធីត្រៀមការទាញហេតុផល** | | |
| ឧបសម្ព័ន្ធទី៥ | ដីកាកោះហៅ (ត្រៀម) | ១_ |
| | របាយការណ៍បញ្ជូន | ១_ |
| | លិខិតអញ្ជើញមេធាវី | ១_ |
| ឧបសម្ព័ន្ធទី៦ | បញ្ជីវត្តមាន | ១_ |
| | កំណត់ហេតុស្តីពីនិតិវិធីត្រៀមសម្រាប់ការទាញហេតុផល | ១_ |
| | របាយការណ៍បញ្ជូន (ការផ្ញើកំណត់ហេតុ) | ១_ |
| **ឧបសម្ព័ន្ធនៅដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់** | | |
| ឧបសម្ព័ន្ធទី៧ | ដីកាកោះហៅ (ទាញ) | ១_ |
| | របាយការណ៍បញ្ជូន | ១_ |
| | លិខិតអញ្ជើញមេធាវី | ១_ |
| ឧបសម្ព័ន្ធទី៨ | បញ្ជីវត្តមាន | ១_ |
| | កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ | ១_ |
| | របាយការណ៍បញ្ជូន (ការផ្ញើកំណត់ហេតុ) | ១_ |
| ឧបសម្ព័ន្ធទី៩ | សាលក្រម | ១_ |
| | អនុសារៈសាលក្រម | ១_ |
| | របាយការណ៍បញ្ជូន | ១_ |
| ឧបសម្ព័ន្ធទី១០ | លិខិតបញ្ជាក់ការចូលជាស្ថាពរ | ១_ |

| | | |
|---|---|---|
| | លិខិតសុំរូបមន្តអនុវត្ត | ១_ |
| ឧបសម្ព័ន្ធទី១១ | ដីកាបញ្ជូនសំណុំរឿង | ១_ |

# ឧបសម្ព័ន្ធទី១
# សេចក្ដីជូនដំណឹងរាជ
# បណ្ឌិសភាពវិជ្ជាជីវៈតុលាការ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
លេខ: ២៥៩/២៣/រ.ប.វ.ត

# សេចក្តីជូនដំណឹង

បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា (អតីតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ) សូមជម្រាបជូន និស្សិត និងមន្ត្រីរាជការទាំងពីរភេទ មេត្តាជ្រាបថា៖ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ចាប់ផ្តើមទទួលពាក្យសុំប្រឡងប្រជែងជ្រើសរើសសិស្សក្រឡាបញ្ជី ជំនាន់ទី៩ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ **ចាប់ពីថ្ងៃចន្ទ ទី១០ ខែមេសា ឆ្នាំ២០២៣ តទៅ។**

លក្ខខណ្ឌសម្រាប់បេក្ខជន ដាក់ពាក្យស្នើសុំចូលរួមប្រឡងប្រជែងជ្រើសរើសសិស្សក្រឡាបញ្ជី ជំនាន់ទី ៩ មានដូចខាងក្រោម៖

១- ត្រូវមានសញ្ជាតិខ្មែរពីកំណើត
២- ត្រូវមានអាយុ ៣០ (សាមសិប) ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជានិស្សិត និងមានអាយុ ៣៥ (សាមសិបប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង
៣- ត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (Bac II)
៤- ត្រូវមានសញ្ញាបត្របញ្ជាក់បញ្ចប់ការសិក្សាឆ្នាំទី ២ ឡើងទៅ ផ្នែកនីតិសាស្ត្រ ឬបរិញ្ញាបត្ររងនៅមហាវិទ្យាល័យដែលមានកម្មវិធីសិក្សាសមមូល (ដោយភ្ជាប់មកជាមួយនូវព្រឹត្តិប័ត្រពិន្ទុពាក់ព័ន្ធ) ឬបរិញ្ញាបត្រនីតិសាស្ត្រ
៥- មិនដែលមានទោសពីបទមជ្ឈិម និងបទឧក្រិដ្ឋ
៦- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។

និស្សិត និងមន្ត្រីរាជការដែលមានចំណាប់អារម្មណ៍ សូមទាញយកពាក្យសុំចូលរួមប្រឡងប្រជែងជ្រើសរើសសិស្សក្រឡាបញ្ជី ជំនាន់ទី ៩ ពីទំព័រហ្វេសប៊ុក **"បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា Royal Academy for Justice of Cambodia"** ដើម្បីបំពេញបែបបទ និងអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ **នៅការិយាល័យរដ្ឋបាល នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ដែលមានទីតាំងឋិតនៅមហាវិថី ឈ្នះឈ្នះ ភូមិព្រែកតាឡែ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ** នៅរៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម និស្សិត និងមន្ត្រីរាជការទាំងអស់ជ្រាបជាព័ត៌មាន។

*បញ្ជាក់៖ បេក្ខជនទាំងពីរភេទ ដែលជាប់កាតព្វកិច្ចក្នុងកិច្ចសន្យា ស្តីពីការបំពេញមុខងារវិជ្ជាជីវៈជាមួយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មិនអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងឡើយ។

ថ្ងៃចន្ទ ៥ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០២៣
**រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ**

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងទូរស័ព្ទលេខ៖
០៩៣ ៥៤៤ ៧៨៦
០១១ ៥៧៦ ៧០០
០៩២ ៦៥២ ៨៥៦

# ឧបសម្ព័ន្ធទី២
# ឯកសារមុនពេលសវនាការ

# ពន្ធដាក់ពាក្យសុំ

ក្រសួងយុត្តិធម៌

កំរូលេខ 09 សហវ/ចមក

260-1- 00367164

MEF20882604121

## បង្កាន់ដៃបង់ប្រាក់

(ភ្ជាប់សំណុំរឿង)

អង្គភាព [illegible]

ទទួលពី ........ អង្គភាព [illegible]

ចំនួនទឹកប្រាក់ជាលេខ [illegible]

ជាអក្សរ [illegible]

អត្ថន័យចំណូល [illegible] មាតិកាថវិកា ........

[illegible] ថ្ងៃទី 17 ខែ 10 ឆ្នាំ 2023

អ្នកប្រមូលចំណូល

MINISTRY OF ECONOMY AND FINANCE

Scanned with CamScanner

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

Scanned with CamScanner

# ពាក្យបណ្តឹង

សាលាដំបូងខេត្តកណ្តាល
ប៉ុស្ដិ៍
សំណុំរឿងរដ្ឋប្បវេណី
លេខៈ 1190
ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

សហដើមចោទ: ឈ្មោះ ភេទប្រុស អាយុ៥៣ឆ្នាំ និងប្រពន្ធឈ្មោះ ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីលំនៅសព្វថ្ងៃ ភូមិកោក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល ។

ចុងចម្លើយ: ឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ និងប្រពន្ធឈ្មោះ ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិកោក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល ។

សូមគោរពចូលមក
ឯកឧត្តមប្រធានសាលាដំបូងខេត្តកណ្តាល

*សូមទានជ្រាប។*

**កម្មវត្ថុ:** ទាមទារប្រាក់ចំនួន ៧,៤០០ (ប្រាំពីរពាន់បួនរយ)ដុល្លារអាមេរិច ។

**ទី១.សាលក្រមដែលទាមទារដោយសហដើមចោទ:**

សហដើមចោទទាមទារឲ្យតុលាការចេញសាលក្រមសម្រេចដែលមានខ្លឹមសារដូចតទៅ៖

១.ឲ្យសហចុងចម្លើយសងប្រាក់ដើមដែលបានខ្ចីចំនួន ៧,៤០០ (ប្រាំពីរពាន់បួនរយ)ដុល្លារអាមេរិច មកឲ្យដើមចោទវិញ ។ ៧០០០

២.ឲ្យសហចុងចម្លើយសងការប្រាក់១៨%ក្នុង១ឆ្នាំ និងការប្រាក់យឺតយ៉ាវ១៨%ក្នុង១ឆ្នាំ លើប្រាក់ដើមចំនួន៧,៤០០(ប្រាំពីរពាន់បួនរយ)ដុល្លារអាមេរិចមកឲ្យដើមចោទ គិតពីពេលបានខ្ចី ចាប់ពីថ្ងៃទី០២ -៧-២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន ។

៣.ឲ្យសហចុងចម្លើយសង ជម្ងឺចិត្ត ការខាតបង់ពេលវេលា ថ្លៃសេវាផ្នែកច្បាប់ និងការចំណាយផ្សេងៗ ចំនួន ២០ ០០០ ០០០ (ម្ភៃលាន)រៀល មកឲ្យដើមចោទ ។

៤.ប្រកាសសាលក្រមនេះ អាចអនុវត្តបណ្តោះអាសន្នបាន ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

**ទី២.អង្គហេតុដែលជាមូលហេតុនៃការទាមទារ:**

កាលពីថ្ងៃទី០២ -៧-២០២១ សហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ បានខ្ចីប្រាក់ពីសហដើមចោទឈ្មោះ និងប្រពន្ធឈ្មោះ ចំនួន ៧,៤០០ (ប្រាំពីរពាន់បួនរយ)ដុល្លារអាមេរិច ដោយបានព្រមព្រៀងបង់ការប្រាក់៥%ក្នុង១ខែ ។ ប៉ុន្តែចាប់តាំងពីថ្ងៃខ្ចីរហូតមកដល់បច្ចុប្បន្ននេះ សហចុងចម្លើយពុំដែលបានបង់ការប្រាក់មកឲ្យដើមចោទទាល់តែសោះ ហើយក៏មិនព្រមសងប្រាក់ដើមឲ្យដើមចោទផងដែរ ទោះបីសហដើមចោទព្យាយាមសម្រុះសម្រួល នៅសាលាឃុំ ក៏ដូចជាមេភូមិ យ៉ាងណាក៏ដោយ ក៏សហចុងចម្លើយឈ្មោះ និងប្រពន្ធឈ្មោះ ព្យាយាមគេចវេសនិងមិនព្រមសងដែរ ។

Scanned with CamScanner

៩៣.<u>ភស្តុតាងបញ្ជាក់:</u>(ច្បាប់ថតចម្លង)

-កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០២-៧-២០២១ ។

-កិច្ចសន្យាទទួលស្គាល់ថាបានខ្ចីប្រាក់កាលពីថ្ងៃទី០២-៧-២០២១ ដែលបានធ្វើជាមួយមេភូមិ ចុះថ្ងៃទី២៩-វិច្ឆិកា-២០២២ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឈ្មោះ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឈ្មោះ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឈ្មោះ ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឈ្មោះ ។

អាស្រ័យហេតុនេះសូម ឯកឧត្តមប្រធាន មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តមប្រធាន ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ថ្ងៃ..ច័ន្ទ..១៣.កើត...... ខែ..អស្សុជ........ ឆ្នាំថោះ បញ្ចស័កព.ស២៥៦៧

ធ្វើនៅកណ្ដាល, ថ្ងៃទី២៧.. ខែ..តុលា.... ឆ្នាំ២០២៣

ស្នាមមេដៃស្តាំ



Scanned with CamScanner

# ភស្តុតាងជាឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

+ + + + + + + + + +

## កិច្ចសន្យាខ្ចីប្រាក់

- ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ភេទប្រុស អាយុ 40 ឆ្នាំ និងប្ដី ឬប្រពន្ធឈ្មោះ អាយុ 36 ឆ្នាំ ដែលមានទីលំនៅភូមិ [illegible] ឃុំ [illegible] ស្រុក [illegible] ខេត្តកណ្ដាល
- បានខ្ចីប្រាក់ពីឈ្មោះ ភេទប្រុស អាយុ 54 ឆ្នាំ នៅភូមិ [illegible] ឃុំ [illegible] ស្រុក [illegible] ខេត្តកណ្ដាល ចំនួន 7400$ [illegible] ប្រាំពីរពាន់បួនរយដុល្លារ ។
- ក្នុងនោះ ខ្ញុំបាទ/នាងខ្ញុំ សូមដាក់បញ្ចាំ សំភារៈជាភស្តុតាងគឺ

- យកប្រាក់នៅថ្ងៃទី 02 ខែ 7 ឆ្នាំ 2021 [illegible] 1 ខែទៀត
- ហើយកំណត់យកប្រាក់មកសងវិញនៅថ្ងៃទី 10 ឆ្នាំ 200 [illegible]
- ចំនួនទឹកប្រាក់បង់ការប្រាក់រយៈពេល គឺ
- បើសិនដល់ថ្ងៃកំណត់ហើយ ខ្ញុំបាទ/នាងខ្ញុំ មិនបានយកមកសងលោកឈ្មោះ វិញទេ ខ្ញុំបាទ/នាងខ្ញុំ សូមប្រគល់ [illegible] ទាំងអស់ [illegible]

ម្ចាស់បំណុលឈ្មោះ ដោយគ្មានប្រកែកតវ៉ាអ្វីឡើយ ។
- ដើម្បីជាប្រាកដ ខ្ញុំបាទ/នាងខ្ញុំ សូមផ្តិតមេដៃស្តាំទុកជាភស្តុតាងនៅពីក្រោមលិខិតនេះ [illegible] ពេលនោះ ខ្ញុំបាទ/នាងខ្ញុំ មានសាក្សីស្គាល់ [illegible] ។

ស្នាមមេដៃស្ដាំសាក្សី | ស្នាមមេដៃស្តាំអ្នកខ្ចីប្រាក់ | ស្នាមមេដៃស្ដាំម្ចាស់ប្រាក់

ឈ្មោះ: | ឈ្មោះ: | ឈ្មោះ:



Scanned with CamScanner
Scanned with CamScanner

# ឧបសម្ព័ន្ធទី៣
# ករណីដើមចោទពឹងពាក់មេធាវី

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ៥៣ឆ្នាំ និងប្រពន្ធឈ្មោះ ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីលំនៅសព្វថ្ងៃ ភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្ដាល ។

### សូមប្រគល់សិទ្ធិជូន

អ្នកស្រីមេធាវី អត្តលេខ មានការិយាល័យ ផ្ទះលេខ១៧ ផ្លូវលេខ៦ ភូមិទួលរកាព៣ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិរបស់ខ្ញុំនិងធ្វើការអាណត្តិនូវកិច្ចការដូចជា៖( - ☑ យល់ព្រម - ☒ មិនយល់ព្រម)

☑ ធ្វើសកម្មភាពតំណាង ,☑ ដាក់ពាក្យបណ្ដឹង ឬ បណ្ដឹងតប , ☑ ការដកពាក្យបណ្ដឹង, ☑ ការផ្សះផ្សា,☑ ការទាមទារ , ☑ ការដកខ្លួនចេញពីបណ្ដឹង , ☑ ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ,☐ដាក់ពាក្យបណ្ដឹងទាស់ , ☐ ដាក់ពាក្យបណ្ដឹងជំទាស់ , ☐ ដាក់ពាក្យបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ១.១.៩.០. ចុះថ្ងៃទី១៧....ខែតុលា.... ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្ដាល ។

បញ្ជាក់ៈសោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗនៅក្នុងបណ្ដឹងនេះ ជាបន្ទុករបស់យើងខ្ញុំ(អាណត្តិទាយក) ។ ក្នុងករណីមិនបានគោរពនូវកាតព្វកិច្ចនេះ យើងខ្ញុំ(អាណត្តិទាយក)សុខចិត្តទទួលខុសត្រូវនូវរាល់ការខាតបង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់ ។

អ្នកស្រីមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអនុវត្តនូវកិច្ចការអាណត្តិតាមច្បាប់ដែលអាណត្តិទាយកបានប្រគល់ជូនដូចខាងលើចាប់ពីថ្ងៃផ្ដិតមេដៃ ឬចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១០..ខែ.តុលា.....ឆ្នាំ២០២៣

ស្នាមមេដៃស្ដាំអ្នកប្រគល់សិទ្ធិ



បានឃើញនិងយល់ព្រម
ធ្វើមេធាវីតំណាងដោយអាណត្តិឲ្យ
ឈ្មោះ និងប្រពន្ធឈ្មោះ
ថ្ងៃ... ខែ... ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
...ថ្ងៃទី១០... ខែតុលា.. ឆ្នាំ២០២៣
មេធាវី
មេធាវី.

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

Scanned with CamScanner

# លិខិតតំណាងដោយអាណត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
ចូល លេខ: 2142
ថ្ងៃទី 31 ខែ 10 ឆ្នាំ 2023
ម៉ោង 9 និង 45 នាទី

ការិយាល័យមេធាវី

TOP CHHUNLENG
LAW OFFICE

**លិខិតតំណាងដោយអាណត្តិ**

នាងខ្ញុំមេធាវី ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ: ។

**សូមគោរពជូនមក**

**លោកចៅក្រមសាលាដំបូងខេត្តកណ្ដាល**

*សូមជ្រាប។*

**កម្មវត្ថុ:** ស្ដីពីមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ និងប្រពន្ធឈ្មោះ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ១១៩០ ចុះថ្ងៃទី១៧-១០-២០២៣ របស់សាលាដំបូងខេត្តកណ្ដាល ។

**យោង:** -ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។
-លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិរបស់ឈ្មោះ និងប្រពន្ធឈ្មោះ ចុះថ្ងៃទី៣០-១០-២០២៣ ។

តាមកម្មវត្ថុ និងយោងខាងលើនាងខ្ញុំសូមជម្រាបជូន លោកចៅក្រម មេត្តាជ្រាបថា: កូនក្ដីឈ្មោះ , និងប្រពន្ធឈ្មោះ បានប្រគល់សិទ្ធិឲ្យនាងខ្ញុំដើម្បីធ្វើជាមេធាវីតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ១១៩០ ចុះថ្ងៃទី ១៧-១០-២០២៣ របស់សាលាដំបូងខេត្តកណ្ដាល ។

អាស្រ័យហេតុនេះ សូម លោកចៅក្រម មេត្តាជ្រាបតាមនីតិវិធីច្បាប់ចាប់ពីពេលនេះតទៅ។

សូម លោកចៅក្រម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃច័ន្ទ ១រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០២៣
មេធាវី

AVOCAT ATTORNEY AT LAW
KINGDOM OF CAMBODIA

មេធាវី

អាសយដ្ឋាន ផ្ទះលេខ17B ផ្លូវ 06 ភូមិទួលគោក3 សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទូរស័ព្ទ 017 55 48 79
Address: #17B, St.06, Tuolroka 3 Village, Sangkat Chakangrekroun, Khan Meanchey, Phnom Penh Tel:......................

Scanned with CamScanner

# ឧបសម្ព័ន្ធទី៤
# ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ

# ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
គុណភាពរដ្ឋប្បវេណី បន្ទប់ "ថ"
លេខ ៩៣៣ រ.ឋ/២៣

## ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

យើង ទ៉ាន់ សុបញ្ញា ចៅក្រមសាលាដំបូងខេត្តកណ្តាល

- បានឃើញ មាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១១៩០ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្តាល ដែលមាន៖

ក .អត្តសញ្ញាណភាគី

សហដើមចោទ៖ ឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៧០ (អាយុ៥៣ ឆ្នាំ) និងប្រពន្ធឈ្មោះ ភេទស្រី កើតឆ្នាំ១៩៦៨ (អាយុ ៥៥ ឆ្នាំ) ជនជាតិ ខ្មែរ។

ទីលំនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

សហចុងចម្លើយ៖ ឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៨៣ (អាយុ ៤០ ឆ្នាំ) និងប្រពន្ធឈ្មោះ ភេទស្រី កើតឆ្នាំ ១៩៨៥ (អាយុ៣៨ ឆ្នាំ) ជនជាតិ ខ្មែរ។

ទីលំនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

ខ. សញ្ញាណនៃរឿងក្តី៖ សុំឱ្យចុងចម្លើយសងប្រាក់។

### សំអាងហេតុ

យល់ឃើញថា ដើម្បីអាចឱ្យតុលាការដំណើរការសកម្មភាពក្នុងនីតិវិធីតាមបណ្តឹងរដ្ឋប្បវេណី តាមមាត្រា ៦២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការនឹងកំណត់អំពីចំនួនទឹកប្រាក់ចាំបាច់ ដែលតម្រូវឱ្យភាគីបង់ជាមុនសម្រាប់សកម្មភាពទាំងនោះ តាមមាត្រា ៦២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### សេចក្តីសម្រេច

បង្គាប់ឱ្យអ្នកដាក់ពាក្យសុំឈ្មោះ និងប្រពន្ធឈ្មោះ ដូចមានអត្តសញ្ញាណខាងលើ បង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ចំនួន ១២០.០០០ (ដប់ពីរម៉ឺន) រៀល នៅសាលាដំបូងខេត្តកណ្តាល គិតចាប់ពីថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ថ្ងៃទី ..៣១..... ខែ ..វិច្ឆិកា........ ឆ្នាំ២០២៣ ។

បង់រួច 08.11.2023

ថ្ងៃ ពុធ ០៣រោច ខែអស្សុជ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧
ខេត្តកណ្តាល ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣
ចៅក្រម

ទ៉ាន់ សុបញ្ញា

Scanned with CamScanner

# របាយការណ៍បញ្ជូន

## ( ឯកសារគំរូ )

### របាយការណ៍អំពីការបញ្ជូនឯកសារ

-ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី:

ក-កាលបរិច្ឆេទចេញ: ថ្ងៃទី ______ ខែ ___________ ឆ្នាំ ២០២៤
សំណុំរឿងរដ្ឋប្បវេណីលេខ __________ ចុះថ្ងៃទី _____ ខែ _______ ឆ្នាំ ២០២៤
ឈ្មោះឯកសារចេញ: ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រឆាំងក្តីក្រៅពីពន្ធលេខ _______ /២៤
ចុះថ្ងៃទី ______ ខែ __________ ឆ្នាំ ២០២៤
អ្នកទទួលបន្ទុកកិច្ចការបញ្ជូនឯកសារនេះគឺ: លោក ឃ្លាយ ឃី
អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងខេត្តកណ្តាល
លោក/លោកស្រីដែលត្រូវទទួលឯកសារបញ្ជូនទៅ: ឈ្មោះ ____________________ ។

ខ-ហត្ថលេខាឬស្នាមមេដៃអ្នកទទួលឯកសារនាក់ព័ន្ធ ______________________________

-ប្រអប់ខាងក្រោមត្រូវបំពេញដោយប្រតិបត្តិការបញ្ជូន (កន្លាប្រៃសណីយ៍, អាជ្ញាសាលា ឬក្រឡាបញ្ជី)។

ក
ទីកន្លែងធ្វើការបញ្ជូនទៅ: ភូមិ ___________ ឃុំ ____________ ស្រុក __________ ខេត្តកណ្តាល។
កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី ____ ខែ ______ ឆ្នាំ ២០____ វេលាម៉ោង ____ ព្រឹក/រសៀល។

**វិធីសាក់ព័ន្ធក្នុងការបញ្ជូន**

ខ
[១] បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ ។
☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអក្សរ ។

ច
[២] បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យ ចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកត្រូវទទួលការបញ្ជូនដោយផ្ទាល់ នៅកន្លែងដែលត្រូវបញ្ជូននោះទេ។
☐ អ្នកបំរើ ☐ អ្នកស្មៀនដែលនៅធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ

ឆ
ឈ្មោះ ______________________________________________

[៣] ឯកសារត្រូវបានទុកនៅទីកន្លែងដែលធ្វើការបញ្ជូនទៅដោយហេតុថា: បុគ្គលខាងក្រោមនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។
☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ
☐ អ្នកនៅជាមួយ ☐ អ្នកស្មៀនដែលធ្វើការនៅទីនោះ

ឌ
ឈ្មោះ ______________________________________________

[៤] ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ

ឈ
[៥] ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅកន្លែងដែលត្រូវទទួលការបញ្ជូន ខ្ញុំមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលឯកសារនេះទេ។

ញ
កាលបរិច្ឆេទធ្វើរបាយការណ៍: ______________________________
ឈ្មោះនិងហត្ថលេខាអ្នកធ្វើរបាយការណ៍: ______________________________

CS Scanned with CamScanner

# ឧបសម្ព័ន្ធទី៥
# ឯកសារក្នុងដំណាក់កាល
# ត្រៀមសម្រាប់ការទាញហេតុផល

# ដីកាកោះហៅ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

តុលាការរដ្ឋប្បវេណី បន្ទប់ "ថ"

លេខ: 1044 ...រ.ប/២៣

## ដីកាកោះហៅ

យើង ទ៉ាន់ សុបញ្ញា ចៅក្រមសាលាដំបូងខេត្តកណ្តាល

អមដោយលោក ហួយ ហ៊ី ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១១៩០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្តាល ដែលមាន៖

ក. អត្តសញ្ញាណភាគី៖

សហដើមចោទ៖ ឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៧០ (អាយុ ៥៣ ឆ្នាំ) ជនជាតិខ្មែរ និងប្រពន្ធ ឈ្មោះ កើតនៅឆ្នាំ ១៩៦៨ ជនជាតិ ខ្មែរ។

ទីលំនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

សហចុងចម្លើយ៖ ឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៨៣ (អាយុ ៤០ ឆ្នាំ) ជនជាតិខ្មែរ និងប្រពន្ធ ឈ្មោះ កើតឆ្នាំ ១៩៨៥ (អាយុ ៣៨ ឆ្នាំ)។

ទីលំនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

ខ. សញ្ញាណនៃរឿងក្តី៖ ប្តឹងសុំឱ្យចុងចម្លើយសងប្រាក់។

គ. គោលបំណងនៃការកោះហៅ៖

អញ្ជើញ៖ ឈ្មោះ និងប្រពន្ធឈ្មោះ ដូចមានអត្តសញ្ញាណខាងលើ។

ឱ្យចូលមកកាន់ ៖ តុលាការរដ្ឋប្បវេណី នៃសាលាដំបូងខេត្តកណ្តាល បន្ទប់អក្សរ (ថ)

នៅថ្ងៃទី 11... ខែ 12......... ឆ្នាំ២០២៣ វេលាម៉ោង 9..... ព្រឹក☑ រសៀល☐។

ដើម្បីចូលរួម ៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល☑ នីតិវិធីនៃការសាកសួរ☐ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់☐ ការប្រកាសសាលក្រម☐។

សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងបានកំណត់ខាងលើនេះ។

ថ្ងៃ 22......10 កើត ខែ កត្តិក ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

ខេត្តកណ្តាល ថ្ងៃទី 22... ខែវិច្ឆិកា ឆ្នាំ២០២៣

ចៅក្រម

ទ៉ាន់ សុបញ្ញា



Scanned with CamScanner

# របាយការណ៍បញ្ជូន

## របាយការណ៍អំពីការបញ្ជូនឯកសារ

-ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី:

ក-កាលបរិច្ឆេទចេញ: ថ្ងៃទី ២២ ខែវិច្ឆិកាឆ្នាំ ២០២៣
សំណុំរឿងរដ្ឋប្បវេណីលេខ ០១៩០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០២៣
ឯកសារចេញ: ដីកាកោះលេខ ០០៥៨ វ.ម ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣
អ្នកទទួលបន្ទុកកិច្ចការបញ្ជូនឯកសារនេះគឺ: លោក ឃួយ ឃឿ
អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងខេត្តកណ្តាល
លោក/លោកស្រីដែលត្រូវទទួលឯកសារបញ្ជូនទៅ: ឈ្មោះ ______ និងប្រពន្ធឈ្មោះ ______

ខ-ហត្ថលេខាឬស្នាមមេដៃអ្នកទទួលឯកសារនៅកន្លែង ______

-ប្រអប់ខាងក្រោមត្រូវបំពេញដោយប្រតិបត្តិការបញ្ជូន (ភ្នាក់ងារប្រៃសណីយ៍, អាជ្ញាសាលា ឬក្រឡាបញ្ជី)។

គ ទីកន្លែងធ្វើការបញ្ជូនទៅ: ភូមិកាកក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។
កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី ____ ខែ វិច្ឆិកា ឆ្នាំ ២០២៣ វេលាម៉ោង ____ ព្រឹក/រសៀល។

វិធីដាក់កន្លែងក្នុងការបញ្ជូន

ឃ ☑ ១ បានប្រគល់ផ្ទាល់ជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ ។
☐ ខ្ញុំបានពន្យល់ផ្ទាល់ជនដែលត្រូវទទួលការបញ្ជូន ឱ្យចុះហត្ថលេខាសន្និដ្ឋានឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអក្សរ ។

ច ២ បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យ ចំពោះការទទួលឯកសារនេះ ពីព្រោះមិនបានជួបអ្នកត្រូវទទួលការបញ្ជូនដោយផ្ទាល់ នៅកន្លែងដែលត្រូវបញ្ជូននោះទេ។
☐ អ្នកបំរើ ☐ អ្នកស្មៀនដែលនៅធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ
ឈ្មោះ ______

ឆ ៣ ឯកសារត្រូវបានទុកនៅទីកន្លែងដែលធ្វើការបញ្ជូនទៅដោយហេតុថា: បុគ្គលខាងក្រោមនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។
☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ
☐ អ្នកនៅជាមួយ ☐ អ្នកស្មៀនដែលធ្វើការនៅទីនោះ
ឈ្មោះ ______

ជ ៤ ខ្ញុំបានបញ្ជូនឯកសារតាមវិធីផ្សេងខាងលើ

ឈ ៥ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅកន្លែងដែលត្រូវទទួលការបញ្ជូន ខ្ញុំមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលសារនេះទេ ។

ញ កាលបរិច្ឆេទធ្វើរបាយការណ៍: 04.12.23

ឈ្មោះនិងហត្ថលេខាអ្នកធ្វើរបាយការណ៍: ______

04 DEC 23
KANDAL CAMBODIA 080000

Scanned with CamScanner

# លិខិតអញ្ជើញមេធាវី

## (ឯកសារគំរូ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

**តុលាការរដ្ឋប្បវេណី បន្ទប់ "...."**

លេខ: ................. /២៤

**លិខិតអញ្ជើញមេធាវី**

យើង **ទ៉ាន់ សុបញ្ញា** ចៅក្រមសាលាដំបូងខេត្តកណ្ដាល
អមដោយលោក **ហួយ ហ៊ី** ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ............... ចុះថ្ងៃទី ......... ខែ ............. ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកណ្ដាល។

- បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី ........ ខែ ............ ឆ្នាំ២០២៤ របស់ ............................... ដែលតំណាងដោយអគ្គនាយកលោក .............................. មានលោក .................... អត្តលេខ ........... ជាមេធាវីតំណាងដោយអាណត្តិ។

**អញ្ជើញ** ៖ លោកមេធាវី .................... អត្តលេខ .........................។

**ការិយាល័យ** ៖ មានការិយាល័យនៅផ្ទះលេខ ........... ផ្លូវលេខ .......... សង្កាត់ ............. ខណ្ឌ ................. រាជធានីភ្នំពេញ។

**មកកាន់** ៖ សាលាដំបូងខេត្តកណ្ដាល មន្ទីរស៊ើបសួរ (ឈ) នៅថ្ងៃទី .......... ខែ ............ ឆ្នាំ ២០២៤ វេលាម៉ោង ................ និង ........ នាទី ព្រឹក☐ រសៀល☐។

**ដើម្បី** ៖ ចូលរួមការក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល☐ ការទាញហេតុដោយផ្ទាល់មាត់☐ នីតិវិធីនៃការសាកសួរ☐។

**រឿងក្ដី** ៖ ប្ដឹងទាមទារប្រាក់។

**ក្នុងឋានៈជា** ៖ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ☐ ចុងចម្លើយ☐។

លោក-លោកស្រីត្រូវតែអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ ............................... ខែ ................. ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨

ខេត្តកណ្ដាល ,ថ្ងៃទី ......... ខែ ............. ឆ្នាំ២០២៤

**ចៅក្រម**

Scanned with CamScanner

# ឧបសម្ព័ន្ធទី៦
# ឯកសារក្នុងអំឡុងពេល
# ត្រៀមសម្រាប់ការទាញហេតុផល

# បញ្ជីវត្តមាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

លេខ៖ ................/ឈ

## បញ្ជីរាយនាមជនជាប់ចោទ/ឆាក់ផិន

| ល.រ | ឈ្មោះ | ត្រូវជា | ផ្សេងៗ |
|---|---|---|---|
| ១ | | ([illegible]) | [illegible] |
| ២ | | ([illegible]) | |
| ៣ | | ([illegible]) | |
| ៤ | | | |
| ៥ | | | |
| ៦ | | | |
| ៧ | | | |
| ៨ | | | |
| ៩ | | | |
| ១០ | | | |
| ១១ | | | |
| ១២ | | | |

ថ្ងៃ .......................... ខែ ...[illegible]... ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧
ខេត្តកណ្ដាល, ថ្ងៃទី ..11..... ខែ ..[illegible].. ឆ្នាំ២០២៤.

ក្រឡាបញ្ជី

Scanned with CamScanner
Scanned with CamScanner

# កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

តុលាការរដ្ឋប្បវេណី បន្ទប់ "ម"

## កំណត់ហេតុ

## ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

| | | |
|---|---|---|
| កាលបរិច្ឆេទនៃនីតិវិធី | ៖ | ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ៩ និង ៣០ នាទី ព្រឹក។ |
| ទីតាំង | ៖ | បន្ទប់ "ឋ" នៃសាលាដំបូងខេត្តកណ្តាល។ |
| ចៅក្រមទទួលបន្ទុករឿងក្តី | ៖ | លោក ទ៉ាន់ សុបញ្ញា ចៅក្រមសាលាដំបូងខេត្តកណ្តាល |
| ក្រឡាបញ្ជីទទួលបន្ទុករឿងក្តី | ៖ | លោក ឡាយ ហ៊ី ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល |
| សំណុំរឿងរដ្ឋប្បវេណី | ៖ | លេខ ១១៩០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣។ |
| សញ្ញាណនៃរឿងក្តី | ៖ | ប្តឹងសុំទាមទារប្រាក់។ |

ក. អត្តសញ្ញាណភាគី

សហដើមចោទ៖

ឈ្មោះ ភេទ ប្រុស កើតនៅឆ្នាំ ១៩៧០ (អាយុ ៥៣ ឆ្នាំ) និងប្រពន្ធឈ្មោះ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

ទីលំនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

អ្នកតំណាងដោយអាណត្តិ៖ លោកស្រីមេធាវី តុប ឈុនឡេង អត្តលេខ ៦៧៧។

សហចុងចម្លើយ៖

ឈ្មោះ ភេទ ប្រុស កើតឆ្នាំ១៩៨៣ (អាយុ ៤០ ឆ្នាំ) និងប្រពន្ធឈ្មោះ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

ទីលំនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

អ្នកតំណាងដោយអាណត្តិ៖ គ្មាន។

ខ. ខ្លឹមសារនៃសាលក្រមដែលសហដើមចោទទាមទារឱ្យតុលាការចេញ៖

១. សុំទាមទារប្រាក់ដើម ចំនួន ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិក។

២. ទាមទារការប្រាក់ ១៨% ក្នុង ០១ ឆ្នាំ លើប្រាក់ដើម ចំនួន ៧៤០០ ដុល្លារអាមេរិក។

៣. ទាមទារការប្រាក់យឺតយ៉ាវ ១៨% ក្នុង ០១ ឆ្នាំ លើប្រាក់ដើម ចំនួន ៧៤០០ ដុល្លារអាមេរិក។

T. [illegible]

Scanned with CamScanner



Scanned with CamScanner

៤. សុំទាមទារសំណងជម្ងឺចិត្ត, ការខាតបង់ពេលវេលា, ថ្លៃសេវាផ្នែកច្បាប់ និងចំណាយផ្សេងៗ ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។

៥. ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់សហចុងចម្លើយ។

ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១. អំពីវត្តមានភាគី៖

- សហដើមចោទ៖ អវត្តមាន។

-មេធាវីរបស់ដើមចោទ៖ មានវត្តមាន។

- សហចុងចម្លើយ៖ មានវត្តមានប្រពន្ធឈ្មោះ ។

២. អំពីដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក. អំពីការផ្សះផ្សារ

តុលាការពុំបានលើកអំពីសំណើផ្សះផ្សារចំពោះភាគីទាំងសងខាងទេ ដោយសាររឿងក្ដីនេះ មិនអាចបើកកាលបរិច្ឆេទនៃការផ្សះផ្សារបាន។

ខ. អំពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល៖

ខ.១. ចំពោះការទាមទារ៖

១. សុំទាមទារប្រាក់ដើម ចំនួន ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិក។

២. ទាមទារការប្រាក់ ១៨% ក្នុង ០១ ឆ្នាំ លើប្រាក់ដើម ចំនួន ៧៤០០ ដុល្លារអាមេរិក។

៣. ទាមទារការប្រាក់យឺតយ៉ាវ ១៨% ក្នុង ០១ ឆ្នាំ លើប្រាក់ដើម ចំនួន ៧៤០០ ដុល្លារអាមេរិក។

៤. សុំទាមទារសំណងជម្ងឺចិត្ត, ការខាតបង់ពេលវេលា, ថ្លៃសេវាផ្នែកច្បាប់ និងចំណាយផ្សេងៗ ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។

សហដើមចោទ៖ នាងខ្ញុំជាមេធាវីតំណាងឱ្យសហដើមចោទ នៅតែរក្សាការទាមទារដូចការទារក្នុងពាក្យបណ្ដឹងរបស់កូនក្ដីនាងខ្ញុំ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ដដែល ដោយសារសហចុងចម្លើយបានខ្ចីប្រាក់ពីកូនក្ដីនាងខ្ញុំ កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ ចំនួន ៧៤០០ (ប្រពីរពាន់បួនរយ) ដុល្លារអាមរិក ដោយមានកិច្ចសន្យាជាលាយល័ក្ខអក្សរត្រឹមត្រូវ ហើយសហចុងចម្លើយនៅពុំទាន់បានសងប្រាក់ដើមឱ្យកូនក្ដីនាងខ្ញុំនៅឡើយ សូម្បីតែការប្រាក់ក៏សហចុងចម្លើយពុំដែលបានបង់ឱ្យកូនក្ដីនាងខ្ញុំមួយរៀលឡើយ កូនក្ដីនាងខ្ញុំព្យាយាមទាមទារយ៉ាងណា ក៏សហចុងចម្លើយខាងលើ តែងតែគេចវេះនិយាយដោះសាមិនព្រមសងជានិច្ច។

សហចុងចម្លើយ៖

ឈ្មោះ បានធ្វើសេចក្ដីថ្លែងការណ៍ថា៖ នាងខ្ញុំទទួលស្គាល់ថា នាងខ្ញុំពិតជាជំពាក់ប្រាក់សហដើមចោទឈ្មោះ ភេទ ប្រុស និងប្រពន្ធឈ្មោះ ចំនួន ៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកមែន តែមិនមែនជំពាក់ដល់ ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិកទេ ហើយកន្លងមកខ្ញុំពិតជាពុំដែលបានបង់ការប្រាក់ឱ្យ សហដើម

T. [signature]

Scanned with CamScanner

ចោទមែន តម្លៃការប្រាក់ព្រមព្រៀងគ្នា ៥% ក្នុង ០១ ខែ។ ចំពោះដំណោះស្រាយសង ខាងខ្ញុំសុំឱ្យសហដើមចោទទុកពេលឱ្យខាងខ្ញុំលក់ដីដាច់សិន ចំណែកការទាមទារ ៣ ចំណុចបន្ថែមទៀតរបស់សហដើមចោទ ដូចមានក្នុងពាក្យបណ្តឹងខាងលើ វាធ្ងន់ធ្ងរពេកសម្រាប់ខ្ញុំដែលមានរបរជាអ្នកលក់បាយបន្តិចបន្តួចក្នុងពេលបច្ចុប្បន្ន។

គ. ចំណុចវិវាទ និងចំណុចគ្មានវិវាទ៖

គ.១. ចំណុចគ្មានវិវាទ៖ គ្មាន។

គ.២. ចំណុចវិវាទ៖

១. តើចុងចម្លើយជំពាក់ប្រាក់ដើមចោទ ចំនួន ៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ឬ ជំពាក់ ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិក?

២. តើចុងចម្លើយជំពាក់ការប្រាក់ ចំនួន ១៨% ក្នុង ០១ ឆ្នាំ និងជំពាក់ការប្រាក់យឺតយ៉ាវ ចំនួន ១៨% ក្នុង ០១ ឆ្នាំ លើប្រាក់ដែលចុងចម្លើយជំពាក់ដើមចោទឬទេ?

ឃ. អំពីសេចក្តីសម្រេចរបស់តុលាការក្នុងកំណត់ហេតុ៖

ក្នុងរឿងក្តីនេះ តុលាការសម្រេចបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់យកកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ២ នាទី រសៀល។ តុលាការទុកពេល ០២ សប្តាហ៍ ដើម្បីឱ្យគូភាគីដាល់បញ្ចូលភស្តុតាង។

បញ្ចប់កំណត់ហេតុត្រឹមនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ នៅវេលាម៉ោង ១១ និង ៤៥ នាទី ព្រឹក នៅថ្ងៃខែឆ្នាំដូចខាងលើ។

ក្រឡាបញ្ជី

ចៅក្រមទទួលបន្ទុក

សហដើមចោទ

មេធាវីដើមចោទ

សហចុងចម្លើយ

Scanned with CamScanner

# របាយការណ៍បញ្ជូន
# កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
# (ឯកសារគំរូ)

## របាយការណ៍អំពីការបញ្ជូនឯកសារ

-ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី:

ក-កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី ______ ខែ __________ ឆ្នាំ ២០២៤
សំណុំរឿងរដ្ឋប្បវេណីលេខ __________ ចុះថ្ងៃទី _____ ខែ ________ ឆ្នាំ ២០២៤
ឈ្មោះឯកសារផ្ញើចេញ: កំណត់ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លេខ ________ /២៤
ចុះថ្ងៃទី ______ ខែ __________ ឆ្នាំ ២០២៤
អ្នកទទួលបន្ទុកកិច្ចការបញ្ជូនឯកសារនេះគឺ: លោក ឡាយ ឃី
អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងខេត្តកណ្តាល
លោក/លោកស្រីដែលត្រូវទទួលឯកសារបញ្ជូនទៅ: ឈ្មោះ ____________________ ។

ខ-ហត្ថលេខាឬស្នាមមេដៃអ្នកទទួលឯកសារដាក់ស្តែង ______________________________

_ប្រអប់ខាងក្រោមត្រូវបំពេញដោយប្រតិបត្តិការបញ្ជូន (កន្លែងប្រៃសណីយ៍, អាជ្ញាសាលា ឬក្រឡាបញ្ជី)។

ត

| | |
|---|---|
| ទីកន្លែងធ្វើការបញ្ជូនទៅ: ភូមិ ____________ ឃុំ ____________ ស្រុក __________ ខេត្តកណ្តាល។ | |
| កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី ____ ខែ ______ ឆ្នាំ ២០____ វេលាម៉ោង ____ ព្រឹក/រសៀល។ | |
| **វិធីដាក់ស្តែងក្នុងការបញ្ជូន** | |
| ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ ។ |
| | ☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអក្សរ ។ |
| ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យ ចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកត្រូវទទួលការបញ្ជូនដោយផ្ទាល់ នៅកន្លែងដែលត្រូវបញ្ជូននោះទេ។ |
| | ☐ អ្នកបំរើ ☐ អ្នកធ្វើការដែលនៅធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ ______________________________ |
| ៣ | ឯកសារត្រូវបានទុកនៅទីកន្លែងដែលធ្វើការបញ្ជូនទៅដោយហេតុថា: បុគ្គលខាងក្រោមនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។ |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ<br>☐ អ្នកនៅជាមួយ ☐ អ្នកធ្វើការដែលធ្វើការនៅទីនោះ |
| | ឈ្មោះ ______________________________ |
| ៤ ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ | |
| ៥ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅកន្លែងដែលត្រូវទទួលការបញ្ជូន ខ្ញុំមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលឯកសារនេះទេ។ | |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ______________________________ | |
| ឈ្មោះនិងហត្ថលេខាអ្នកធ្វើរបាយការណ៍: ______________________________ | |

CS Scanned with CamScanner

# ឧបសម្ព័ន្ធទី៧
# ឯកសារក្នុងដំណាក់កាល
# ការទាញហេតុផលដោយផ្ទាល់មាត់

# ដីកាកោះហៅ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្ដាល

តុលាការរដ្ឋប្បវេណី បន្ទប់ "ឋ"

លេខ: ៩៣៥ រ.ឋ/២៣

## ដីកាកោះហៅ

យើង ទ៉ាន់ សុបញ្ញា ចៅក្រមសាលាដំបូងខេត្តកណ្ដាល

អមដោយលោក ហ្វួយ ហ៊ី ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១១៩០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្ដាល ដែលមាន៖

ក. អត្តសញ្ញាណភាគី៖

សហដើមចោទ៖ ឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៧០ (អាយុ៥៣ ឆ្នាំ) និងប្រពន្ធឈ្មោះ ភេទស្រី កើតឆ្នាំ១៩៦៨ (អាយុ ៥៥ ឆ្នាំ) ជនជាតិ ខ្មែរ។

ទីលំនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្ដាល។

សហចុងចម្លើយ៖ ឈ្មោះ ភេទប្រុស កើតឆ្នាំ ១៩៨៣ (អាយុ ៤០ ឆ្នាំ) និងប្រពន្ធឈ្មោះ ភេទស្រី កើតឆ្នាំ ១៩៨៥ (អាយុ៣៨ ឆ្នាំ) ជនជាតិ ខ្មែរ។

ទីលំនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្ដាល។

ខ. សញ្ញាណនៃរឿងក្ដី៖ សុំឱ្យចុងចម្លើយសងប្រាក់។

គ. គោលបំណងនៃការកោះហៅ៖

អញ្ជើញ៖ ឈ្មោះ និងប្រពន្ធឈ្មោះ ដូចមានអត្តសញ្ញាណខាងលើ។

ឱ្យចូលមកកាន់ ៖ តុលាការរដ្ឋប្បវេណី នៃសាលាដំបូងខេត្តកណ្ដាល បន្ទប់អក្សរ (ឋ)

<u>នៅថ្ងៃទី ..២១.. ខែ ..វិច្ឆិកា..... ឆ្នាំ២០២៣ វេលាម៉ោង ..៨.... ព្រឹក☒ រសៀល☐។</u>

ដើម្បីចូលរួម ៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល☐ នីតិវិធីនៃការសាកសួរ☐ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់☒ ការប្រកាសសាលក្រម☐។

សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងបានកំណត់ខាងលើនេះ។

ថ្ងៃ ពុធ ០៣ រោច ខែអស្សុជ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

ខេត្តកណ្ដាល ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣

ចៅក្រម

ទ៉ាន់ សុបញ្ញា

[illegible]

Scanned with CamScanner

# របាយការណ៍បញ្ជូន

## របាយការណ៍អំពីការបញ្ជូនឯកសារ

-ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី:

ក-កាលបរិច្ឆេទផ្ញើចេញ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០២៣
សំណុំរឿងរដ្ឋប្បវេណីលេខ ១១៩០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣
ឈ្មោះឯកសារផ្ញើចេញ ដីកាកោះហៅលេខ ៩៣៥ រ.ប/២៣ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣
អ្នកទទួលបន្ទុកកិច្ចការបញ្ជូនឯកសារគឺ ក្រឡាបញ្ជីលោក ហួយ ហ៊ី
អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូនទៅ សាលាដំបូងខេត្តកណ្ដាល។
លោក/លោកស្រីដែលត្រូវទទួលឯកសារបញ្ជូនទៅ លោក ___ និងលោកស្រី ___ ស្ថិតនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អ
ខេត្តកណ្ដាល

ខ-ហត្ថលេខា ឬស្នាមមេដៃអ្នកទទួលឯកសារផាក់ស្ដែង

........................................................... ........................................ ...........................

_ប្រអប់ខាងក្រោមត្រូវបំពេញដោយប្រតិបត្តិការបញ្ជូន (ភ្នាក់ងារប្រៃសណីយ៍ ឬអាជ្ញាសាលា ឬក្រឡាបញ្ជី)

គ | ទីកន្លែងធ្វើការបញ្ជូនទៅ: លោក លី សារឿន និងលោកស្រី ម៉េង ស្រីអូន ស្ថិតនៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្ដាល។

កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី........... ខែ................ ឆ្នាំ២០២៣ វេលាម៉ោង ...................... ព្រឹក/រសៀល

**វិធីជាក់ស្ដែងក្នុងការបញ្ជូន**

ង | [១] បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ។

☐ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអក្សរ ។

ច | [២] បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យ ចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកត្រូវទទួលការបញ្ជូនដោយផ្ទាល់ នៅកន្លែងដែលត្រូវបញ្ជូនទៅនោះទេ។

☐ អ្នកបំរើ ☐ អ្នកផ្សេងដែលនៅធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ

ឈ្មោះ ..............................................................................................................

ឆ | [៣] ឯកសារត្រូវបានទុកនៅទីកន្លែងដែលធ្វើការបញ្ជូនទៅ ដោយហេតុថា: បុគ្គលខាងក្រោមនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល។

☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ
☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ

ឈ្មោះ ..............................................................................................................

ជ | ☐ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើហើយ។

ឈ | ☐ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅកន្លែងដែលត្រូវទទួលការបញ្ជូន ខ្ញុំមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូនឬជនដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលឯកសារនេះទេ ។

ញ | កាលបរិច្ឆេទធ្វើរបាយការណ៍: ..............................................................................................

ឈ្មោះនិងហត្ថលេខាអ្នកធ្វើរបាយការណ៍: ..............................................................................

[illegible]
[illegible]

Scanned with CamScanner
Scanned with CamScanner

# លិខិតអញ្ជើញមេធាវី

## (ឯកសារគំរូ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

**តុលាការរដ្ឋប្បវេណី បន្ទប់ "...."**

លេខ: ................. /២៤

**លិខិតអញ្ជើញមេធាវី**

យើង **ទ៊ាន់ សុបញ្ញា** ចៅក្រមសាលាដំបូងខេត្តកណ្ដាល

អមដោយលោក **ហ្វយ ហ៊ី** ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ............... ចុះថ្ងៃទី ......... ខែ ............. ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកណ្ដាល។

- បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី ........ ខែ ............. ឆ្នាំ២០២៤ របស់ ............................. ដែលតំណាងដោយអគ្គនាយកលោក ............................. មានលោក .................... អត្តលេខ ........... ជាមេធាវីតំណាងដោយអាណត្តិ។

**អញ្ជើញ** ៖ លោកមេធាវី .................... អត្តលេខ ..........................។

**ការិយាល័យ** ៖ មានការិយាល័យនៅផ្ទះលេខ ........... ផ្លូវលេខ .......... សង្កាត់ ............. ខណ្ឌ ................. រាជធានីភ្នំពេញ។

**មកកាន់** ៖ សាលាដំបូងខេត្តកណ្ដាល មន្ទីរស៊ើបសួរ (ឈ) នៅថ្ងៃទី .......... ខែ ............ ឆ្នាំ ២០២៤ វេលាម៉ោង ............. និង ........ នាទី ព្រឹក□ រសៀល□។

**ដើម្បី** ៖ ចូលរួមការក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល□ ការទាញហេតុដោយផ្ទាល់មាត់□ នីតិវិធីនៃការសាកសួរ□។

**រឿងក្ដី** ៖ ប្ដឹងទាមទារប្រាក់។

**ក្នុងឋានៈជា** ៖ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ□ ចុងចម្លើយ□។

លោក-លោកស្រីត្រូវតែអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃ ............................... ខែ ................. ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨

ខេត្តកណ្ដាល ,ថ្ងៃទី ......... ខែ ............. ឆ្នាំ២០២៤

**ចៅក្រម**

Scanned with CamScanner

# ឧបសម្ព័ន្ធទី៨
# ឯកសារអំឡុងពេល
# ការទាញហេតុផលដោយផ្ទាល់មាត់

# បញ្ជីវត្តមាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

លេខ៖ ................/ឈ

## បញ្ជីរាយនាមជនជាប់ឆាក់ធិន

| ល.រ | ឈ្មោះ | ត្រូវជា | ផ្សេងៗ |
|---|---|---|---|
| ១ | [illegible] | ([illegible]) | T. elmw |
| ២ | [illegible] | ([illegible]) | |
| ៣ | [illegible] | ([illegible]) | |
| ៤ | | | |
| ៥ | | | |
| ៦ | | | |
| ៧ | | | |
| ៨ | | | |
| ៩ | | | |
| ១០ | | | |
| ១១ | | | |
| ១២ | | | |

ថ្ងៃ ........................ ខែ ..[illegible]... ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧
ខេត្តកណ្តាល, ថ្ងៃទី ..11..... ខែ ..[illegible].. ឆ្នាំ២០២៤.

ក្រឡាបញ្ជី

CS Scanned with CamScanner
CS Scanned with CamScanner

# កំណត់ហេតុស្តីពីការទាញហេតុដោយផ្ទាល់មាត់

## (ឯកសារគំរូ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

តុលាការរដ្ឋប្បវេណី បន្ទប់ "ឈ"

លេខ៖ ...................... /ឈ

### កំណត់ហេតុ

### ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

| | | |
|---|---|---|
| កាលបរិច្ឆេទនៃនីតិវិធី | ៖ | ថ្ងៃទី ..... ខែ ........ ឆ្នាំ២០២៤ វេលាម៉ោង .................. ព្រឹក។ |
| ទីតាំង | ៖ | បន្ទប់ "ឈ" នៃសាលាដំបូងខេត្តកណ្ដាល។ |
| ចៅក្រមទទួលបន្ទុករឿងក្តី | ៖ | លោក ទ៊ាន់ សុបញ្ញា ចៅក្រមសាលាដំបូងខេត្តកណ្ដាល |
| ក្រឡាបញ្ជីទទួលបន្ទុករឿងក្តី | ៖ | លោក ហួយ ហ៊ី ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល |
| សំណុំរឿងរដ្ឋប្បវេណី | ៖ | លេខ ........... ចុះថ្ងៃទី ......... ខែ ................ ឆ្នាំ២០២៤។ |
| សញ្ញាណនៃរឿងក្តី | ៖ | ប្តឹងសុំទាមទារប្រាក់។ |

**ក. អត្តសញ្ញាណភាគី**

**សហដើមចោទ៖**

ឈ្មោះ ...................

ភេទ ................. កើតនៅឆ្នាំ ............... (អាយុ ........ ឆ្នាំ) និងប្រពន្ធឈ្មោះ ................... ជនជាតិ...... សញ្ជាតិ...........។

ទីលំនៅភូមិ ................ ឃុំ ................... ស្រុក ......................... ខេត្តកណ្ដាល។

អ្នកតំណាងដោយអាណត្តិ៖ លោកស្រីមេធាវី .................... អត្តលេខ .........................។

**សហចុងចម្លើយ៖**

ឈ្មោះ ................. ភេទ ........... កើតឆ្នាំ ............... (អាយុ ......... ឆ្នាំ) និងប្រពន្ធឈ្មោះ ............. ជនជាតិ ............ សញ្ជាតិ .....................។

ទីលំនៅភូមិ ................. ឃុំ .................... ស្រុក ...................... ខេត្តកណ្ដាល។

អ្នកតំណាងដោយអាណត្តិ៖ .........................................។

**ខ. ខ្លឹមសារនៃសាលក្រមដែលសហដើមចោទទាមទារឱ្យតុលាការចេញ៖**

១. សុំទាមទារប្រាក់ដើម ចំនួន ..................... (.........................) ដុល្លារអាមេរិក។

២. ទាមទារការប្រាក់ ........% ក្នុង ០១ ឆ្នាំ លើប្រាក់ដើម ចំនួន .............. (.................) ដុល្លារអាមេរិក។

៣. ទាមទារការប្រាក់យឺតយ៉ាវ ...........% ក្នុង ០១ ឆ្នាំ លើប្រាក់ដើម ចំនួន ............ (............) ដុល្លារអាមេរិក។

CS Scanned with CamScanner

៤. សុំទាមទារសំណងជម្ងឺចិត្ត, ការខាតបង់ពេលវេលា, ថ្លៃសេវាផ្នែកច្បាប់ និងចំណាយផ្សេងៗ ចំនួន .................. (..................) រៀល។

៥. ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់សហចុងចម្លើយ។

**ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**១. អំពីវត្តមានភាគី៖**

- សហដើមចោទ៖ អវត្តមាន។

-មេធាវីរបស់ដើមចោទ៖ មានវត្តមាន។

- សហចុងចម្លើយ៖ មានវត្តមានប្រពន្ធឈ្មោះ ........................។

**២. អំពីដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ក. អំពីការផ្សះផ្សារ**

តុលាការពុំបានលើកអំពីសំណើផ្សះផ្សារចំពោះភាគីទាំងសងខាងទេ ដោយសាររឿងក្តីនេះ មិនអាចបើកកាលបរិច្ឆេទនៃការផ្សះផ្សារបាន។

**ខ. អំពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល៖**

**ខ.១. ចំពោះការទាមទារ៖**

១. សុំទាមទារប្រាក់ដើម ចំនួន .................. (..................) ដុល្លារអាមេរិក។

២. ទាមទារការប្រាក់ ........ % ក្នុង ០១ ឆ្នាំ លើប្រាក់ដើម ចំនួន ................ (...............) ដុល្លារអាមេរិក។

៣. ទាមទារការប្រាក់យឺតយ៉ាវ ១៨% ក្នុង ០១ ឆ្នាំ លើប្រាក់ដើម ចំនួន ៧៤០០ ដុល្លារអាមេរិក។

៤. សុំទាមទារសំណងជម្ងឺចិត្ត, ការខាតបង់ពេលវេលា, ថ្លៃសេវាផ្នែកច្បាប់ និងចំណាយផ្សេងៗ ចំនួន ................ (..............) រៀល។

**សហដើមចោទ៖** នាងខ្ញុំជាមេធាវីតំណាងឱ្យសហដើមចោទ នៅតែរក្សាការទាមទារដូចការទារក្នុងពាក្យបណ្តឹងរបស់កូនក្តីនាងខ្ញុំ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ដដែល ដោយសារសហចុងចម្លើយបានខ្ចីប្រាក់ពីកូនក្តីនាងខ្ញុំ កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ ចំនួន ................ (...............) ដុល្លារអាមេរិក ដោយមានកិច្ចសន្យាជាលាយលក្ខអក្សរត្រឹមត្រូវ ហើយសហចុងចម្លើយនៅពុំទាន់បានសងប្រាក់ដើមឱ្យកូនក្តីនាងខ្ញុំនៅឡើយ សូម្បីតែការប្រាក់ក៏សហចុងចម្លើយពុំដែលបានបង់ឱ្យកូនក្តីនាងខ្ញុំមួយរៀលឡើយ កូនក្តីនាងខ្ញុំព្យាយាមទាមទារយ៉ាងណា ក៏សហចុងចម្លើយខាងលើ តែងតែគេចវេះនិយាយដោះសាមិនព្រមសងជានិច្ច។

**សហចុងចម្លើយ៖**

ឈ្មោះ .............. បានធ្វើសេចក្តីថ្លែងការណ៍ថា៖ នាងខ្ញុំទទួលស្គាល់ថា នាងខ្ញុំពិតជាជំពាក់ប្រាក់សហដើមចោទឈ្មោះ ................ ភេទ ប្រុស និងប្រពន្ធឈ្មោះ ............ ចំនួន ................ (..............) ដុល្លារអាមេរិកមែនតែមិនមែនជំពាក់ដល់ ................ (...............) ដុល្លារអាមេរិកទេ ហើយកន្លងមកខ្ញុំពិតជាពុំដែលបានបង់ការប្រាក់ឱ្យសហ

CS Scanned with CamScanner

ដើមចោទមែន តម្លៃការប្រាក់ព្រមព្រៀងគ្នា ៥% ក្នុង ០១ ខែ។ ចំពោះដំណោះស្រាយសង នាងខ្ញុំសុំឱ្យសហដើមចោទទុកពេលឱ្យនាងខ្ញុំលក់ដីដាច់សិន ចំណែកការទាមទារ ៣ ចំណុចបន្ថែមទៀតរបស់សហដើមចោទ ដូចមានក្នុងពាក្យបណ្តឹងខាងលើ វាធ្ងន់ធ្ងរពេកសម្រាប់ខ្ញុំដែលមានរបរជាអ្នកលក់បាយបន្តិចបន្តួចក្នុងពេលបច្ចុប្បន្ន។

**គ. ចំណុចវិវាទ និងចំណុចគ្មានវិវាទ៖**

**គ.១. ចំណុចគ្មានវិវាទ៖ គ្មាន។**

**គ.២. ចំណុចវិវាទ៖**

១. តើចុងចម្លើយជំពាក់ប្រាក់ដើមចោទ ចំនួន ................ (..............) ដុល្លារអាមេរិក ឬជំពាក់ ................ (...............) ដុល្លារអាមេរិក?

២. តើចុងចម្លើយជំពាក់ការប្រាក់ ចំនួន ...... % ក្នុង ០១ ឆ្នាំ និងជំពាក់ការប្រាក់យឺតយ៉ាវ ចំនួន .......% ក្នុង ០១ ឆ្នាំ លើប្រាក់ដែលចុងចម្លើយជំពាក់ដើមចោទឬទេ?

**ឃ. អំពីសេចក្តីសម្រេចរបស់តុលាការក្នុងកំណត់ហេតុ៖**

ក្នុងរឿងក្តីនេះ តុលាការសម្រេចបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់យកកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ....... ខែ ............ ឆ្នាំ២០២៤ វេលាម៉ោង ...... រសៀល។ តុលាការទុកពេល ០២ សប្តាហ៍ ដើម្បីឱ្យគូភាគីដាល់បញ្ចូលភស្តុតាង។

បញ្ចប់កំណត់ហេតុត្រឹមនៅថ្ងៃទី ......... ខែ ............ ឆ្នាំ២០២៤ នៅវេលាម៉ោង ១១ និង ៤៥ នាទី ព្រឹក នៅថ្ងៃខែឆ្នាំដូចខាងលើ៕

**ក្រឡាបញ្ជី** **ចៅក្រមទទួលបន្ទុក**

**សហដើមចោទ** **មេធាវីដើមចោទ** **សហចុងចម្លើយ**

CS Scanned with CamScanner

# របាយការណ៍
# ការផ្ញើកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់
# (ឯកសារគំរូ)

## របាយការណ៍អំពីការបញ្ជូនឯកសារ

-ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី:

ក-កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី ______ ខែ __________ ឆ្នាំ ២០២៤

សំណុំរឿងរដ្ឋប្បវេណីលេខ __________ ចុះថ្ងៃទី _____ ខែ _______ ឆ្នាំ ២០២៤

ឈ្មោះឯកសារផ្ញើចេញ: កំណត់ហេតុទាញហេតុផលដោយផ្ទាល់មាត់ លេខ _______ ចុះថ្ងៃទី _____ ខែ _______ ឆ្នាំ ២០២៤

អ្នកទទួលបន្ទុកកិច្ចការបញ្ជូនឯកសារនេះគឺ: លោក ឃ្លុយ បឿ

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងខេត្តកណ្ដាល

លោក/លោកស្រីដែលត្រូវទទួលឯកសារបញ្ជូនទៅ: ឈ្មោះ ____________________ ។

ខ-ហត្ថលេខាឬស្នាមមេដៃអ្នកទទួលឯកសារដាក់ពិស្តារ ____________________

-ប្រអប់ខាងក្រោមត្រូវបំពេញដោយប្រតិបត្តិការបញ្ជូន (កន្លាប្រែលណីយ៍, អាជ្ញាសាលា ឬក្រឡាបញ្ជី)។

ឃ ទីកន្លែងធ្វើការបញ្ជូនទៅ: ភូមិ ____________ ឃុំ ____________ ស្រុក ____________ ខេត្តកណ្ដាល។

កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី ____ ខែ ______ ឆ្នាំ ២០____ វេលាម៉ោង ____ ព្រឹក/រសៀល។

### វិធីដាក់ពិស្តារក្នុងការបញ្ជូន

ង [១] បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ ។

☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន គូរខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអក្សរ ។

ច [២] បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យ ចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកត្រូវទទួលការបញ្ជូនដោយផ្ទាល់ នៅកន្លែងដែលត្រូវបញ្ជូននោះទេ។

☐ អ្នកបំរើ ☐ អ្នកធ្វើរដែលនៅធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ

ឆ ឈ្មោះ ____________________

[៣] ឯកសារត្រូវបានទុកនៅទីកន្លែងដែលធ្វើការបញ្ជូនទៅដោយហេតុថា: បុគ្គលខាងក្រោមនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។

☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ

☐ អ្នកនៅជាមួយ ☐ អ្នកធ្វើរដែលធ្វើការនៅទីនោះ

ជ ឈ្មោះ ____________________

[៤] ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ

ឈ [៥] ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅកន្លែងដែលត្រូវទទួលការបញ្ជូន ខ្ញុំមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលឯកសារនេះទេ។

កាលបរិច្ឆេទធ្វើរបាយការណ៍: ____________________

ញ ឈ្មោះនិងហត្ថលេខាអ្នកធ្វើរបាយការណ៍: ____________________

CS Scanned with CamScanner

# ឧបសម្ព័ន្ធទី៩
# ឯកសារក្នុងដំណាក់កាល
# ក្រោយសវនាការ

# សាលក្រម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

តុលាការរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណីលេខ ១១៩០

ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣

សាលក្រមរដ្ឋប្បវេណីលេខ ០៣៨/ឈ

ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

## សាលក្រម

ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ៖ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤។

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤។

ចៅក្រមជំនុំជម្រះ

លោក ច័ាន់ សុបញ្ញា ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាចៅក្រមជំនុំជម្រះ

ក្រឡាបញ្ជី

លោក ហួយ ហុី ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

ក. អំពីអត្តសញ្ញាណភាគី

សហដើមចោទឈ្មោះ ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

សហដើមចោទឈ្មោះ ភេទស្រី អាយុ ៥៥ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

អាសយដ្ឋានភូមិរកាក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ៖

លោកស្រី អត្តលេខ ជាសមាជិក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យផ្ទះលេខ ៦៦២ ផ្លូវលេខ ១៩២A ភូមិតាងៅ សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

សហចុងចម្លើយឈ្មោះ ភេទប្រុស អាយុ ៤០ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

សហចុងចម្លើយឈ្មោះ ភេទស្រី អាយុ ៤០ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។

អាសយដ្ឋានភូមិរកាក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

អង្គហេតុ និងចំណុចវិវាទ

ក. ខ្លឹមសារនៃពាក្យបណ្តឹងដែលដើមចោទទាមទារឱ្យតុលាការចេញ

១. ឱ្យសហចុងចម្លើយសងប្រាក់ដើមដែលបានខ្ចីចំនួន ៧,៤០០ (ប្រាំពីពាន់បួនរយ) ដុល្លារអាមេរិច មកឱ្យសហដើមចោទវិញ។

២. ឱ្យសហចុងចម្លើយសងការប្រាក់ចំនួន ១៨% ក្នុងមួយឆ្នាំ និងការប្រាក់យឺតយ៉ាវ ១៨ % ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៧,៤០០ (ប្រាំពីពាន់បួនរយ) ដុល្លារអាមេរិចមកឱ្យដើមចោទ គិតពីពេលបានខ្ចីចាប់ពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ រហូតមកដល់ថ្ងៃសងគ្រប់ចំនួន។

Scanned with CamScanner
Scanned with CamScanner

៣. ឱ្យសហចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា ថ្លៃសេវាផ្នែកច្បាប់ និងការចំណាយផ្សេងៗ ចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល មកឱ្យដើមចោទ។

៤. ប្រកាសសាលក្រមនេះ អាចអនុវត្តបណ្ដោះអាសន្នបាន។

៥. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

ខ. ដំណើររឿងក្ដី និងចំណុចវិវាទ

ខ.១. ការសង្ខេបអំពីរឿងក្ដី

ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ សហចុងចម្លើយបានខ្ចីប្រាក់ពីសហដើមចោទចំនួន ៧,៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិច ដោយបានព្រមព្រៀងបង់ការប្រាក់ចំនួន ៥% ក្នុងមួយខែ។ ចាប់តាំងពីថ្ងៃខ្ចីរហូតមកដល់ពេលបច្ចុប្បន្ន សហចុងចម្លើយពុំដែលបង់ការប្រាក់មកឱ្យដើមចោទ និងមិនបានសងប្រាក់ឱ្យដើមចោទដើមចោទផងដែរ ទោះបីសហដើមចោទព្យាយាមសម្រុះសម្រួលទៅសាលាឃុំក៏ដូចជាមេភូមិយ៉ាងណាក៏ដោយ ក៏សហចុងចម្លើយព្យាយាមគេចវេស និងមិនព្រមសងដែរ។

ខ.២. អង្គហេតុដែលគ្មានវិវាទ៖ គ្មាន។

ខ.៣. អំពីចំណុចវិវាទ

ខ.៣.១. ស្ដីពីចំណុចវិវាទទី១៖ តើសហចុងចម្លើយជំពាក់ប្រាក់ដើមចោទចំនួន ៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិច ឬក៏ ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិច?

ខ.៣.២. ស្ដីពីចំណុចវិវាទទី២៖ តើសហចុងចម្លើយជំពាក់ការប្រាក់ចំនួន ១៨% ក្នុងមួយឆ្នាំ និងជំពាក់ការប្រាក់យឺតយ៉ាវចំនួន ១៨ % ក្នុងមួយឆ្នាំ លើប្រាក់ដែលចុងចម្លើយជំពាក់ដើមចោទឬទេ?

ខ.៤. ការអះអាងរបស់ភាគីស្ដីពីចំណុចវិវាទ

ខ.៤.១. ស្ដីពីចំណុចវិវាទទី១៖

ក. ការអះអាងរបស់ដើមចោទ៖ នាងខ្ញុំមេធាវីតំណាងឱ្យសហដើមចោទនៅតែរក្សាការទាមទារដូចការទាមទារក្នុងពាក្យបណ្ដឹងរបស់កូនក្ដីនាងខ្ញុំចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ដដែល ដោយសហចុងចម្លើយបានខ្ចីប្រាក់ពីកូនក្ដីនាងខ្ញុំ កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ ចំនួន ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិច ដោយមានកិច្ចសន្យាជាលាយល័ក្ខអក្សរត្រឹមត្រូវ។

ខ. ការអះអាងរបស់ចុងចម្លើយ៖ នាងខ្ញុំទទួលស្គាល់ថា នាងខ្ញុំពិតជាជំពាក់ប្រាក់សហដើមចោទឈ្មោះ សុក ណាស៊ី ភេទ ប្រុស និងប្រពន្ធឈ្មោះ ម៉ាត់ យ៉ាត់ ចំនួន ៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិចមែន តែមិនមែនជំពាក់ដល់ ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិកទេ។ កន្លងមកខ្ញុំពិតជាពុំដែលបានបង់ការប្រាក់ឱ្យសហដើមចោទមែន តម្លៃការប្រាក់ព្រមព្រៀងគ្នា ៥% ក្នុងមួយខែ។ ចំពោះដំណោះស្រាយសង នាងខ្ញុំសុំឱ្យសហដើមចោទទុកពេលឱ្យនាងខ្ញុំលក់ដីដាច់សិន ចំណែកការទាមទារទី៣ ចំណុចបន្ថែមទៀតរបស់សហដើមចោទដូចមានក្នុងពាក្យបណ្ដឹងខាងលើ វាធ្ងន់ធ្ងរពេកសម្រាប់ខ្ញុំដែលមានមុខរបរដែលជាអ្នកលក់បាយបន្តិចបន្តួចក្នុងពេលបច្ចុប្បន្ននេះ។

ខ.៤.២. ស្ដីពីចំណុចវិវាទទី២៖

Scanned with CamScanner
Scanned with CamScanner

ក. ការអះអាងរបស់ដើមចោទ៖ សហចុងចម្លើយនៅពុំទាន់បានសងប្រាក់ដើមឱ្យកូនក្ដីខាងខ្ញុំនៅឡើយទេ សូម្បីតែការប្រាក់ក៏សហចុងចម្លើយពុំដែលបានបង់ឱ្យកូនក្ដីខាងខ្ញុំមួយរៀលឡើយ កូនក្ដីខាងខ្ញុំព្យាយាមទាមទារយ៉ាងណា ក៏សហចុងចម្លើយខាងលើ តែងតែគេចវេសនិយាយដោះសារមិនព្រមសងជានិច្ច។

ខ. ការអះអាងរបស់ចុងចម្លើយ៖ កន្លងមកខ្ញុំពិតជាពុំដែលបានបង់ការប្រាក់ឱ្យសហដើមចោទមែន តម្លៃការប្រាក់គឺព្រមព្រៀងគ្នា ៥% ក្នុងមួយខែ។ ចំពោះដំណោះស្រាយសង ខាងខ្ញុំសុំឱ្យសហដើមចោទទុកពេលឱ្យខាងខ្ញុំលក់ដីដាច់សិន ចំណែកការទាមទារទី៣ ចំណុចបន្ថែមទៀតរបស់សហដើមចោទដូចមានក្នុងពាក្យបណ្ដឹងខាងលើ វាធ្ងន់ធ្ងរពេកសម្រាប់ខ្ញុំដែលមានមុខរបរដែលជាអ្នកលក់បាយបន្តិចបន្តួចក្នុងពេលបច្ចុប្បន្ននេះ។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យអំពីចំណុចវិវាទទី១៖

#### ក.១. ការទទួលស្គាល់អង្គហេតុ

ក្នុងរឿងក្ដីនេះ ដើមចោទបានទាមទារឱ្យចុងចម្លើយសងប្រាក់ចំនួន ៧,៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិក ដោយផ្អែកទៅលើកិច្ចសន្យាចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១។ ចុងចម្លើយបានទទួលស្គាល់នូវការទាមទារមួយផ្នែកចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក និងបានបដិសេធការទាមទារមួយផ្នែកចំនួន ៤០០ (បួនរយ) ដុល្លារអាមេរិក។ តាមលទ្ធផលនៃការពិនិត្យលើភស្តុតាងជាឯកសារឃើញថា កិច្ចសន្យាខ្ចីប្រាក់រវាងដើមចោទ និងចុងចម្លើយ បានចំនួន ២ (ពីរ) ផ្សេងគ្នា ដែលមានកម្មវត្ថុជាទឹកប្រាក់ចំនួន ៧,៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិក និងចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។ រវាងកិច្ចសន្យាទាំងពីរនេះ ឃើញថា មានទម្រង់តែមួយ និងខ្លឹមសារតែមួយ មានស្នាមមេដៃរបស់ចុងចម្លើយ គ្រាន់តែកិច្ចសន្យាមួយ មិនបានការបញ្ជាក់របស់មេភូមិរការក្រោម ហើយកិច្ចសន្យាមួយទៀត មានការបញ្ជាក់របស់មេភូមិរការក្រោម។ រវាងកិច្ចសន្យាទាំងពីរនេះ ឃើញថា កិច្ចសន្យាដែលមានការបញ្ជាក់របស់មេភូមិរការក្រោម អាចឱ្យតុលាការមានភាពជឿជាក់ជាង ហេតុនេះ តុលាការទទួលស្គាល់នូវអង្គហេតុដែលចុងចម្លើយបានខ្ចីប្រាក់ចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ពីដើមចោទ។

#### ក.២. ការវិនិច្ឆ័យ

តាមមាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី តុលាការសម្រេចបង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ឱ្យទៅសហដើមចោទ។ តុលាការពិនិត្យឃើញថា ដើមចោទ និងចុងចម្លើយ ពុំបាន

### ខ. ការវិនិច្ឆ័យអំពីចំណុចវិវាទទី២៖

#### ខ.១. ការទទួលស្គាល់អង្គហេតុ

១. ក្នុងរឿងក្ដីនេះ ដើមចោទទាមទារឱ្យចុងចម្លើយសងការប្រាក់ចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ។ សហចុងចម្លើយទទួលស្គាល់ថា កិច្ចសន្យារវាងដើមចោទ និងចុងចម្លើយ គឺចុងចម្លើយត្រូវបង់ការប្រាក់ឱ្យដើមចោទចំនួន ៥ (ប្រាំ) ភាគរយ ក្នុងមួយខែ ឬស្មើនឹង ៦០ (ហុក) ភាគរយ ក្នុងមួយឆ្នាំ។ តាមលទ្ធផលនៃការពិនិត្យភស្តុតាងឃើញថា ការប្រាក់ដែលដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នា (អត្រាការប្រាក់ក្នុងកិច្ចសន្យា) គឺលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតតាមមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី។ ហេតុនេះ តុលាការទទួលស្គាល់នូវអង្គហេតុដែលចុងចម្លើយជំពាក់ការប្រាក់ដើមចោទចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ។

Scanned with CamScanner
Scanned with CamScanner

២. ក្នុងរឿងក្ដីនេះ សហដើមចោទទាមទារឱ្យសហចុងចម្លើយបង់ការប្រាក់នៃការយឺតយ៉ាវចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ។ តាមមាត្រា ៣៩៩ (បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់) នៃក្រមរដ្ឋប្បវេណី ចែងថា "១-ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ទោះបីជាកូនបំណុលមានសំអាងបញ្ជាក់ថា ការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយប្រធានសក្តិក៏ដោយ ក៏កូនបំណុលនោះមិនអាចរួចផុតពីការសងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះបានដែរ។ ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះត្រូវគណនាតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់។ បើអត្រាការប្រាក់ក្នុងកិច្ចសន្យាខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ នោះត្រូវគណនាតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា។ ២-ចំពោះការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ ប្រសិនបើកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ នោះកូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។" ចំពោះចុងចម្លើយបានទទួលស្គាល់ថា មិនបានសងប្រាក់ និងការប្រាក់ឱ្យដើមចោទ ហេតុនេះឃើញថា ការទាមទារការប្រាក់នៃការយឺតយ៉ាវរបស់ដើមចោទ មានភាពត្រឹមត្រូវតាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី។ ដោយឡែក ចំពោះអត្រាការប្រាក់នៃការយឺតយ៉ាវដែលដើមចោទបានធ្វើការទាមទារវិញនោះឃើញថា មានភាពត្រឹមត្រូវតាមប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌។

ខ.២. ការវិនិច្ឆ័យ

១. តាមមាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី តុលាការសម្រេចបង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់ចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ ដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ឱ្យទៅសហដើមចោទ។

២. តាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី និងតាមប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ តុលាការសម្រេចបង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់នៃការយឺតយ៉ាវចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ ឱ្យទៅសហដើមចោទ។

**គ. ការវិនិច្ឆ័យអំពីការទាមទារចំណុចទី៣៖**

ដើមចោទឱ្យសហចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា ថ្លៃសេវាផ្នែកច្បាប់ ការចំណាយផ្សេងៗ ចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល។ មូលដ្ឋាននៃការពិចារណាលើការខូចខាតខាងផ្លូវចិត្ត គឺជាការពិនិត្យអំពីកាលៈទេសៈជុំវិញសំណុំរឿង ការទាមទារសោហ៊ុយសេវាកម្មច្បាប់របស់ដើមចោទ គឺជាចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាពត្វកិច្ច តាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី ហេតុនេះ តុលាការសម្រេចក្នុងភាពសមរម្យដោយបង្គាប់ឱ្យសហចុងចម្លើយរួមគ្នាដោយសាមគ្គីភាព បង់ចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាតព្វកិច្ចចំនួន ២.០០០.០០០ (ពីរលាន) រៀល ឱ្យទៅដើមចោទ។

**ឃ. អំពីការប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ន**

ក្នុងរឿងក្ដីនេះ ដើមចោទទាមទារឱ្យតុលាការធ្វើការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នទាំងអស់លើការទាមទាររបស់ខ្លួន។ តុលាការពិនិត្យឃើញថា ដើមចោទមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់អំពីអត្ថិភាពនៃ

Scanned with CamScanner
Scanned with CamScanner

សិទ្ធិទាមទារលើប្រាក់ដើម ការប្រាក់ ប៉ុន្តែមានវិវាទលើការទាមទារការប្រាក់នៃការយឺតយ៉ាវ ហេតុនេះតុលាការសម្រេចប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើម និងការប្រាក់។

ឃ. អំពីបន្ទុកនៃការប្រាក់ប្រដាប់ក្ដី

តាមមាត្រា ៦៤ មាត្រា ១៨២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការនឹងសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្ដី នៅសាលាដំបូងឱ្យជាបន្ទុករបស់សហចុងចម្លើយ។

## សេចក្ដីសម្រេចបញ្ចប់

ក. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ និងឈ្មោះ រួមគ្នាដោយសាមគ្គីភាព៖

១. បង់ប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ឱ្យទៅសហដើមចោទឈ្មោះ និងឈ្មោះ ។

២. បង់ការប្រាក់ចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ នៃប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ឱ្យទៅសហដើមចោទឈ្មោះ និងឈ្មោះ ។

៣. បង់ការប្រាក់នៃការយឺតយ៉ាវចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ នៃប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួនឱ្យទៅសហដើមចោទឈ្មោះ និងឈ្មោះ ។

៤. បង់ចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាតព្វកិច្ចចំនួន ២.០០០.០០០ (ពីរលាន) រៀល ឱ្យទៅសហដើមចោទឈ្មោះ និងឈ្មោះ ។

ខ. ប្រកាសអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុច ក.១ ចំណុច ក.២ នៃផ្នែកសេចក្ដីសម្រេចនៃសាលក្រមរដ្ឋប្បវេណីនេះ ហើយច្រានចោលការទាមទារលើសពីនេះ។

គ. ប្រាក់ប្រដាប់ក្ដីនៅជាន់សាលាដំបូង គឺជាបន្ទុករបស់ចុងចម្លើយ។

ថ្ងៃ ពុធ ៦ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្ដាល, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

ចៅក្រម

ទ៊ាន់_សុបញ្ញា

Scanned with CamScanner

# អនុសារសាលក្រម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
តុលាការរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណីលេខ ១១៩០
ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣
សាលក្រមរដ្ឋប្បវេណីលេខ ០៣៨/ឈ
ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

## សាលក្រម

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្តាល**

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ៖ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤។
កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤។

**ចៅក្រមជំនុំជម្រះ**

លោក ចាន់ សុបញ្ញា ចៅក្រមសាលាដំបូងខេត្តកណ្តាល និងជាចៅក្រមជំនុំជម្រះ

**ក្រឡាបញ្ជី**

លោក ហួយ ហ៊ី ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**ក. អំពីអត្តសញ្ញាណភាគី**

សហដើមចោទឈ្មោះ ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។
សហដើមចោទឈ្មោះ ភេទស្រី អាយុ ៥៥ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។
អាសយដ្ឋានភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។
អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ៖
លោកស្រី អត្តលេខ ជាសមាជិក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
ការិយាល័យផ្ទះលេខ ៦៦២ ផ្លូវលេខ ១៩២A ភូមិតាងៅ សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។
សហចុងចម្លើយឈ្មោះ ភេទប្រុស អាយុ ៤០ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។
សហចុងចម្លើយឈ្មោះ ភេទស្រី អាយុ ៤០ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។
អាសយដ្ឋានភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

**អង្គហេតុ និងចំណុចវិវាទ**

**ក. ខ្លឹមសារនៃពាក្យបណ្តឹងដែលដើមចោទទាមទារឱ្យតុលាការចេញ**

១. ឱ្យសហចុងចម្លើយសងប្រាក់ដើមដែលបានខ្ចីចំនួន ៧,៤០០ (ប្រាំពីពាន់បួនរយ) ដុល្លារអាមេរិច មកឱ្យសហដើមចោទវិញ។

២. ឱ្យសហចុងចម្លើយសងការប្រាក់ចំនួន ១៨% ក្នុងមួយឆ្នាំ និងការប្រាក់យឺតយ៉ាវ ១៨ % ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៧,៤០០ (ប្រាំពីពាន់បួនរយ) ដុល្លារអាមេរិចមកឱ្យដើមចោទ គិតពីពេលបានខ្ចីចាប់ពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ រហូតមកដល់ថ្ងៃសងគ្រប់ចំនួន។

Scanned with CamScanner

៣. ឱ្យសហចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា ថ្លៃសេវាផ្នែកច្បាប់ និងការចំណាយផ្សេងៗ ចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល មកឱ្យដើមចោទ។

៤. ប្រកាសសាលក្រមនេះ អាចអនុវត្តបណ្តោះអាសន្នបាន។

៥. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

**ខ. ដំណើររឿងក្តី និងចំណុចវិវាទ**

**ខ.១. ការសង្ខេបអំពីរឿងក្តី**

ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ សហចុងចម្លើយបានខ្ចីប្រាក់ពីសហដើមចោទចំនួន ៧,៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិច ដោយបានព្រមព្រៀងបង់ការប្រាក់ចំនួន ៥% ក្នុងមួយខែ។ ចាប់តាំងពីថ្ងៃខ្ចីរហូតមកដល់ពេលបច្ចុប្បន្ន សហចុងចម្លើយពុំដែលបង់ការប្រាក់មកឱ្យដើមចោទ និងមិនបានសងប្រាក់ឱ្យដើមចោទដើមចោទផងដែរ ទោះបីសហដើមចោទព្យាយាមសម្រុះសម្រួលទៅសាលាឃុំក៏ដូចជាមេភូមិយ៉ាងណាក៏ដោយ ក៏សហចុងចម្លើយព្យាយាមគេចវេស និងមិនព្រមសងដែរ។

**ខ.២. អង្គហេតុដែលគ្មានវិវាទ៖ គ្មាន។**

**ខ.៣. អំពីចំណុចវិវាទ**

**ខ.៣.១. ស្តីពីចំណុចវិវាទទី១៖ តើសហចុងចម្លើយជំពាក់ប្រាក់ដើមចោទចំនួន ៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិច ឬក៏ ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិច?**

**ខ.៣.២. ស្តីពីចំណុចវិវាទទី២៖ តើសហចុងចម្លើយជំពាក់ការប្រាក់ចំនួន ១៨% ក្នុងមួយឆ្នាំ និងជំពាក់ការប្រាក់យឺតយ៉ាវចំនួន ១៨ % ក្នុងមួយឆ្នាំ លើប្រាក់ដែលចុងចម្លើយជំពាក់ដើមចោទឬទេ?**

**ខ.៤. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ**

**ខ.៤.១. ស្តីពីចំណុចវិវាទទី១៖**

ក. ការអះអាងរបស់ដើមចោទ៖ នាងខ្ញុំមេធាវីតំណាងឱ្យសហដើមចោទនៅតែរក្សាការទាមទារដូចការទាមទារក្នុងពាក្យបណ្តឹងរបស់កូនក្តីនាងខ្ញុំចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ដដែល ដោយសហចុងចម្លើយបានខ្ចីប្រាក់ពីកូនក្តីនាងខ្ញុំ កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ ចំនួន ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិច ដោយមានកិច្ចសន្យាជាលាយល័ក្ខអក្សរត្រឹមត្រូវ។

ខ. ការអះអាងរបស់ចុងចម្លើយ៖ នាងខ្ញុំទទួលស្គាល់ថា នាងខ្ញុំពិតជាជំពាក់ប្រាក់សហដើមចោទឈ្មោះ ស្មុក ណាស៊ី ភេទ ប្រុស និងប្រពន្ធឈ្មោះ ម៉ាត់ យ៉ាត់ ចំនួន ៧០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិចមែន តែមិនមែនជំពាក់ដល់ ៧៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិកទេ។ កន្លងមកខ្ញុំពិតជាពុំដែលបានបង់ការប្រាក់ឱ្យសហដើមចោទមែន តម្លៃការប្រាក់ព្រមព្រៀងគ្នា ៥% ក្នុងមួយខែ។ ចំពោះដំណោះស្រាយសង នាងខ្ញុំសុំឱ្យសហដើមចោទទុកពេលឱ្យនាងខ្ញុំលក់ដីដាច់សិន ចំណែកការទាមទារទី៣ ចំណុចបន្ថែមទៀតរបស់សហដើមចោទដូចមានក្នុងពាក្យបណ្តឹងខាងលើ វាធ្ងន់ធ្ងរពេកសម្រាប់ខ្ញុំដែលមានមុខរបរដែលជាអ្នកលក់បាយបន្តិចបន្តួចក្នុងពេលបច្ចុប្បន្ននេះ។

**ខ.៤.២. ស្តីពីចំណុចវិវាទទី២៖**

Scanned with CamScanner
Scanned with CamScanner

ក. ការអះអាងរបស់ដើមចោទ៖ សហចុងចម្លើយនៅពុំទាន់បានសងប្រាក់ដើមឱ្យកូនក្តីខាងខ្ញុំនៅឡើយទេ សូម្បីតែការប្រាក់ក៏សហចុងចម្លើយពុំដែលបានបង់ឱ្យកូនក្តីខាងខ្ញុំមួយរៀលឡើយ កូនក្តីខាងខ្ញុំព្យាយាមទាមទារយ៉ាងណា ក៏សហចុងចម្លើយខាងលើ តែងតែគេចវេសនិយាយដោះសារមិនព្រមសងជានិច្ច។

ខ. ការអះអាងរបស់ចុងចម្លើយ៖ កន្លងមកខ្ញុំពិតជាពុំដែលបានបង់ការប្រាក់ឱ្យសហដើមចោទមែន តម្លៃការប្រាក់គឺព្រមព្រៀងគ្នា ៥% ក្នុងមួយខែ។ ចំពោះដំណោះស្រាយសង ខាងខ្ញុំសុំឱ្យសហដើមចោទទុកពេលឱ្យខាងខ្ញុំលក់ដីដាច់សិន ចំណែកការទាមទារទី៣ ចំណុចបន្ថែមទៀតរបស់សហដើមចោទដូចមានក្នុងពាក្យបណ្តឹងខាងលើ វាធ្ងន់ធ្ងរពេកសម្រាប់ខ្ញុំដែលមានមុខរបរដែលជាអ្នកលក់បាយបន្តិចបន្តួចក្នុងពេលបច្ចុប្បន្ននេះ។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យអំពីចំណុចវិវាទទី១៖

#### ក.១. ការទទួលស្គាល់អង្គហេតុ

ក្នុងរឿងក្តីនេះ ដើមចោទបានទាមទារឱ្យចុងចម្លើយសងប្រាក់ចំនួន ៧,៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិក ដោយផ្អែកទៅលើកិច្ចសន្យាចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១។ ចុងចម្លើយបានទទួលស្គាល់នូវការទាមទារមួយផ្នែកចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក និងបានបដិសេធការទាមទារមួយផ្នែកចំនួន ៤០០ (បួនរយ) ដុល្លារអាមេរិក។ តាមលទ្ធផលនៃការពិនិត្យលើភស្តុតាងជាឯកសារឃើញថា កិច្ចសន្យាខ្ចីប្រាក់រវាងដើមចោទ និងចុងចម្លើយ បានចំនួន ២ (ពីរ) ផ្សេងគ្នា ដែលមានកម្មវត្ថុជាទឹកប្រាក់ចំនួន ៧,៤០០ (ប្រាំពីរពាន់បួនរយ) ដុល្លារអាមេរិក និងចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក។ រវាងកិច្ចសន្យាទាំងពីរនេះ ឃើញថា មានទម្រង់តែមួយ និងខ្លឹមសារតែមួយ មានស្នាមមេដៃរបស់ចុងចម្លើយ គ្រាន់តែកិច្ចសន្យាមួយ មិនបានការបញ្ជាក់របស់មេភូមិរការក្រោម ហើយកិច្ចសន្យាមួយទៀត មានការបញ្ជាក់របស់មេភូមិរការក្រោម។ រវាងកិច្ចសន្យាទាំងពីរនេះ ឃើញថា កិច្ចសន្យាដែលមានការបញ្ជាក់របស់មេភូមិរការក្រោម អាចឱ្យតុលាការមានភាពជឿជាក់ជាង ហេតុនេះ តុលាការទទួលស្គាល់នូវអង្គហេតុដែលចុងចម្លើយបានខ្ចីប្រាក់ចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ពីដើមចោទ។

#### ក.២. ការវិនិច្ឆ័យ

តាមមាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី តុលាការសម្រេចបង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ឱ្យទៅសហដើមចោទ។ តុលាការពិនិត្យឃើញថា ដើមចោទ និងចុងចម្លើយ ពុំបាន

### ខ. ការវិនិច្ឆ័យអំពីចំណុចវិវាទទី២៖

#### ខ.១. ការទទួលស្គាល់អង្គហេតុ

១. ក្នុងរឿងក្តីនេះ ដើមចោទទាមទារឱ្យចុងចម្លើយសងការប្រាក់ចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ។ សហចុងចម្លើយទទួលស្គាល់ថា កិច្ចសន្យារវាងដើមចោទ និងចុងចម្លើយ គឺចុងចម្លើយត្រូវបង់ការប្រាក់ឱ្យដើមចោទចំនួន ៥ (ប្រាំ) ភាគរយ ក្នុងមួយខែ ឬស្មើនឹង ៦០ (ហុក) ភាគរយ ក្នុងមួយឆ្នាំ។ តាមលទ្ធផលនៃការពិនិត្យភស្តុតាងឃើញថា ការប្រាក់ដែលដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នា (អត្រាការប្រាក់ក្នុងកិច្ចសន្យា) គឺលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតតាមមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី។ ហេតុនេះ តុលាការទទួលស្គាល់នូវអង្គហេតុដែលចុងចម្លើយជំពាក់ការប្រាក់ដើមចោទចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ។

CS Scanned with CamScanner
CS Scanned with CamScanner

២. ក្នុងរឿងក្តីនេះ សហដើមចោទទាមទារឱ្យសហចុងចម្លើយបង់ការប្រាក់នៃការយឺតយ៉ាវចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ។ តាមមាត្រា ៣៩៩ (បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់) នៃក្រមរដ្ឋប្បវេណី ចែងថា "១-ចំពោះកាតព្វកិច្ចដែលមានគោលបំណងសងជាប្រាក់ ទោះបីជាកូនបំណុលមានសំអាងបញ្ជាក់ថា ការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយប្រធានសក្តិក៏ដោយ ក៏កូនបំណុលនោះមិនអាចរួចផុតពីការសងការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះបានដែរ។ ការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះត្រូវគណនាតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់។ បើអត្រាការប្រាក់ក្នុងកិច្ចសន្យាខ្ពស់ជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ នោះត្រូវគណនាតាមអត្រាការប្រាក់ក្នុងកិច្ចសន្យា។ ២-ចំពោះការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវ ប្រសិនបើកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ នោះកូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។" ចំពោះចុងចម្លើយបានទទួលស្គាល់ថា មិនបានសងប្រាក់ និងការប្រាក់ឱ្យដើមចោទ ហេតុនេះឃើញថា ការទាមទារការប្រាក់នៃការយឺតយ៉ាវរបស់ដើមចោទ មានភាពត្រឹមត្រូវតាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី។ ដោយឡែក ចំពោះអត្រាការប្រាក់នៃការយឺតយ៉ាវដែលដើមចោទបានធ្វើការទាមទារវិញនោះឃើញថា មានភាពត្រឹមត្រូវតាមប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌។

ខ.២. ការវិនិច្ឆ័យ

១. តាមមាត្រា ៥៩៤ នៃក្រមរដ្ឋប្បវេណី តុលាការសម្រេចបង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់ចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ ដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ឱ្យទៅសហដើមចោទ។

២. តាមមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី និងតាមប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ តុលាការសម្រេចបង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់នៃការយឺតយ៉ាវចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ ឱ្យទៅសហដើមចោទ។

**គ. ការវិនិច្ឆ័យអំពីការទាមទារចំណុចទី៣៖**

ដើមចោទឱ្យសហចុងចម្លើយសងជម្ងឺចិត្ត ការខាតបង់ពេលវេលា ថ្លៃសេវាផ្នែកច្បាប់ ការចំណាយផ្សេងៗ ចំនួន ២០,០០០,០០០ (ម្ភៃលាន) រៀល។ មូលដ្ឋាននៃការពិចារណាលើការខូចខាតខាងផ្លូវចិត្ត គឺជាការពិនិត្យអំពីកាលៈទេសៈជុំវិញសំណុំរឿង ការទាមទារសោហ៊ុយសេវាកម្មច្បាប់របស់ដើមចោទ គឺជាចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាតព្វកិច្ច តាមមាត្រា ៤០០ នៃក្រមរដ្ឋប្បវេណី ហេតុនេះ តុលាការសម្រេចក្នុងភាពសមរម្យដោយបង្គាប់ឱ្យសហចុងចម្លើយរួមគ្នាដោយសាមគ្គីភាព បង់ចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាតព្វកិច្ចចំនួន ២.០០០.០០០ (ពីរលាន) រៀល ឱ្យទៅដើមចោទ។

**ឃ. អំពីការប្រកាសឱ្យអនុវត្តបណ្តោះអាសន្ន**

ក្នុងរឿងក្តីនេះ ដើមចោទទាមទារឱ្យតុលាការធ្វើការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នទាំងអស់លើការទាមទាររបស់ខ្លួន។ តុលាការពិនិត្យឃើញថា ដើមចោទមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់អំពីអត្ថិភាពនៃ

Scanned with CamScanner
Scanned with CamScanner

សិទ្ធិទាមទារលើប្រាក់ដើម ការប្រាក់ ប៉ុន្តែមានវិវាទលើការទាមទារការប្រាក់នៃការយឺតយ៉ាវ ហេតុនេះតុលាការសម្រេចប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម និងការប្រាក់។

**ឃ. អំពីបន្ទុកនៃការប្រាក់ប្រដាប់ក្តី**

តាមមាត្រា ៦៤ មាត្រា ១៨២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការនឹងសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី នៅសាលាដំបូងឱ្យជាបន្ទុករបស់សហចុងចម្លើយ។

**សេចក្តីសម្រេចបញ្ចប់**

ក. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ និងឈ្មោះ រួមគ្នាដោយសាមគ្គីភាព៖

១. បង់ប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ឱ្យទៅសហដើមចោទឈ្មោះ និងឈ្មោះ ។

២. បង់ការប្រាក់ចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ នៃប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ឱ្យទៅសហដើមចោទឈ្មោះ , និងឈ្មោះ ។

៣. បង់ការប្រាក់នៃការយឺតយ៉ាវចំនួន ១៨ (ដប់ប្រាំបី) ភាគរយ ក្នុងមួយឆ្នាំ នៃប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួនឱ្យទៅសហដើមចោទឈ្មោះ និងឈ្មោះ ។

៤. បង់ចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាតព្វកិច្ចចំនួន ២.០០០.០០០ (ពីរលាន) រៀល ឱ្យទៅសហដើមចោទឈ្មោះ និងឈ្មោះ ។

ខ. ប្រកាសអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុច ក.១ ចំណុច ក.២ នៃផ្នែកសេចក្តីសម្រេចនៃសាលក្រមរដ្ឋប្បវេណីនេះ ហើយច្រានចោលការទាមទារលើសពីនេះ។

គ. ប្រាក់ប្រដាប់ក្តីនៅជាន់សាលាដំបូង គឺជាបន្ទុករបស់ចុងចម្លើយ។

ថ្ងៃ ពុធ ៦ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្តាល, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

ចៅក្រម

ហត្ថលេខា និងត្រា ទ៉ាន់ សុបញ្ញា

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ៦ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្តាល, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

បានឃើញ

ចៅក្រម

ក្រឡាបញ្ជី

ទ៉ាន់ សុបញ្ញា

ហួយ ហ៊ី

Scanned with CamScanner
Scanned with CamScanner

# របាយការណ៍បញ្ជូន
# អានុសាសន៍សាលក្រម
# (ឯកសារគំរូ)

## របាយការណ៍អំពីការបញ្ជូនឯកសារ

-ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី:

| |
|---|
| ក-កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី ______ ខែ __________ ឆ្នាំ ២០២៤ |
| សំណុំរឿងរដ្ឋប្បវេណីលេខ __________ ចុះថ្ងៃទី _____ ខែ _______ ឆ្នាំ ២០២៤ |
| ឈ្មោះឯកសារផ្ញើចេញ: អនុសាសន៍សាលក្រមរដ្ឋប្បវេណី លេខ _____ /____ ចុះថ្ងៃទី _____ ខែ _______ ឆ្នាំ ២០២៤ |
| អ្នកទទួលបន្ទុកកិច្ចការបញ្ជូនឯកសារនេះគឺ: លោក ឃួយ ឃី |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងខេត្តកណ្ដាល |
| លោក/លោកស្រីដែលត្រូវទទួលឯកសារបញ្ជូនទៅ: ឈ្មោះ ____________________ ។ |
| ខ-ហត្ថលេខាឬស្នាមមេដៃអ្នកទទួលឯកសារដាក់ពាក្យប្ដឹង ______________________________ |

_ប្រអប់ខាងក្រោមត្រូវបំពេញដោយប្រតិបត្តិការបញ្ជូន (កន្លែងប្រៃសណីយ៍, អាជ្ញាសាលា ឬក្រឡាបញ្ជី)។

| | |
|---|---|
| ទីកន្លែងធ្វើការបញ្ជូនទៅ: ភូមិ ____________ ឃុំ ____________ ស្រុក ____________ ខេត្តកណ្ដាល។ | |
| កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី ____ ខែ ______ ឆ្នាំ ២០____ វេលាម៉ោង ____ ព្រឹក/រសៀល។ | |
| **វិធីដាក់ពាក្យក្នុងការបញ្ជូន** | |
| ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ ។ |
| | ☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអក្សរ ។ |
| ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យ ចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកត្រូវទទួលការបញ្ជូនដោយផ្ទាល់ នៅកន្លែងដែលត្រូវបញ្ជូននោះទេ។ |
| | ☐ អ្នកបំរើ ☐ អ្នកធ្វើការដែលនៅធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ ______________________________________ |
| ៣ | ឯកសារត្រូវបានទុកនៅទីកន្លែងដែលធ្វើការបញ្ជូនទៅដោយហេតុថា: បុគ្គលខាងក្រោមនេះ មិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល ។ |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ<br>☐ អ្នកនៅជាមួយ ☐ អ្នកធ្វើការដែលធ្វើការនៅទីនោះ |
| | ឈ្មោះ ______________________________________ |
| ៤ ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ | |
| ៥ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅកន្លែងដែលត្រូវទទួលការបញ្ជូន ខ្ញុំមិនបានជួបនឹងជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យ ក្នុងការទទួលឯកសារនេះទេ។ | |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ______________________________ | |
| ឈ្មោះនិងហត្ថលេខាអ្នកធ្វើរបាយការណ៍: ______________________________ | |

CS Scanned with CamScanner

# ឧបសម្ព័ន្ធទី១០
# ពាក្យសុំបញ្ជាក់សាលក្រម
# និងសុំរូបមន្តអនុវត្ត

# ពាក្យសុំបញ្ជាក់សាលក្រម

| សាលាដំបូងខេត្តកណ្ដាល | |
|---|---|
| ចូល | លេខ: ៦៤ |
| | ថ្ងៃទី 09 ខែ 05 ឆ្នាំ 2024 |
| | ម៉ោង 2 និង 25 នាទី |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ពាក្យសុំបញ្ជាក់សាលក្រមស្ថាពរ**

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ៥៣ឆ្នាំ និងប្រពន្ធឈ្មោះ ភេទស្រី អាយុ៥៨ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីលំនៅសព្វថ្ងៃ ភូមិកោះក្របី ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្ដាល ។

សូមគោរពជូនចំពោះ
**ឯកឧត្ដមប្រធានសាលាដំបូងខេត្តកណ្ដាល**

លោកចៅក្រម និងក្រឡាបញ្ជី ទទួលបន្ទុក ពិនិត្យជាសបគ្គកិច្ច ។ *សូមជ្រាបៗ*

កម្មវត្ថុៈ សំណើសុំបញ្ជាក់ថាសាលក្រមរដ្ឋប្បវេណីលេខ: ០៣៨ / ឈ ចុះថ្ងៃទី៣១ -មករា -២០២៤ របស់សាលាដំបូងខេត្តកណ្ដាល ជាសាលក្រមស្ថាពរ ។

យោងៈ -សំណុំរឿងរដ្ឋប្បវេណីលេខៈ១១៩០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្ដាល ។

-សាលក្រមរដ្ឋប្បវេណីលេខ: ០៣៨ / ឈ ចុះថ្ងៃទី៣១ -មករា -២០២៤ របស់សាលាដំបូងខេត្តកណ្ដាល ។

តាមកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបថា : សាលាដំបូងខេត្តកណ្ដាលបានលើកយកសំណុំរឿងរដ្ឋប្បវេណីលេខៈ១១៩០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ មកធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់កាលពីថ្ងៃទី១១-មករា-២០២៤ និងបានប្រកាសសាលក្រមលេខ: ០៣៨ / ឈ ចុះថ្ងៃទី៣១-មករា-២០២៤ មកដល់ពេលនេះ សាលក្រមនេះបានចូលជាស្ថាពរហើយ ព្រោះគ្មានភាគីណាប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធានមេត្តាពិនិត្យ និងសម្រេចបញ្ជាក់សាលក្រមស្ថាពរ ដើម្បីឲ្យយើងខ្ញុំយកទៅប្រើប្រាស់តាមផ្លូវច្បាប់ដោយក្ដីអនុគ្រោះ ។

សូម ឯកឧត្តមប្រធាន ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស២៥៦៧
ធ្វើនៅកណ្ដាល, ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤
ស្នាមមេដៃស្ដាំ

Scanned with CamScanner

# ពាក្យសុំរូបមន្តអនុវត្ត

ទទួល
លេខ:...
ថ្ងៃទី ០៩ ខែ 05 ឆ្នាំ2024
ម៉ោង 2 និង 25 នាទី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំរូបមន្តអនុវត្ត**

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ៥៣ឆ្នាំ និងប្រពន្ធឈ្មោះ ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីលំនៅសព្វថ្ងៃ ភូមិរកាក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងខេត្តកណ្តាល**

លោកចៅក្រម និងក្រឡាបញ្ជី
ទូលបន្ទុក ពិនិត្យជាសមត្ថកិច្ច ។

*សូមមានប្រាប*

កម្មវត្ថុៈសំណើសុំរូបមន្តអនុវត្តសាលក្រមរដ្ឋប្បវេណីលេខៈ០៣៨/ឈ ចុះថ្ងៃទី៣១ -មករា -២០២៤ របស់សាលាដំបូងខេត្តកណ្តាល ។

យោងៈ-សំណុំរឿងរដ្ឋប្បវេណីលេខៈ ០៣៨ / ឈ ចុះថ្ងៃទី៣១ -មករា -២០២៤ របស់សាលាដំបូងខេត្តកណ្តាល ។

-សាលក្រមរដ្ឋប្បវេណីលេខៈ ០៣៨ / ឈ ចុះថ្ងៃទី៣១ -មករា -២០២៤ របស់សាលាដំបូងខេត្តកណ្តាល ។

តាមកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន ឯកឧត្តមប្រធាន មេត្តាជ្រាបថា : សាលាដំបូងខេត្តកណ្តាលបានលើកយកសំណុំរឿងរដ្ឋប្បវេណីលេខៈ១១៩០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ មកធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់កាលពីថ្ងៃទី១១-មករា-២០២៤ និងបានប្រកាសសាលក្រមលេខៈ ០៣៨ / ឈ ចុះថ្ងៃទី៣១-មករា-២០២៤ មកដល់ពេលនេះ សាលក្រមនេះបានចូលជាស្ថាពរហើយ ព្រោះគ្មានភាគីណាប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

អាស្រ័យហេតុនេះ សូម ឯកឧត្តមប្រធាន មេត្តាពិនិត្យ និងសម្រេចផ្តល់រូបមន្តអនុវត្តសាលក្រម ដើម្បីឲ្យយើងខ្ញុំយកទៅប្រើប្រាស់តាមផ្លូវច្បាប់ដោយក្តីអនុគ្រោះ ។

សូម ឯកឧត្តមប្រធាន ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស២៥៦៧
ធ្វើនៅកណ្តាល, ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤
ស្នាមមេដៃស្តាំ

Scanned with CamScanner

# ឧបសម្ព័ន្ធទី១១

# ករណីមានបណ្ដឹងឧទ្ធរណ៍

# លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

លេខ៖៧៩៧.០ ប.ស.ព/ឈ

## លិខិតបញ្ជាក់
## ការចូលជាស្ថាពរនៃសាលក្រម

យើង ហួយ ហ៊ី ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

_បានឃើញ មាត្រា ៣៥៤ និងមាត្រា ៣៥៥ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

_បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១១៩០ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកណ្ដាល។

_បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ០៣៨/ឈ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកណ្ដាល។

_បានឃើញ ពាក្យសុំបញ្ជាក់សាលក្រមស្ថាពរ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ របស់ឈ្មោះ

បច្ចុប្បន្ននៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្ដាល។

**បញ្ជាក់ថា:**

សាលក្រមរដ្ឋប្បវេណីលេខ ០៣៨/ឈ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកណ្ដាល បានចូលជាស្ថាពរចាប់ពី ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៤ នេះតទៅហើយ ដោយគូភាគីមិនបានចូលមកប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

យើងចេញលិខិតនេះ ដើម្បីអនុញ្ញាតឲ្យដាក់រូបមន្តអនុវត្តលើសាលក្រមនេះ សម្រាប់ឲ្យគូភាគីយកទៅអនុវត្តតាមច្បាប់។

ថ្ងៃ ព្រហស្បតិ៍ ៧ កើត ខែ ជេស្ឋ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨

ខេត្តកណ្ដាល, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤

ក្រឡាបញ្ជី

ហួយ_ហ៊ី

Scanned with CamScanner
Scanned with CamScanner

# រូបមន្តអនុវត្តសាលក្រម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

លេខ៖ ១៥០ វ.អ/ឈ

## រូបមន្តអនុវត្តសាលក្រម

យើង ហ្វយ ហ៊ី ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

_*បានឃើញ* មាត្រា ៣៥៤, មាត្រា ៣៥៥, មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

_*បានឃើញ* សាលក្រមរដ្ឋប្បវេណីលេខ ០៣៨/ឈ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកណ្តាល។

_*បានឃើញ* ពាក្យសុំរូបមន្តអនុវត្ត ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤ របស់ឈ្មោះ និងប្រពន្ធឈ្មោះ នៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

*សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តមានដូចខាងក្រោម*

*សហម្ចាស់បំណុលនៃការអនុវត្ត៖* ឈ្មោះ និងប្រពន្ធឈ្មោះ នៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

*អាចអនុវត្តដោយបង្ខំ៖* តាមសេចក្តីសម្រេចនៃសាលក្រមលេខ ០៣៨/ឈ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តកណ្តាល។

*ពីសហកូនបំណុលនៃការអនុវត្ត៖*

១-ឈ្មោះ ភេទ ប្រុស អាយុ ៤០ ឆ្នាំ ជនជាតិ ខ្មែរ។

២-ឈ្មោះ ភេទ ស្រី អាយុ ៤០ ឆ្នាំ ជនជាតិ ខ្មែរ។

នៅភូមិរការក្រោម ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល។

*សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ណ្ណនៃការអនុវត្តដោយបង្ខំ អនុវត្តឱ្យបានសម្រេចតាមសាលក្រមនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។*

ថ្ងៃ ព្រហស្បតិ៍ ៧ កើត ខែ ជេស្ឋ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨
ខេត្តកណ្តាល, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤

ក្រឡាបញ្ជី

ហ្វយ_ហ៊ី

Scanned with CamScanner
Scanned with CamScanner

# ឧបសម្ព័ន្ធទី១១
# ដីកាបញ្ជូនសំណុំរឿង
# ទៅតុលាការជាន់ខ្ពស់

# ដីកាបញ្ជូនទៅសាលាឧទ្ធរណ៍
## (ឯកសារគំរូ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
លេខ:...............................

**ដីកាបញ្ជូន**
**សូមគោរពជូន**
**ឯកឧត្តមប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | - | ០១ ច្បាប់ | "ដើម្បីគោរពជូនពិនិត្យ និងចាត់ការតាមនីតិវិធីច្បាប់" |
| ០២ | - | ០១ ច្បាប់ | |
| ០៣ | - | ០២ ច្បាប់ | |
| សរុប | | ០៤ ច្បាប់ | |

ថ្ងៃ.............ខែ.............ឆ្នាំ.............ព.ស ២៥៦......
ខេត្តកណ្តាល, ថ្ងៃទី..........ខែ...........ឆ្នាំ២០......
**ប្រធានសាលាដំបូង**

Scanned with CamScanner